

# សិទ្ធិដកដង្ហើម៖
# វគ្គបណ្តុះបណ្តាលស្តីពីសិទ្ធិមនុស្ស សម្រាប់សហគមន៍ ដែលរងផលប៉ះពាល់ ដោយសារជំងឺរបេង

*សៀវភៅណែនាំសម្រាប់អ្នកសម្របសម្រួល*


គាំទ្រ និងប្រែសម្រួលជាភាសាខ្មែរដោយ៖

KHANA
UNITED FOR A STRONGER COMMUNITY

ACT! ACTIVISTS' COALITION ON TB ASIA-PACIFIC

APCASO
Strengthening community systems. Advancing human rights.

Stop TB Partnership

## មាតិកា


សេចក្តីថ្លែងអំណរគុណ ....... ១

អក្សរកាត់....... ២

សេចក្តីណែនាំ....... ៣

ជំពូក១ : កំណត់សំគាល់សម្រាប់អ្នកសម្របសម្រួលវគ្គបណ្តុះបណ្តាល ....... ៨

អំពីសៀវភៅណែនាំបណ្តុះបណ្តាល ....... ៩

ទិដ្ឋភាពទូទៅនៃវគ្គបណ្តុះបណ្តាល ....... ១០

ទិដ្ឋភាពទូទៅនៃវគ្គបណ្តុះបណ្តាល ....... ១៣

កន្លែងបណ្តុះបណ្តាល និង សម្ភារៈគាំទ្រផ្សេងៗ ....... ១៤

ជំពូក ២ : ម៉ូឌុលបណ្តុះបណ្តាល....... ១៤

ក. សកម្មភាពបើកវគ្គបណ្តុះបណ្តាល....... ១៤

ខ. ស្ថានភាពជំងឺរបេង និងសិទ្ធិមនុស្ស ....... ១៨

គ. មូលដ្ឋានចំណេះដឹងអំពីជំងឺរបេង ....... ១៨

ឃ. វគ្គភ្ជាប់ទំនាក់ទំនងៈ បញ្ហាដែលទាក់ទងនឹងជំងឺរបេងនានា នៅសហគមន៍ ....... ២៧

ង. ជំងឺរបេង និងសិទ្ធិមនុស្ស....... ២៨

ច. ការគៀងគរសហគមន៍រងផលប៉ះពាល់ដោយសារជំងឺរបេង ដើម្បីចងក្រងឯកសារអំពីសិទ្ធិមនុស្ស....... ៤០

ឆ. ការតម្រង់ទិសលើការតស៊ូមតិ....... ៤៦

ជំពូកទី ៣ៈ ការបិទវគ្គបណ្តុះបណ្តាល ....... ៥៥

ជំពូកទី ៤ៈ ការវាយតម្លៃការបណ្តុះបណ្តាល ....... ៥៧

ឧបសម្ព័ន្ធ....... ៥៩

ឧបសម្ព័ន្ធ ១. កម្រងសំណួរតេស្តមុនវគ្គ / ក្រោយវគ្គ ....... ៥៩

ឧបសម្ព័ន្ធទី ២. គម្រូឧបករណ៍ចងក្រងឯកសារ....... ៦១

ឧបសម្ព័ន្ធ ៣ គម្រូការបញ្ជាក់ពីការយល់ព្រម ....... ៦២

ឧបសម្ព័ន្ធ ៤ៈ គម្រូនៃទម្រង់ផែនការតស៊ូមតិ ....... ៦៤

ឧបសម្ព័ន្ធទី ៥ៈ របៀបវារៈនៃវគ្គបណ្តុះបណ្តាលទាំងមូល ....... ៦៥

ឧបសម្ព័ន្ធទី ៦ៈ ទម្រង់វាយតម្លៃ....... ៦៨

# សិទ្ធិដកដង្ហើមៈ

## វគ្គបណ្តុះបណ្តាលស្តីពីសិទ្ធិមនុស្ស សម្រាប់សហគមន៍ដែលរងផលប៉ះពាល់ដោយសារជំងឺរបេង

វិច្ឆិកា ២០១៩

និពន្ធដោយ: អមារា ខេ្វសាដា (AMARA QUESADA)
អ្នកសម្របសម្រួល និង កែសម្រួល: ជេហ្វ្រី អាកាបា (JEFFRY ACABA)
អ្នករចនា និង រៀបប្លង់: ដារិន អេលាសារ ភើរិន (DARREN ELEAZAR PERREN)

**សម្ព័ន្ធសកម្មជននៃអ្នកជំងឺរបេង ប្រចាំតំបន់អាស៊ីប៉ាស៊ីភិច (ACT! AP)**

c/o APCASOapacaso

66/5 33 Tower Sukhumvit 33 Road, Klongton Nuea

Wattana, Bangkok 10110 Thailand

Email: apcasoteam@apcaso.org

ប្រែសម្រួលជាភាសាខ្មែរ ដោយក្រុមការងារផ្នែកគោលនយោបាយ ភាពជាដៃគូ និងពង្រឹងបណ្តាញនៃអង្គការខាណាៈ

1. ផង់ ចន្ទន (អ្នកសម្របសម្រួលជាន់ខ្ពស់ផ្នែកគោលនយោបាយ ភាពជាដៃគូ និងពង្រឹងបណ្តាញ)
2. រស់ កាហ្សាណែត (បុគ្គលិកហាត់ការផ្នែកទំនាក់ទំនង និងស្វែងរកការគាំទ្រ)
3. ជឹម ពុជារ៉ា (ជំនួយការផ្នែកភាពជាដៃគូ និងពង្រឹងបណ្តាញ)
4. ពុំ ជាតិប៉ុណ្ណា (ជំនួយការផ្នែកទំនាក់ទំនង និងយុទ្ធនាការ)

# សេចក្តីថ្លែងអំណរគុណ

ដំណើរការអភិវឌ្ឍន៍ សិទ្ធិដកដង្ហើម ៖ វគ្គបណ្តុះបណ្តាលស្តីពីសិទ្ធិមនុស្ស សម្រាប់សហគមន៍ដែលរងផលប៉ះពាល់ដោយសារជំងឺរបេង នឹងមិនអាចរៀបចំចងក្រងឡើងបានទេ បើគ្មានការគាំទ្រពី Stop TB Partnership និងប្រជាពលរដ្ឋអាមេរិកតាមរយៈ ទីភ្នាក់ងារសហរដ្ឋអាមេរិច ដើម្បីអភិវឌ្ឍអន្តរជាតិ (USAID) ។

សម្ព័ន្ធសកម្មជននៃអ្នកជំងឺរបេងប្រចាំតបន់អាស៊ី និងប៉ាស៊ីភិច (ACT! AP) និងអង្គការបណ្តាញ APCASO ពិតជាមានសេចក្តីសោមនស្សរីករាយក្រៃលែង ចំពោះលោកស្រី អមរា ខេ្វសាដា (Amara Quesada) ដែលបានដឹកនាំការចងក្រងសៀវភៅណែនាំមួយនេះ។ ការរៀបចំចងក្រងអភិវឌ្ឍន៍សៀវភៅណែនាំនេះ បានឆ្លងកាត់ការពិគ្រោះយោបល់ថ្នាក់តំបន់មួយ កាលពីថ្ងៃទី ២១ ដល់ ២២ ខែមីនា ឆ្នាំ ២០១៩ នៅទីក្រុងបាងកក ប្រទេសថៃ និង វគ្គបណ្តុះបណ្តាលសាកល្បងចំនួនពីរ នៅទីក្រុងម៉ានីល ប្រទេសហ្វីលីពីនដែលចាប់ផ្តើមពីថ្ងៃទី ២៦ ដល់ ២៨ ខែកក្កដា ឆ្នាំ ២០១៩ និងនៅទីក្រុងភ្នំពេញ ប្រទេសកម្ពុជាចាប់ពីថ្ងៃទី ១៩ ដល់ ២១ ខែសីហា ឆ្នាំ ២០១៩ ។ បន្ទាប់ពីនេះកិច្ចពិគ្រោះយោប់ទាំងអស់នេះ ក៏ដូចជាការចូលរួមចំណែកនានា ពី ៖ ជូប សុខចំរើន ផង់ ចន្ទន និងក្រុមការងារអង្គការខាណា (KHANA) សម្រាប់ការគាំទ្រនៅក្នុងកម្មវិធីសាកល្បងនៅកម្ពុជា អមរា ខេ្វសាដា (Amara Quesada) ជូនីលីន ចាដ្យូលីន (Junelyn Jadualin) អាល់ហ្វ្រេដ ពីធឺវេលច៍ ឡាក់បាយ៉ូ (Alfred Petterwelch Lacbayo) និងក្រុមការងារមកពី អង្គការអាឈីវ (ACHIEVE) ប្រទេសហ្វីលីពីន ដាញ៉ែល ម៉ាហ្គារី (Daniel Marguari) មកពី មូលនិធិស្ពីរីទា (Spiritia Foundation) ប្លេស៊ី គុម៉ារ (Blessi Kumar) មកពីសម្ព័ន្ធសកម្មជននៃអ្នកជំងឺរបេងសកល (Global Coalition of TB Activists) អែលវី ស៊ីអាហាន់ (Elvi Siahaan) មកពី MAP Internasional) និង ហ្វ្រេនស៊ីស ចូសេហ្វ (Francis Joseph) មកពីបណ្តាញនៃអ្នកប្រើប្រាស់គ្រឿងញៀនប្រចាំតំបន់អាស៊ី និងប៉ាស៊ីភិច (Asian Network of People who Use Drugs – ANPUD) សម្រាប់ផ្តល់ជាគោលគំនិតដើម្បីកំណត់ដាក់បញ្ចូលទៅក្នុងក្របខណ្ឌសៀវភៅណែនាំនេះ។ នៅក្នុងការបង្កើតសៀវភៅណែនាំនេះផងដែរ មានបុគ្គលមួយចំនួនទៀត ក៏បានចូលរួមចំណែកក្នុងការកំណត់នូវខ្លឹមសារ ការផ្តល់យោបល់ និងការពិនិត្យឡើងវិញនូវ មានដូចជា វីអូរែល ស៊ុលតង់ (Viorel Soltan) ជេម ម៉ាឡារ (James Malar) ឃ្វីវ៉ា ស្មីត (Caoimhe Smyth) និង ស្រីនីវ៉ាស់ នែរ (Sreenivas Nair) មកពី Stop TB Partnership ប្រាយអេន ស៊ីត្រូ (Brian Citro) មកពីសាកលវិទ្យាល័យ Northwestern University អាឡាន់ ម៉ាលេច (Allan Maleche) មកពី KELIN អាណា វើសហ្វែល (Anna Versfeld) និង ឌែលៀណា ហ្គាសៀ (Deliana Garcia) មកពីបណ្តាញ Migrant Clinicians Network។ ការសម្របសម្រួល និងការគាំទ្រផ្នែកបច្ចេកទេសពីក្រុមការងារអង្គការបណ្តាញ APCASO រួមមាន អឌី ម៉ាតេ (RD Marte) ជេនីហ្វឺ ហូ (Jennifer Ho) ជេហ្វ្រី អាកាបា (Jeffry Acaba) គ្រីស ប៉ាខនថាដាផន (Kris Pakornthadaphan) និង រ៉ូចាណា ស៊ីស៊ូវ៉ាណាគុល (Rojjana Seesuwanakul) ដែលបានធានានូវការផ្តល់ទិន្នន័យ និងដំណើការនៃសៀវភៅណែនាំនេះ តាមពេលវេលាកំណត់។

សម្ព័ន្ធសកម្មជននៃអ្នកជំងឺរបេងប្រចាំតបន់អាស៊ី និងប៉ាស៊ីភិច (ACT! AP) និងអង្គការបណ្តាញ APCASO សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ជូនចំពោះសហគមន៍ដែលរងផលប៉ះពាល់ដោយសារជំងឺរបេង បុគ្គលិកថែទាំសុខភាពផ្នែកជំងឺរបេង និង អង្គការក្នុងសហគមន៍ ដែលបានចូលរួមចំណែកធ្វើការងារឆ្លើយតប និងចូលរួមចែករំលែកក្នុងបទពិសោធន៍ដ៏ពិសេសទាំងអស់នេះ។

## អក្សរកាត់

ACHIEVE – សកម្មភាពសម្រាប់គំនិតផ្តួចផ្តើមសុខភាព ( Action for Health Initiatives )

ACT! AP – សម្ព័ន្ធសកម្មជននៃអ្នកជំងឺរបេងប្រចាំតបន់អាស៊ី និងប៉ាស៊ីភិច ( Activists Coalition on TB Asia-Pacific )

BCG - ថ្នាំវ៉ាក់សាំងបង្ការជំងឺរបេងបេសេហ្សេ ( Bacillus Calmette-Guérin )

CBNAAT – ឧបករណ៍សម្រាប់រកមេរោគរបេង និងរបេងស៊ាំថ្នាំរីហ្វាមពីស៊ីន ( Cartridge-based Nucleic Acid Amplification Test )

CSO – អង្គការសង្គមស៊ីវិល ( Civil Society Organisation )

DOTS – វិធីសាស្រ្តព្យាបាលដោយផ្ទាល់ ( Direct Observed Treatment Shortcourse )

HIV – ជំងឺអេដស៍ ( Human Immunodeficiency Virus )

HLM – កិច្ចប្រជុំកម្រិតខ្ពស់ ( High-Level Meeting )

HRBA – វិធីសាស្រ្តផ្អែកលើសិទ្ធិមនុស្សជាគោល ( Human Rights Based Approach )

LAM - ការធ្វើតេស្តទឹកនោម ( Lipoarabinomannan assay )

MDR- TB – របេងស៊ាំថ្នាំច្រើនមុខ ( Multi-drug Resistant Tuberculosis )

PLHIV – អ្នកផ្ទុកមេរោគអេដស៍ ( People Living with HIV )

TB – ជម្ងឺរបេង ( Tuberculosis )

UN – អង្គការសហប្រជាជាតិ ( United Nations )

## សេចក្តីណែនាំ

នៅក្នុងឆ្នាំ ២០១៨ ក្នុងចំណោមប្រជាជនចំនួន ៣,៩ ពាន់លាននាក់នៅក្នុងតំបន់អាស៊ី និងប៉ាស៊ីភិច មានមនុស្សចំនួន ៦,២លាននាក់ ត្រូវបានធ្វើរោគវិនិច្ឆ័យថាមានជំងឺរបេង។ តំបន់អាស៊ី និងប៉ាស៊ីហ្វិក បានរួមចំណែកដល់ជាង ៥០% នៃបន្ទុកជំងឺរបេងពិភពលោក និងជំងឺរបេងស៊ាំថ្នាំ ដែលជាជំងឺរាតត្បាតសកល ហើយត្រូវបានមើលរំលងក្នុងប្រវត្តិសាស្ត្រ ដោយភាគច្រើនបានប៉ះពាល់ដល់ប្រជាពលរដ្ឋរាប់លាននាក់ ដូចជាប្រជាពលរដ្ឋក្រីក្រ ប្រជាពលរដ្ឋងាយរងប៉ះពាល់ និងសហគមន៍ប្រឈមមុខខ្ពស់ផ្សេងៗទៀត។

ការអំពាវនាវរបស់សហគមន៍ពិភពលោក សម្រាប់ការផ្លាស់ប្តូរគម្រូក្នុងការឆ្លើយតបនឹងជំងឺរបេង ហើយបានឆ្លុះបញ្ចាំងនៅក្នុងផែនការសកល ដើម្បីបញ្ចប់ជំងឺរបេង[1] និងនៅក្នុងយុទ្ធសាស្ត្របញ្ចប់ជំងឺរបេងរបស់អង្គការWHO[2] រួមទាំងការផ្តោតកាន់តែខ្លាំងឡើងលើមនុស្ស សហគមន៍ និងតម្រូវការសម្រាប់វិធីសាស្ត្រផ្អែកលើសិទ្ធិមនុស្សជាគោល[3] ត្រូវបានចាប់ផ្តើមទទួលការយកចិត្តទុកដាក់ជាសកល។ នេះជាភស្តុតាងនៅក្នុងសេចក្តីថ្លែងការណ៍រួមរបស់សហគមន៍ និងសង្គមស៊ីវិល ដែលរងផលប៉ះពាល់ដោយជំងឺរបេង នៅមុនកិច្ចប្រជុំកម្រិតខ្ពស់របស់អង្គការសហប្រជាជាតិ (UN-HLM) ស្តីពីជំងឺរបេង នាខែកញ្ញាឆ្នាំ ២០១៨ ដែលជាតម្រូវការសំខាន់ ឱ្យមានការបញ្ចូលភាសា និង ខ្លឹមសារសិទ្ធិមនុស្សនៅក្នុងអង្គការសហប្រជាជាតិ (UN-HLM) ស្តីពីសេចក្តីប្រកាសនយោបាយស្តីពីជំងឺរបេង[4]។ សេចក្តីថ្លែងការណ៍នយោបាយដែលត្រូវបានអនុម័តនៅក្នុងកិច្ចប្រជុំកម្រិតខ្ពស់របស់អង្គការសហប្រជាជាតិ (UN-HLM) បន្ទាប់ពីការបញ្ចប់នីតិវិធីសម្ងាត់លើកទី២ ដែលត្រូវបានចេញផ្សាយនៅលើគេហទំព័រផ្លូវការ របស់ប្រធានអង្គមហាសន្និបាតរបស់អង្គការសហប្រជាជាតិ ដោយរក្សាទុកនូវភាសាសិទ្ធិមនុស្សជាច្រើន ដែលសង្គមស៊ីវិលចង់បាន នៅមុនកិច្ចប្រជុំកម្រិតខ្ពស់របស់អង្គការសហប្រជាជាតិ (UN-HLM) ស្តីពីជំងឺរបេង រួមទាំងការប្តេជ្ញាចិត្តចំពោះ៖ ការទទួលបានថ្នាំដែលមានតំលៃសមរម្យបញ្ចប់ការមាក់ងាយ និងការរើសអើងគ្រប់ទម្រង់ ការចូលរួមរបស់សហគមន៍ និងសង្គមស៊ីវិល ការទទួលស្គាល់ឧបសគ្គវប្បធម៌សង្គមផ្សេងៗក្នុងការទទួលបានសេវារបេង និងការអភិវឌ្ឍសេវាសុខភាពផ្អែកលើសហគមន៍តាមរយៈវិធីគាំពារ និងលើកកម្ពស់សមធម៌ សីលធម៌ សមភាពយេនឌ័រ និងសិទ្ធិមនុស្ស។ លើសពីនេះ ក៏មានកិច្ចខិតខំប្រឹងប្រែងផ្សេងៗទៀត ដើម្បីស្វែងយល់ពីឧបសគ្គក្នុងការទទួលបានបទពិសោធន៍ពីមនុស្សដែលរងផលប៉ះពាល់ដោយជំងឺរបេងតាមរយៈ៖ បរិយាកាសផ្នែកច្បាប់ជាតិ យេនឌ័រ ការមាក់ងាយ និង ការវាយតម្លៃប្រជាពលរដ្ឋគន្លឹះ[5] ដែលមានគាំទ្រដោយ Stop TB Partnership និង ឧបករណ៍លើកកម្ពស់ការចូលរួមរបស់សហគមន៍ រួមបញ្ចូលទាំង កម្មវិធី One Impact[6]។

---

1 *Global Plan to End TB* http://www.stoptb.org/assets/documents/global/plan/GlobalPlanToEndTB_TheParadigmShift_2016-2020_StopTBPartnership.pdf

2 *WHO End TB Strategy* https://www.who.int/tb/post2015_strategy/en/

3 *A Human Rights-based Approach to Tuberculosis: The Nairobi Strategy* (June 2016) found at: http://www.stoptb.org/assets/documents/communities/NairobyTBStrategyFINAL.pdf

4 *The Nairobi Strategy High Level Meeting on TB and Human Rights Communique* (August 2018) found at: http://www.kelinkenya.org/delegates-secure-the-voice-of-human-rights-in-tb-response-through-communique-to-the-un-high-level-meeting/

5 Stop TB Partnership: Community, Rights, and Gender webpage founda at http://www.stoptb.org/communities/

6 Stop TB Partnership OneImpact app found at https://stoptbpartnershiponeimpact.org/#

ក្នុងនាមសហគមន៍សកល នៃអ្នកតស៊ូមតិផ្នែកជំងឺរបេង ធ្វើការងារ ក្នុងការធានានូវការប្តេជ្ញាចិត្តផ្នែកនយោបាយកម្រិតខ្ពស់ សម្រាប់ការឆ្លើយតបនឹងជំងឺរបេង ដោយផ្អែកលើមូលដ្ឋានលើសិទ្ធិមនុស្ស និងស្វែងចេញនូវបញ្ហាសិទ្ធិមនុស្សនៅក្នុងបរិបទនៃជំងឺរបេង តាមរយៈសេចក្តីប្រកាសស្តីពីសិទ្ធិរបស់មនុស្សដែលរងផលប៉ះពាល់ដោយជំងឺរបេង[7] ការគៀងគរសហគមន៍ និងសង្គមស៊ីវិលនៅកម្រិតមូលដ្ឋានដែលជាកត្តាសារៈសំខាន់សម្រាប់ការពារ និងធ្វើឱ្យរដ្ឋាភិបាលទទួលខុសត្រូវចំពោះសិទ្ធិរបស់ប្រជាពលរដ្ឋ និងសហគមន៍ដែលរងផលប៉ះពាល់ដោយជំងឺរបេង។ យ៉ាងណាក្តី ការស្វែងយល់ និងការយល់ដឹងអំពីគោលការណ៍សិទ្ធិមនុស្សនៅតែមានកម្រិតទាប ក្នុងចំណោមមនុស្សដែលរស់នៅជាមួយជំងឺរបេង និងរងផលប៉ះពាល់ដោយជំងឺរបេង នៅក្នុងផ្នែកជាច្រើននៃតំបន់អាស៊ីប៉ាស៊ីភិច។ កិច្ចខិតខំប្រឹងប្រែងឆ្ពោះទៅរកការធ្វើសមាហរណកម្ម និងប្រតិបត្តិការគោលការណ៍សិទ្ធិមនុស្ស នៅក្នុងការឆ្លើយតបទៅនឹងជំងឺរបេងថ្នាក់ជាតិ ត្រូវបានជួបបញ្ហាបន្ថែមទៀត ដោយបរិយាបទនយោបាយរឹតត្បិត នៅផ្នែកជាច្រើនក្នុងតំបន់។

[7] *Declaration of the Rights of People Affected By Tuberculosis*
http://www.stoptb.org/assets/documents/communities/Declaration%20of%20the%20rights%20of%20people%20affected%20by%20TB%20-%20A5%20english%20version.pdf

## សេចក្តីប្រកាសអំពីសិទ្ធិរបស់មនុស្សដែលរងផលប៉ះពាល់ដោយជំងឺរបេង

| | |
|---|---|
| មាត្រា ២ | សិទ្ធិរស់រានមានជីវិត |
| មាត្រា ៣ | សិទ្ធិទទួលបានសេចក្តីថ្លៃថ្នូរ |
| មាត្រា ៤ | សិទ្ធិទទួលបានសុខភាពផ្លូវកាយ និងផ្លូវចិត្តកម្រិតស្តង់ដារខ្ពស់ (សិទ្ធិទទួលបានសុខភាព) |
| មាត្រា ៥ | សិទ្ធិក្នុងការរួចផុតពីការធ្វើទារុណកម្ម រងអំពើឃោរឃៅ អំពើអមនុស្សធម៌ ឬរងអំពើថោកទាប |
| មាត្រា ៦ | សិទ្ធិទទួលបានភាពស្មើគ្នា និងសេរីភាពដោយគ្មានការរើសអើង |
| មាត្រា ៧ | សិទ្ធិសេរីភាព និងសន្តិសុខបុគ្គល |
| មាត្រា ៨ | សេរីភាពក្នុងការធ្វើដំណើរ |
| មាត្រា ៩ | សិទ្ធិទទួលបានជីវិតឯកជន និង ជីវិតគ្រួសារ |
| មាត្រា ១០ | សិទ្ធិទទួលបានការរក្សាការសម្ងាត់ |
| មាត្រា ១១ | សិទ្ធិទទួលបានព័ត៌មាន |
| មាត្រា ១២ | សិទ្ធិទទួលបានការព្រមព្រៀង |
| មាត្រា ១៣ | សិទ្ធិទទួលបានការអប់រំ |
| មាត្រា ១៤ | សិទ្ធិធ្វើការ (សិទ្ធិការងារ) |
| មាត្រា ១៥ | សិទ្ធិទទួលបានអាហារគ្រប់គ្រាន់ |
| មាត្រា ១៦ | សិទ្ធិទទួលបានលំនៅដ្ឋាន |
| មាត្រា ១៧ | សិទ្ធិទទួលបានទឹកស្អាត និងអនាម័យ |
| មាត្រា ១៨ | សិទ្ធិទទួលបានសន្តិសុខសង្គម |
| មាត្រា ១៩ | សិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ |
| មាត្រា ២០ | សិទ្ធិសេរីភាពក្នុងការជួបប្រជុំ និងការបង្កើតសមាគម |
| មាត្រា ២១ | សិទ្ធិក្នុងការចូលរួម |
| មាត្រា ២២ | សិទ្ធិទទួលបានយុត្តិធម៌ និងតាមដំណើរការត្រឹមត្រូវ |
| មាត្រា ២៣ | សិទ្ធិទទួលបានអត្ថប្រយោជន៍នៃវឌ្ឍភាពវិទ្យាសាស្ត្រ (សិទ្ធិវិទ្យាសាស្ត្រ) |

ប្រភពៈ

http://www.stoptb.org/assets/documents/communities/Declaration%20of%20the%20rights%20of%20people%20affected%20by%20TB%20-%20A5%20english%20version.pdf

សម្ព័ន្ធសកម្មជននៃអ្នកជំងឺរបេងប្រចាំតបន់អាស៊ី និងប៉ាស៊ីភិច (ACT! AP)[8] និងសមាជិករបស់ខ្លួន ដែលរួមមានទាំងអង្គការខាណា (KHANA) នៅប្រទេសកម្ពុជា[9] និងសកម្មភាពសម្រាប់គំនិតផ្តួចផ្តើមសុខភាព (ACHIEVE) នៅប្រទេសហ្វីលីពីន[10,11] បានជ្រើសរើសជាទីកន្លែងយ៉ាងសំខាន់នៅក្នុងតំបន់ ដើម្បីបង្កើតវិធីសាស្រ្តច្នៃប្រឌិតថ្មីនេះ សម្រាប់បង្កើនការយល់ដឹង និងគាំទ្រទៅលើការគៀងគរ ការចូលរួមរបស់សហគមន៍ប្រកបដោយនិរន្តរភាពក្នុងការឆ្លើយតបជំងឺរបេងដោយផ្អែកលើសិទ្ធិមនុស្សជាមូលដ្ឋាន ។ សម្ព័ន្ធសកម្មជននៃអ្នកជំងឺរបេងប្រចាំតបន់អាស៊ី និងប៉ាស៊ីភិច (ACT! AP) បានប្រមូលផ្តុំពីសមាជិកនានា ដែឡមានបទពិសោធន៍យ៉ាងទូលំទូលាយក្នុងការធ្វើការជាមួយសហគមន៍ដែលងាយរងគ្រោះ ការគៀងគរ និងការចូលរួមរបស់សហគមន៍ ក៏ដូចជា ការរៀបចំ និង អនុវត្តសកម្មភាពនានាក្នុងការពង្រឹងសមត្ថភាពសហគមន៍នៅក្នុងប្រទេសរបស់ខ្លួន។

គោលដៅនៃគម្រោងមួយនេះ គឺដើម្បីពង្រឹងសមត្ថភាពដល់មនុស្សដែលរងផលប៉ះពាល់ដោយជំងឺរបេងនៅតំបន់អាស៊ី និងប៉ាស៊ីហ្វិក ក្នុងការជម្រុញលើភាពទំនួលខុសត្រូវរបស់រាជរដ្ឋាភិបាល និងអ្នកទទួលខុសត្រូវផ្សេងៗទៀត ដើម្បីទទួលបានសិទ្ធិរបស់ពួកគេ នៅក្នុងការអនុវត្តយុទ្ធសាស្រ្តជាតិស្តីពីជំងឺរបេង ។

នៅក្នុងសេចក្តីប្រកាសស្តីពីសិទ្ធិរបស់បុគ្គលដែលរងផលប៉ះពាល់ដោយជំងឺរបេង[12] សហគមន៍ដែលរងផលប៉ះពាល់ សំដៅទៅលើៈ បុគ្គលដែលជាអ្នករងផលប៉ះពាល់ដោយសារជំងឺរបេង ឬ បុគ្គលដែលធ្លាប់មានជំងឺរបេងពីមុន ក៏ដូចជាបុគ្គលដែលផ្តល់ការថែទាំទៅលើសមាជិកគ្រួសារ និង សមាជិកនៃជំងឺរបេងគន្លឹះ និងប្រជាពលរដ្ឋដែលងាយរងគ្រោះនានា ដូចជាកុមារ បុគ្គលិកថែទាំសុខភាព ជនជាតិដើមភាគតិច អ្នកផ្ទុកមេរោគអេដស៍ អ្នកប្រើប្រាស់គ្រឿងញៀន អ្នកជាប់ពន្ធនាគារឬកន្លែងឃុំឃាំង កម្មករអណ្តូងរ៉ែ ប្រជាពលរដ្ឋចល័ត ប្រជាពលរដ្ឋចំណាកស្រុក ស្រ្តី និងអ្នកក្រីក្រនៅទីក្រុង និងជនបទ។

## គោលបំណងបណ្តុះបណ្តាល

១. បង្កើនការយល់ដឹងរបស់សហគមន៍ដែលរងផលប៉ះពាល់ដោយជំងឺរបេង អំពីទំនាក់ទំនងរវាងសិទ្ធិមនុស្ស និងជំងឺរបេង។

២. កសាងសមត្ថភាពសហគមន៍ដែលរងផលប៉ះពាល់ដោយជំងឺរបេង ក្នុងការចងក្រងឯកសារស្តីពីការរំលោភបំពានសិទ្ធិមនុស្ស ដែលបានកើតឡើងចំពោះសហគមន៍ដែលរងផលប៉ះពាល់ដោយសារជំងឺរបេង

[8] https://apcaso.org/new-asia-pacific-coalition-of-tb-activists-launched/
[9] More information on KHANA Cambodia can be found at: https://www.khana.org.kh/
[10] More information on Action for Health Initiatives (ACHIEVE), Inc. Philippines can be found at: https://www.facebook.com/achieve.philippines.inc/
[11] Both KHANA Cambodia and ACHIEVE. Inc. in the Philippines are also Stop TB Partnerships' Challenge Facility for Civil Society grantees
[12] សេចក្តីប្រកាសអំពីសិទ្ធិរបស់ប្រជាជនដែលរងផលប៉ះពាល់ដោយជំងឺរបេង http://www.stoptb.org/assets/documents/communities/Declaration%20of%20the%20rights%20of%20people%20affected%20by%20TB%20-%20A5%20english%20version.pdf

៣. ពង្រឹងសមត្ថភាពសហគមន៍ដែលរងផលប៉ះពាល់ដោយជំងឺរបេង ក្នុងការចូលរួមក្នុងការងារស្វែងរកការគាំទ្រ ឬការតស៊ូមតិ ដែលរួមចំណែកជាមួយកម្មវិធីជាតិប្រយុទ្ធកំចាត់រោគរបេង កាន់តែមានភាពរឹងមាំ ក្នុងការដោះស្រាយឧបសគ្គនានា ដើម្បីទទួលបានសេវារបេង និងកាត់បន្ថយគម្លាតនានា នៅក្នុងការឆ្លើយតបរបេងក្នុងប្រទេស។

## ជំពូក១ : កំណត់សំគាល់សម្រាប់អ្នកសម្របសម្រួលវគ្គបណ្តុះបណ្តាល

សៀវភៅណែនាំវគ្គបណ្តុះបណ្តាលនេះត្រូវបានចងក្រងឡើង សម្រាប់អ្នកសម្របសម្រួលវគ្គ ដែលបម្រើការងារនៅក្នុងអង្គការសង្គមស៊ីវិល (CSO) ដែលអនុវត្តអន្តរាគមន៍អំពីជំងឺរបេង អេដស៍ និង សិទ្ធិមនុស្ស រួមទាំងបុគ្គលដែលមានបទពិសោធន៍រៀបចំវគ្គបណ្តុះបណ្តាលស្តីពីសិទ្ធិមនុស្សដល់សហគមន៍ដែលរងផលប៉ះពាល់ដោយជំងឺរបេង ឬ អេដស៍កន្លងមក។ នេះ គឺជាការកំណត់សំគាល់ដ៏សំខាន់មួយ ពីព្រោះវគ្គបណ្តុះបណ្តាលស្តីពីសិទ្ធិមនុស្សជាច្រើន មាននិន្នាការប្រែក្លាយជាទ្រឹស្តីច្រើនពេក។ យ៉ាងណាក៏ដោយ សម្រាប់អ្នកចូលរួមសហគមន៍ ពិតជាមានសារៈសំខាន់ណាស់ ដែលការពិភាក្សាអំពីសិទ្ធិមនុស្ស ត្រូវផ្អែកលើបទពិសោធន៍ប្រចាំថ្ងៃរបស់ពួកគាត់ ដូច្នេះអ្នកចូលរួមទាំងអស់ អាចយល់កាន់តែច្បាស់អំពីគោលគំនិតសិទ្ធិមនុស្ស ដែលនឹងត្រូវបានលើកយកមកពិភាក្សានៅក្នុងវគ្គបណ្តុះបណ្តាលនេះ។ បញ្ហាប្រឈមធំមួយទៀត គឺឈរលើគោលគំនិតសិទ្ធិមនុស្សនៅក្នុងបរិបទរបេង នឹងធ្វើឱ្យប្រាកដថា ទំនាក់ទំនងរវាងបញ្ហាទាំងពីរនេះ កាន់តែយល់ច្បាស់ដោយអ្នកចូលរួម។

ដោយសារភាពស្មុគស្មាញនៃបញ្ហាសិទ្ធិមនុស្ស និងជំងឺរបេង ការរៀបចំឱ្យបានគ្រប់គ្រាន់ អាចធ្វើឡើង ឬបែងចែកជាផ្នែកសម្រាប់សិក្ខាសាលានេះ។ មានការរៀបចំកម្រិតផ្សេងៗគ្នាជាច្រើន នៅមុនពេលវគ្គបណ្តុះបណ្តាលជាក់ស្តែងត្រូវបានធ្វើឡើង។ ក្នុងនាមជាអ្នកសម្របសម្រួលវគ្គបណ្តុះបណ្តាល អ្នកត្រូវមានការប្រុងប្រយ័ត្នចំពោះចំណុចខាងក្រោម៖

**ទីមួយ:** អ្នកត្រូវរៀបចំខ្លួនអ្នក ឱ្យក្លាយខ្លួនជាគ្រូបណ្តុះបណ្តាល។ អ្នកមិនត្រឹមតែបង្រៀនអ្នកចូលរួមរបស់អ្នក អំពីគំនិតដែរពិបាកនោះទេ ប៉ុន្តែអ្នកក៏ត្រូវបើកចិត្តឱ្យទូលំទូលាយ ក្នុងការទទួលចំណេះដឹងរៀនសូត្រ ពីការរស់នៅជាក់ស្តែងរបស់ពួកគាត់ រួមបញ្ចូលទាំង ផ្នែកច្បាប់ នយោបាយ សង្គម និង សេដ្ឋកិច្ច ដែលអ្នកចូលរួមទាំងអស់បានប្រឈម ពីព្រោះវគ្គបណ្តុះបណ្តាលទាំងមូល គឺផ្អែកលើបទពិសោធន៍របស់ពួកគាត់។ បើទោះបីជាសៀវភៅណែនាំនេះ នឹងផ្តល់ឱ្យអ្នកនូវការណែនាំលម្អិតម្តងមួយជំហានៗ អំពីដំណើរការសកម្មភាពក៏ដោយ ទាំងអស់នេះក៏ត្រូវអាស្រ័យលើអ្នកផងដែរ ក្នុងការស្វែងយល់ពីទំនាក់ទំនង ក្នុងចំណោមបទពិសោធន៍ និងគំនិតរបស់ពួកគាត់។

**ទីពីរ:** គោលការណ៍ និងគោលគំនិតសិទ្ធិមនុស្ស គោលនយោបាយ និងច្បាប់ គឺពិបាកធ្វើការបែងចែងនៅក្នុងបរិបទវគ្គបណ្តុះបណ្តាលផ្អែកលើសហគមន៍ ពីព្រោះអ្នកមិនចង់ធ្វើឱ្យអ្នកចូលរួមរបស់អ្នក មានការធុញទ្រាន់ជាមួយបទបង្ហាញស្លាយវែងអន្លាយនោះទេ ។ ចំណុចល្អនោះ គឺថាមនុស្សមានការយល់ដឹង នៅពេលដែលពួកគាត់ត្រូវបានគេធ្វើបាប រងអំពើអយុត្តិធម៌ ឬរងនូវទង្វើមិនស្មើភាពគ្នាណាមួយ។ បុគ្គលមួយចំនួនប្រហែលជាមិនដឹងថា សកម្មភាពអ្វីដែលត្រូវធ្វើ ដើម្បីឆ្លើយតបនឹងទង្វើអយុត្តិធម៌នោះទេ ហើយពួកគាត់ ក៏

ប្រហែលញឹកញាប់មិនយល់ពីភាសាសិទ្ធិមនុស្សផងដែរ ប៉ុន្តែពួកគាត់ដឹងដោយសភាវគតិនៅពេលដែរពួកគាត់ទទួលរងទង្វើខុសឆ្គងទាំងអស់នោះ ដែរបានកើតឡើងចំពោះពួកគាត់។

**ទីបី:** ទាំងអស់នេះ អាចមានផលពិបាកក្នុងការបញ្ចុះបញ្ចូលសហគមន៍ដែលរងផលប៉ះពាល់ពីជំងឺនានាដូចជាសហគមន៍រងផលប៉ះពាល់ដោយសារជំងឺរបេង ថាតើពួកគាត់មានសមត្ថភាពធ្វើអ្វីមួយសម្រាប់ស្ថានភាពរបស់ខ្លួនទេ។ នេះហើយជាមូលហេតុដែលធ្វើឱ្យការពង្រឹងសហគមន៍ ត្រូវការពេលវេលាយូរ និងក៏ជាមូលហេតុដែលសៀវភៅណែនាំវគ្គបណ្តុះបណ្តាលនេះ ជាផ្នែកមួយនៃកម្មវិធីកសាងសហគមន៍ដែលមានលក្ខណៈទូលំទូលាយ និងប្រកបដោយនិរន្តរភាព។ នៅក្នុងវគ្គបណ្តុះបណ្តាលនេះ សកម្មភាពសិក្សាដែលបានរៀបចំឡើង គឺឱ្យអ្នកចូលរួមយល់ដឹងអំពីតួនាទីសំខាន់ៗ ដែលពួកគេមាននៅក្នុងការផ្តួចផ្តើម និង ការផ្លាស់ប្តូរនៅសហគមន៍របស់ខ្លួន។

ជាសំណូមពរ អ្នកគួរពិនិត្យមើលសៀវភៅណែនាំទាំងមូល មុនពេលរៀបចំវគ្គបណ្តុះបណ្តាល ដើម្បីទទួលបាននូវគំនិតអំពីអ្វីៗគ្រប់យ៉ាងដែលចាំបាច់ ដែលត្រូវរៀបចំទុកជាមុន សម្រាប់ការបណ្តុះបណ្តាលជាក់ស្តែង។ ចំណុចនេះក៏អាចជួយអ្នកឱ្យមានទស្សនៈរួមអំពីរចនាសម្ព័ន្ធនៃវគ្គបណ្តុះបណ្តាលផងដែរ ដែលនឹងអនុញ្ញាតឱ្យអ្នកមើលពីរបៀបការផ្សារភ្ជាប់គ្នារវាម៉ូឌុលផ្សេងគ្នា និងដំណើរការឆ្ពោះទៅសម្រេចបានគោលបំណងនៃវគ្គបណ្តុះបណ្តាលទាំងមូល។

## អំពីសៀវភៅណែនាំបណ្តុះបណ្តាល

សៀវភៅណែនាំវគ្គបណ្តុះបណ្តាលនេះ ត្រូវបានចងក្រងឡើង ដោយសហគមន៍ដែលរងផលប៉ះពាល់ដោយជំងឺរបេង និងសកម្មជនរបស់ជំងឺរបេង ដើម្បីកសាង និងពង្រឹងសមត្ថភាពមនុស្សដែលរងផលប៉ះពាល់ដោយជំងឺរបេងយល់កាន់តែច្បាស់អំពីបញ្ហាសិទ្ធិមនុស្ស និងការរំលោភបំពាននានាដែលពួកគេបានជួបប្រទះ និងអាចឆ្លើយតបទៅនឹងបញ្ហាទាំងនោះ ប្រកបដោយលក្ខណៈស្ថាបនា។ សហគមន៍ដែលរងផលប៉ះពាល់ដោយជំងឺរបេង រួមទាំងសហគមន៍អ្នកកំពុងមានជំងឺរបេង អតីតអ្នកជំងឺរបេង និងប្រជាពលរដ្ឋងាយរងគ្រោះផ្សេងទៀត ដូចជាកុមារ បុគ្គលិកថែទាំសុខភាព ជនជាតិដើមភាគតិច អ្នកផ្ទុកមេរោគអេដស៍ អ្នកប្រើគ្រឿងញៀន អ្នកជាប់ពន្ធនាគារ កម្មការជីករ៉ែ ប្រជាពលរដ្ឋចល័ត ស្ត្រី អ្នកក្រីក្រនៅទីក្រុង និងជនបទ និងសមាជិកគ្រួសារ អ្នករស់នៅក្នុងបន្ទុក និងអ្នកមើលថែទាំរបស់អ្នកជំងឺរបេងផងដែរ។ សៀវភៅណែនាំនេះ ត្រូវបានរៀបចំឡើងជាចម្បងសម្រាប់សមាជិកនៃសហគមន៍ទាំងអស់នេះ ដែលពីមុនត្រូវបានចូលរួមជាមួយក្រុម និងបណ្តាញអ្នកជំងឺរបេង ឬអតីតអ្នកជំងឺរបេង ក្រុមគាំទ្រជំងឺរបេងសហគមន៍ ក៏ដូចជាអង្គការសង្គមស៊ីវិលដែលធ្វើសកម្មភាពពង្រឹងសមត្ថភាព និង សកម្មភាពតស៊ូមតិនានា[13]។

សៀវភៅណែនាំវគ្គបណ្តុះបណ្តាលនេះ ផ្អែកលើបទពិសោធន៍កន្លងមករបស់អ្នកចូលរួម ក្នុងការចូលរួមជាមួយការងារដែលពាក់ព័ន្ធនឹងជំងឺរបេង ឬសកម្មភាពនានាទាក់ទងនឹងសិទ្ធិមនុស្ស។ វគ្គបណ្តុះបណ្តាលនេះ មិនត្រូវបាន

[13] *Global Plan to End TB* http://www.stoptb.org/assets/documents/global/plan/GlobalPlanToEndTB_TheParadigmShift_2016-2020_StopTBPartnership.pdf

ណែនាំឱ្យបូកបញ្ចូលសមាជិកសហគមន៍ដែលទើបតែត្រូវបានគេធ្វើរោគវិនិច្ឆ័យថាមានជំងឺរបេងទេ ព្រោះពួកគាត់អាចត្រូវការការគាំទ្រភ្លាមៗ ឬ សេវាសុខភាពផ្លូវចិត្តសង្គម ដែលវគ្គបណ្តុះបណ្តាល នឹងមិនអាចផ្តល់ឱ្យបាននោះទេ។

វគ្គបណ្តុះបណ្តាល នឹងប្រព្រឹត្តទៅសម្រាប់រយៈពេលបីថ្ងៃ។ វគ្គនេះមានអន្តរកម្ម និងត្រូវបានរៀបចំឡើង ដើម្បីបង្កើនការចូលរួមរបស់អ្នកចូលរួម គ្រប់ចំនួនថ្ងៃ រួមជាមួយប្រធានបទដែលនឹងត្រូវបានគ្របដណ្តប់។ ជាការប្រសើរដែលមានអ្នកចូលរួមវគ្គបណ្តុះបណ្តាល ចាប់ពី ២០ ទៅ ២៥នាក់ ដើម្បីធានាបាននូវពេលវេលាគ្រប់គ្រាន់ សម្រាប់អ្នកចូលរួមក្នុងការចែករំលែកគោលគំនិត និងបទពិសោធន៍របស់ខ្លួនគេផ្ទាល់។

## ទិដ្ឋភាពទូទៅនៃវគ្គបណ្តុះបណ្តាល

សៀវភៅណែនាំនេះ មានតម្រូវការសំណុំម៉ូឌុលអប្បបរមា ដើម្បីឈានទៅសម្រេចបាន នូវគោលបំណងរបស់វគ្គបណ្តុះបណ្តាល ដែលបានរៀបរាប់នៅផ្នែកមុនៗ។ ថ្វីបើម៉ូឌុលនៅក្នុងសៀវភៅណែនាំនេះ ត្រូវបានរៀបចំឡើងនៅក្នុងវគ្គសិក្ខាសាលាបណ្តុះបណ្តាលតែមួយក៏ដោយ សកម្មភាពទាំងនេះអាចប្រព្រឹត្តទៅដោយឡែកពីគ្នា ដោយអាស្រ័យលើបរិបទរបស់អ្នកចូលរួមវគ្គបណ្តុះបណ្តាល។ ដូចគ្នាដែរ ម៉ូឌុលនីមួយៗអាចត្រូវបានផ្សំជាមួយម៉ូឌុលផ្សេងទៀតដែលសមស្របតាមតម្រូវការរបស់អ្នកចូលរួម។

ដូចវគ្គសិក្ខាសាលាបណ្តុះបណ្តាលទាំងអស់ដែរ វាមិនអាចជាសកម្មភាពតែមួយ និងឈរតែឯងបានទេ។ វគ្គនេះ គឺជាផ្នែកមួយនៃកម្មវិធីដ៏ទូលំទូលាយដែលត្រូវបានចងក្រងឡើង ដើម្បីបង្កើតចលនាសហគមន៍ក្នុងការចូលរួមចំណែកជួយបញ្ចប់ជំងឺរបេង។

គ្រប់ម៉ូឌុលទាំងអស់ គឺមានគោលបំណងផ្ទាល់ខ្លួនរបស់វា ដោយមានរយៈពេលជាក់លាក់ ដើម្បីដំណើរការ និងគួបផ្សំជាមួយបញ្ជីសម្ភារៈ។ មានការណែនាំពីជំហានមួយទៅជំហានមួយ នៅក្នុងសៀវភៅណែនាំនេះ ដើម្បីជួយអនុវត្តសកម្មភាពបន្ត នៅផ្នែកណាមួយ ដែលហៅថា *"ព័ត៌មានអប្បបរស្តង់ដារសម្រាប់ផ្តល់ធាតុចូល និងពិភាក្សា" (Minimum Standard Information for Input and Discussion)*។ ផ្នែកនេះអាចត្រូវបានចែករំលែកជាមួយអ្នកចូលរួម តាមរយៈបទបង្ហាញជាស្លាយ និងការពិភាក្សាគ្នា ។ ព័ត៌មានទាំងអស់នេះ ក៏អាចត្រូវបានរួមបញ្ចូល នៅក្នុងឯកសារដែលនឹងត្រូវបានចែកចាយដល់អ្នកចូលរួម សម្រាប់ជាឯកសារយោងផងដែរ។

ខាងក្រោម គឺជាសេចក្តីសង្ខេបនៃម៉ូឌុលដែលមាននៅក្នុងសៀវភៅណែនាំនេះ។ ដូចដែលបានរៀបរាប់រួចមកហើយ អ្នកសម្របសម្រួលវគ្គបណ្តុះបណ្តាល គួរតែពិនិត្យមើលសៀវភៅណែនាំទាំងមូល ដើម្បីទទួលបានការយល់ដឹងកាន់តែច្បាស់អំពីរបៀបដែលម៉ូឌុលត្រូវបានរៀបចំឡើង និងរបៀបដែលម៉ូឌុលផ្សារភ្ជាប់ទំនាក់ទំនងគ្នាពីមួយទៅមួយ។

1. **សកម្មភាពបើកវគ្គបណ្តុះបណ្តាល:** ដូចសកម្មភាពវគ្គបណ្តុះបណ្តាលភាគច្រើនដែរ ដោយមានការបើកចាប់ផ្តើម ដែលមាននៅក្នុងម៉ូឌុលនេះហៅថាសកម្មភាពបើកវគ្គបណ្តុះបណ្តាល។ ក្នុងវគ្គនេះ អ្នកសម្របសម្រួលនៃវគ្គ

បណ្តុះបណ្តាល និងអ្នកចូលរួមទាំងអស់ នឹងមានឱកាសស្គាល់គ្នា ក៏ដូចជាចែករំលែកការរំពឹងទុករបស់ពួកគេចំពោះវគ្គបណ្តុះបណ្តាលនេះ។ អ្នកសម្របសម្រួលវគ្គបណ្តុះបណ្តាល នឹងផ្តល់នូវទិដ្ឋភាពទូទៅ នៃគោលបំណងរបស់វគ្គបណ្តុះបណ្តាល និងប្រធានបទនានា ដែលនឹងត្រូវធ្វើការពិភាក្សា ក្នុងអំឡុងពេលវគ្គបណ្តុះបណ្តាលរយៈពេលបីថ្ងៃ។ ផ្នែកនេះ ក៏នឹងអនុញ្ញាតឱ្យអ្នកសម្របសម្រួលធ្វើការប្រៀបធៀបការរំពឹងទុករបស់អ្នកចូលរួម ទៅនឹងអ្វីដែលវគ្គបណ្តុះបណ្តាលអាចផ្តល់ជូន។ ការធ្វើតេស្តមុន នឹងត្រូវបានធ្វើឡើងផងដែរ នៅពេលចាប់ផ្តើមវគ្គបណ្តុះបណ្តាល។ ឧបករណ៍នេះនឹងផ្តល់ឱ្យក្រុមបណ្តុះបណ្តាលនូវមធ្យោបាយសមស្រប ដើម្បីវាយតម្លៃការរៀនសូត្ររបស់សិក្ខាកាម នៅចុងបញ្ចប់នៃវគ្គបណ្តុះបណ្តាលដោយប្រើប្រាស់ឧបករណ៍ការធ្វើតេសក្រោយវគ្គតម្លៃ។

2. **ស្ថានភាពជំងឺរបេង និងសិទ្ធិមនុស្ស:** ដើម្បីកំណត់បរិបទនៃវគ្គបណ្តុះបណ្តាលនេះ ម៉ូឌុលនេះនឹងផ្តល់នូវទិដ្ឋភាពទូទៅនៃស្ថានភាពជំងឺរបេងប និងសិទ្ធិមនុស្សបច្ចុប្បន្ននៅក្នុងប្រទេស ឬតំបន់ណាមួយដែលពាក់ព័ន្ធបំផុតចំពោះអ្នកចូលរួម។ វគ្គនេះនឹងផ្តល់ឱ្យអ្នកចូលរួមនូវគោលគំនិតអំពីទំហំនៃជំងឺរបេង ការវិវត្តនៃជំងឺ ក៏ដូចជាផលប៉ះពាល់ផ្នែកសិទ្ធិមនុស្ស។ ផ្នែកនេះ នឹងបង្កើតនូវហេតុផល ឬតម្រូវការសម្រាប់សហគមន៍ដែលរងផលប៉ះពាល់ដោយជំងឺរបេង ដើម្បីទទួលបានវគ្គបណ្តុះបណ្តាលអំពីជំងឺរបេងនិងសិទ្ធិមនុស្ស។
3. **មូលដ្ឋានចំណេះដឹងអំពីជំងឺរបេង:** នៅក្នុងម៉ូឌុលនេះ អ្នកចូលរួមនឹងឆ្លងកាត់វគ្គអន្តរកម្ម ដែលនឹងផ្តល់ឱ្យពួកគេនូវព័ត៌មានមូលដ្ឋានអំពីជំងឺរបេង របៀបឆ្លង របៀបការពារ និងការព្យាបាល។ អ្នកចូលរួមប្រហែលជាអាចដឹងព័ត៌មានខ្លះៗនៅក្នុងវគ្គនេះរួចមកហើយ ដូច្នេះ វាអាចជាការពិនិត្យឡើងវិញសម្រាប់អ្នកចូលរួមផងដែរ។ ផ្នែកនេះ ក៏នឹងផ្តល់ពេលវេលាដល់អ្នកចូលរួមក្នុងការបំផុសគំនិត និងស្វែងយល់ពីការយល់ឃើញរបស់សង្គមអំពីជំងឺរបេង និងមនុស្សដែលរងផលប៉ះពាល់ដោយសារជំងឺរបេង និងសហគមន៍ជំងឺរបេង។
4. **ការស្វែងយល់អំពីបញ្ហាសិទ្ធិមនុស្សក្នុងបរិបទជំងឺរបេង:** ម៉ូឌុលសិទ្ធិមនុស្សនេះ នឹងចំណាយពេលប្រហែលមួយថ្ងៃកន្លះ ដើម្បីបញ្ចប់។ នៅក្នុងម៉ូឌុលនេះ អ្នកចូលរួមនឹងស្វែងយល់អំពីព័ត៌មានមូលដ្ឋានអំពីសិទ្ធិមនុស្ស និងទទួលបានការយល់ដឹង អំពីបញ្ហាសិទ្ធិមនុស្សទាក់ទងនឹងជំងឺរបេង។
    a. ដើម្បីជួយអ្នកចូលរួមស្វែងយល់អំពីសិទ្ធិមនុស្ស ដែលជាគោលគំនិតមួយដែរ ម៉ូឌុលនឹងចាប់ផ្តើមដោយស្វែងយល់ពីបទពិសោធន៍របស់អ្នកចូលរួមនៅពេលមានជំងឺរបេង។ សម្រាប់សមាជិកនៃប្រជាពលរដ្ឋគន្លឹះ ដែលមិនទាន់បានជួបប្រទះជំងឺរបេង វគ្គដំបូងនៅក្នុងម៉ូឌុលនេះ នឹងស្វែងយល់ពីភាពភ័យខ្លាច និងក្តីបារម្ភរបស់ពួកគេអំពីជំងឺរបេង ដោយត្រូវបានអនុវត្តឡើងតាមរយៈលំហាត់សរសេរដែលអ្នកចូលរួមនឹងចែករំលែកនៅក្នុងក្រុម។ លើសពីនេះ បទពិសោធន៍ដែលនឹងត្រូវបានចែករំលែកនឹងត្រូវបានប្រើប្រាស់ ដើម្បីកំណត់បញ្ហាសិទ្ធិមនុស្ស ដែលទាក់ទងនឹងជំងឺរបេងនៅក្នុងវគ្គបន្ត។
    b. នៅក្នុងវគ្គបណ្តុះបណ្តាលនេះ អ្នកចូលរួមអាចនឹងមានអារម្មណ៍មិនសូវល្អ នៅពេលដែលពួកគេត្រូវចែករំលែកអំពីបទពិសោធន៍អំពីជំងឺរបេង ជាពិសេសប្រសិនបើពួកគាត់ រំលឹកពីបទពិសោធន៍អំពីការលំបាកនៃការព្យាបាល ឬការរើសអើង។ ដោយសារហេតុនេះហើយ ទើបមានកិច្ចពិភាក្សាត្រូវបានរួម

បញ្ចូលក្នុងសៀវភៅណែនាំនេះ ដើម្បីអនុញ្ញាតឱ្យអ្នកចូលរួមទម្លាក់បន្ទុកផ្លូវចិត្ត ចេញពីទ្រូងរបស់ពួកគេ ទើបអាចបន្តទៅវគ្គបន្ទាប់បាន។ សូមកត់សម្គាល់ថា វគ្គដែលបានពិពណ៌នានៅក្នុងសៀវភៅណែនាំនេះ គឺគ្រាន់តែជាការផ្តល់យោបល់ប៉ុណ្ណោះ។ អ្នកសម្របសម្រួលវគ្គបណ្តុះបណ្តាលអាចជ្រើសរើសវិធីសាស្ត្រផ្សេងៗ ដោយផ្អែកលើអ្វីដែលសមស្របសម្រាប់អ្នកចូលរួម។

c. ជំហានបន្ទាប់នៅក្នុងម៉ូឌុលនេះ នឹងតម្រូវឱ្យអ្នកចូលរួមត្រលប់ទៅក្រុមរបស់ពួកគេវិញ ដើម្បីពិនិត្យមើលអក្សរ ឬព័ត៌មាន ដែលបានចែករំលែក ដោយកំណត់នូវផលវិបាក និងបញ្ហាប្រឈមនានា ដែលពួកគាត់ជួបប្រទះទាក់ទងនឹងជំងឺរបេង ឬហានិភ័យដែលអាចបណ្តាលមកពីមានជំងឺរបេង។ ពួកគេក៏នឹងកំណត់ពីលទ្ធផល ឬផលប៉ះពាល់នៃបទពិសោធន៍ដ៏លំបាកទាំងនោះ ចំពោះបុគ្គលដែលធ្លាប់បានជួបប្រទះផងដែរ។ បញ្ហាប្រឈម និងលទ្ធផលនឹងត្រូវបានសរសេរនៅលើក្រដាសបិទតូច (Post-its) ឬក្រដាសពណ៌ ហើយនឹងត្រូវបានដាក់បិទនៅលើក្តារព័ត៌មាន។ ក្រដាសទាំងនោះ នឹងត្រូវបានប្រើជាឯកសារយោងសម្រាប់វគ្គបន្តបន្ទាប់។

d. លំហាត់សម្តែងតួរ (role-playing) នឹងអនុញ្ញាតឱ្យអ្នកចូលរួមមានការយល់ដឹងកាន់តែស៊ីជម្រៅអំពីបញ្ហាប្រឈមដែលពួកគេបានជួបប្រទះ។ វាក៏នឹងអាចផ្តល់ឱកាសឱ្យពួកគេស្វែងយល់ពីរបៀបដែលអាចផ្លាស់ប្តូរលទ្ធផល នៃបទពិសោធន៍ដ៏លំបាកដែលពួកគេបានកំណត់កាលពីវគ្គមុនផងដែរ។

e. បន្ទាប់ពីវគ្គសកម្មភាពជាបន្តបន្ទាប់មក នេះជាតម្រូវការសំខាន់ណាស់ដែលត្រូវមានការសំយោគ និងរំលឹកឡើងវិញនូវចំណុចសិក្សាសំខាន់ៗស្តីពីសិទ្ធិមនុស្សក្នុងបរិបទរបេង។ វគ្គនេះអាចប្រព្រឹត្តទៅបានតាមរយៈបទបង្ហាញស្លាយដែលមានព័ត៌មានមូលដ្ឋានអំពីសិទ្ធិមនុស្ស។ ហើយក៏មានវីដេអូជីវចលខ្លីៗមួយចំនួនស្តីពីព័ត៌មានសិទ្ធិមនុស្សថ្នាក់មូលដ្ឋាននៅលើអ៊ីនធឺណិត ដែលអាចចូលមើលបានហើយចាក់បង្ហាញសម្រាប់វគ្គនេះ។

f. បន្ទាប់ពីធ្វើការសំយោគរួចមក អ្នកចូលរួមនឹងត្រលប់ទៅក្រុមរបស់ពួកគេវិញ រួចពិនិត្យឡើងវិញនូវការសម្តែងតួរ (role-playing ) ដែលពួកគេបានសម្តែង និងកំណត់បញ្ហាពីការរំលោភបំពានសិទ្ធិមនុស្សដែលត្រូវបានបង្ហាញឡើង។ បន្ទាប់ពីអ្នកចូលរួមបានកំណត់ពីការរំលោភសិទ្ធិមនុស្ស ពួកគេនឹងត្រូវបានស្នើសុំឱ្យព្យាយាមកំណត់អត្តសញ្ញាណអ្នកទទួលខុសត្រូវ ឬទីភ្នាក់ងាររាជរដ្ឋាភិបាលនានា ដែលពួកគាត់គិតថា មានការទទួលខុសត្រូវ ឬសិទ្ធិអំណាច ដើម្បីដោះស្រាយបញ្ហាទាក់ទងនឹងការរំលោភបំពានសិទ្ធិមនុស្ស ដែលពួកគេបានកំណត់។ ពួកគេនឹងសរសេរអំពីអ្នកមានកាតព្វកិច្ច នៅលើក្រដាសបិទ (Post-its) និងបិទនៅកន្លែងណាមួយ។ បញ្ជីឈ្មោះអ្នកមានកាតព្វកិច្ចទាំងនេះ នឹងត្រូវប្រើប្រាស់ នៅក្នុងវគ្គក្រោយស្តីពីការស្វែងរកការគាំទ្រ ឬការតស៊ូមតិ។

ម៉ូឌុលស្តីពីសិទ្ធិមនុស្ស កំណត់ការយល់ដឹងអំពីគោលគំនិតសិទ្ធិមនុស្ស នៅក្នុងបរិបទអ្នកចូលរួមដែលធ្លាប់ជួបប្រទះកន្លងមក ក្នុងនាមអតីតអ្នកជំងឺ ឬសហគមន៍ដែលរងផលប៉ះពាល់ដោយជំងឺរបេង។ នៅក្នុង

ម៉ូឌុលពីរបន្ទាប់ទៀត អ្នកចូលរួមនឹងត្រូវអនុវត្តនូវអ្វីដែលពួកគេបានរៀនតាមរយៈ ១) ចងក្រងឯកសារស្តីពីការរំលោភសិទ្ធិមនុស្សក្នុងចំណោមសហគមន៍ជំងឺរបេង និង ២) ចូលរួមក្នុងសកម្មភាពស្វែងរកការគាំទ្រ ឬការតស៊ូមតិ។

5. **ការចងក្រងឯកសារនៃការរំលោភបំពានសិទ្ធិមនុស្សទាក់ទងនឹងជំងឺរបេង៖** ក្នុងម៉ូឌុលនេះ នឹងផ្តល់ឱ្យអ្នកចូលរួមនូវជំនាញក្នុងការសម្ភាសន៍សមាជិកនៅក្នុងសហគមន៍របស់ពួកគេ ដែលបានជួបប្រទះលើការរំលោភបំពានសិទ្ធិមនុស្ស ហើយនឹងចាប់យកបទពិសោធន៍ទាំងនោះ បញ្ចូលទៅក្នុងទម្រង់ឯកសារស្តីអំពីសិទ្ធិមនុស្ស។
6. **ការស្វែងរកការគាំទ្រ ឬការតស៊ូមតិ៖** ការចូលរួមក្នុងសកម្មភាពស្វែងរកការគាំទ្រ ឬការតស៊ូមតិ គឺជាជំនាញដ៏សំខាន់មួយចំពោះសហគមន៍ដែលរងផលប៉ះពាល់ដោយសារជំងឺរបេង ត្រូវតែយល់ដឹង ដើម្បីឱ្យពួកគេអាចចូលរួមក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្ត លើកបញ្ហា និងកង្វល់របស់ពួកគេទៅកាន់អ្នកមានកាតព្វកិច្ច និងអ្នកធ្វើសេចក្តីសម្រេច ព្រមទាំងការផ្លាស់ប្តូរផ្នែកច្បាប់ គោលនយោបាយ កម្មវិធី និងការផ្តល់សេវាផងដែរ។ ពួកគេនឹងប្រើប្រាស់លទ្ធផលពីម៉ូឌុលមុនៗ សម្រាប់វគ្គពង្រឹងជំនាញស្វែងរកការគាំទ្រ ឬតស៊ូមតិ។

សកម្មភាពវគ្គបណ្តុះបណ្តាលក្នុងរយៈពេលបីថ្ងៃនេះនឹងឈានដល់សិក្ខាសាលារៀបចំផែនការស្វែងរកការគាំទ្រ ឬតស៊ូមតិ ដែលគួរតែបន្តអនុវត្ត និងគាំទ្របន្ទាប់ពីវគ្គបណ្តុះបណ្តាល។ បន្ទាប់ពីអ្នកចូលរួម បានចែករំលែកពីផែនការស្វែងរកការគាំទ្រ ឬតស៊ូមតិរបស់ពួកគេ កម្រងសំណួរក្រោយវគ្គការនឹងត្រូវបានផ្តល់ឱ្យអ្នកចូលរួម។ ការវាយតម្លៃលើវគ្គបណ្តុះបណ្តាល ក៏នឹងត្រូវធ្វើឡើងដោយប្រើឧបករណ៍វាយតម្លៃ រួមបញ្ចូលនៅក្នុងសៀវភៅណែនាំនេះផងដែរ។

## ទិដ្ឋភាពទូទៅនៃវគ្គបណ្តុះបណ្តាល

| *ថ្ងៃ* | *ថ្ងៃទី១* | *ថ្ងៃទី២* | *ថ្ងៃទី៣* |
|---|---|---|---|
| ព្រឹក | ម៉ូឌុលទី១៖ សកម្មភាពបើកវគ្គបណ្តុះបណ្តាល<br>ម៉ូឌុលទី២៖ ស្ថានភាពជំងឺរបេង និងសិទ្ធិមនុស្ស<br>ម៉ូឌុលទី៣៖ មូលដ្ឋានចំណេះដឹងអំពីជំងឺរបេង | ម៉ូឌុលទី៤៖ ការស្វែងយល់អំពីបញ្ហាសិទ្ធិមនុស្សក្នុងបរិបទជំងឺរបេង (បន្ត) | ម៉ូឌុលទី៦៖ ការស្វែងរកការគាំទ្រ ឬការតស៊ូមតិ |
| រសៀល | ម៉ូឌុលទី៤៖ ការស្វែងយល់អំពីបញ្ហាសិទ្ធិមនុស្សក្នុងបរិបទជំងឺរបេង | ម៉ូឌុលទី៥៖ ការចងក្រងឯកសារនៃការរំលោភបំពានសិទ្ធិមនុស្សទាក់ទងនឹងជំងឺរបេង | ម៉ូឌុលទី៦៖ ការស្វែងរកការគាំទ្រ ឬការតស៊ូមតិ (បន្ត) |

## កន្លែងបណ្តុះបណ្តាល និង សម្ភារៈគាំទ្រផ្សេងៗ

វាមានសារៈសំខាន់ណាស់ក្នុងការពិចារណាពីទីកន្លែងសម្រាប់វគ្គសិក្ខាសាលាបណ្តុះបណ្តាលនេះ គួរតែជាកន្លែងមានអំណោយផលសម្រាប់ការរៀនសូត្រ និងទំហំសមល្មមស្របតាមសកម្មភាពនីមួយៗ ជាមួយនឹងការធានាបាននូវភាពងាយស្រួលរបស់អ្នកចូលរួម។ មានសកម្មភាពមួយចំនួនដែលតម្រូវឱ្យអ្នកចូលរួម មានចម្ងាយសមស្របពីគ្នាទៅវិញទៅមក។ ទោះបីវគ្គបណ្តុះបណ្តាលនេះមិនមានលក្ខណៈដូចនូវក្នុងថ្នាក់រៀន ដែលតម្រូវឱ្យអ្នកចូលរួមអង្គុយជាប្រចាំក៏ដោយ ទីកន្លែងក៏គួរមានតុសម្រាប់អង្គុយ ដែលតម្រូវទៅតាមប្រធានបទមួយចំនួន ដូច្នេះអ្នកត្រូវប្រាកដថាទីកន្លែងអាចបត់បែនតាមតម្រូវការរបស់វគ្គបណ្តុះបណ្តាលនេះ។

ខាងក្រោម ជាបញ្ជីសង្ខេបនៃឧបករណ៍ សម្ភារៈ និងការផ្គត់ផ្គង់ទាំងអស់ សម្រាប់វគ្គបណ្តុះបណ្តាល៖

1. កុំព្យូទ័រ
2. ម៉ាស៊ីនបញ្ចាំង LCD ( LCD projector )
3. ក្រដាសផ្ទាំងស ( Flip chart papers )
4. ក្រដាសបិទតូច ឬ ក្រដាសពណ៌ ( Post-its or colored papers )
5. ហ្វឺត ( Markers )
6.ស្កត់បិទ ( Masking tapes )
7. ក្រដាសសរសេរ ( Writing pad )
8. ប៊ិច ( Ballpens )

ឯកសារខាងក្រោមនេះ តម្រូវការប្រើប្រាស់ចាំបាច់ និងព្រីនចេញ នៅមុនពេលវគ្គបណ្តុះបណ្តាលកើតឡើង៖

1. កម្រងសំណួរមុនវគ្គ និងក្រោយវគ្គ
2. របៀបវារៈនៃវគ្គបណ្តុះបណ្តាល
3. ឧបករណ៍គម្រូសម្រាប់ការចងក្រងឯកសារ
4. ទម្រង់វាយតម្លៃវគ្គបណ្តុះបណ្តាល
5. ទម្រង់ផែនការស្វែងរកការគាំទ្រ ឬតស៊ូមតិ

## ជំពូក ២ : ម៉ូឌុលបណ្តុះបណ្តាល

### ក. សកម្មភាពបើកវគ្គបណ្តុះបណ្តាល

**គោលបំណង៖** ដើម្បីចាប់ផ្តើមបើកវគ្គសិក្ខាសាលាបណ្តុះបណ្តាលជាផ្លូវការ ធ្វើការណែនាំសិក្ខាកាម ដែលបានចូលរួមឱ្យស្គាល់គ្នាទៅវិញទៅមក និងចែករំលែកការរំពឹងទុករបស់ពួកគេ ចំពោះវគ្គសិក្ខាសាលាបណ្តុះបណ្តាលនេះ និងបញ្ជាក់ពីគោលបំណងនៃការបណ្តុះបណ្តាល។

រយៈពេល: ៦០នាទី

## សកម្មភាពៈ

1. សេចក្តីផ្តើម
2. ការកំណត់សេចក្តីរំពឹងទុក
3. ស្លាយបទបង្ហាញ
4. កិច្ចព្រមព្រៀងរួមគ្នា (បទបញ្ជាផ្ទៃក្នុង)
5. ការធ្វើតេស្តមុនវគ្គ

## សម្ភារៈៈ

1. ក្រដាសផ្ទាំង
2. ហ្វឺត
3. ក្រដាសបិទតូច (Post-Its) ឬក្រដាសពណ៌ត្រូវបានកាត់ជាទំហំរបស់ Post-Its
4. កម្រងសំណួរតេស្តមុនវគ្គ

## រៀបចំការធ្វើតេស្តមុន (២០ នាទី)

ជាមធ្យោបាយដ៏សាមញ្ញក្នុងការវាស់ស្ទង់ការរៀនសូត្ររបស់អ្នកចូលរួម កម្រងសំណួរតេស្តមុនវគ្គ (ឧបសម្ព័ន្ធ ១) គួរតែធ្វើឡើងនៅថ្ងៃដំបូង។ វាជាការល្អបំផុតក្នុងការចែកចាយកម្រងសំណួរ នៅពេលអ្នកចូលរួមចូលក្នុងបន្ទប់ ដូច្នេះពួកគេ អាចធ្វើការសម្រេចបានមុនពេលវគ្គបណ្តុះបណ្តាលចាប់ផ្តើម។

1. ជូនដំណឹងដល់សិក្ខាកាមថា ពួកគេនឹងតម្រូវឱ្យធ្វើតេស្តមុនវគ្គ និងតេស្តក្រោយវគ្គបណ្តុះបណ្តាល ដើម្បីពិនិត្យមើលថា តើពួកគេបានរៀនអ្វីខ្លះពីវគ្គបណ្តុះបណ្តាលនេះ។ អ្នកបណ្តុះបណ្តាលត្រូវពន្យល់ថា លទ្ធផលនៃការធ្វើតេស្តនឹងមិនមានផលវិបាកទៅលើពួកគាត់ទេ។ ពន្យល់អ្នកចូលរួមថា នឹងមិនមានបញ្ហាអ្វីទេ ប្រសិនបើពួកគេមិនច្បាស់ពីចម្លើយដែលពួកបានឆ្លើយ។
2. ចែកកម្រងសំណួរ។
3. ផ្តល់រយៈពេល ១០ នាទីដល់អ្នកចូលរួមក្នុងការឆ្លើយសំណួរ។
4. បន្ទាប់ពី ១០ នាទីក្រោយមក ប្រមូលកម្រងសំណួរ។
5. ទុកកម្រងសំណួរដោយឡែក ហើយពិនិត្យមើលវានៅពេលក្រោយ។

## ការណែនាំខ្លួនរបស់អ្នកចូលរួម (១៥ នាទី)

ធម្មតាការចាប់ផ្តើមវគ្គសិក្ខាសាលាបណ្តុះបណ្តាល ត្រូវចាប់ផ្តើមជាមួយកម្មវិធីបើក ដើម្បីស្វាគមន៍អ្នកចូលរួម ហើយណែនាំពីពួកគេពីអ្វីដែលត្រូវរំពឹងទុកពីវគ្គបណ្តុះបណ្តាលនេះ។ នេះ គឺជាពេលមួយដែលត្រូវកំណត់ថា ហេតុអ្វីបានជាពួកគេ(អ្នកចូលរួម) មកចូលក្នុងវគ្គបណ្តុះបណ្តាលនេះ។ អ្នកអាចចាប់ផ្តើមជាមួយនឹងសុន្ទរកថាស្វាគមន៍ជាផ្លូវការ ដែលជាធម្មតាត្រូវបានធ្វើឡើងដោយអ្នករៀបចំ។ ល្អបំផុតត្រូវចំណាយពេលមិនលើសពី ៥នាទីទេសម្រាប់វគ្គនេះ។

1. ចែកអ្នកចូលរួមជាពីរក្រុម។
2. ប្រាប់ក្រុមទីមួយឱ្យបង្កើតជារង្វង់ ហើយបែរមុខចេញទៅខាងក្រៅ។
3. ប្រាប់ក្រុមទី ២ ឱ្យបង្កើតរង្វង់មួយទៀតនៅជុំវិញក្រុមទីមួយដោយបែរមុខចូលក្នុង។ អ្នកគួរតែមានរង្វង់មួយដែលអ្នកចូលរួមទាំងពីរក្រុមនេះ បែរមុខដាក់គ្នា ហើយអ្នកចូលរួមម្នាក់ៗគួរមានដៃគូរបស់ខ្លួន។
4. ផ្តល់ការណែនាំដូចខាងក្រោម៖
    a. អ្នកទាំងអស់ដែលនៅក្នុងរង្វង់ខាងក្នុង នឹងណែនាំខ្លួនទៅដៃគូរបស់ខ្លួនជាមុនសិន។
    b. ណែនាំឈ្មោះរបស់អ្នក កន្លែងដែលអ្នករស់នៅ(ភូមិ ឬទីក្រុង) ហើយដាក់ឈ្មោះរបស់អ្វីមួយដែលធ្វើឱ្យអ្នកមានភាពរីករាយ។
    c. បន្ទាប់មកអ្នកដែលនៅរង្វង់ខាងក្រៅ ក៏នឹងណែនាំខ្លួនពួកគេត្រឡប់ទៅដៃគូវិញផងដែរ។ គូនីមួយៗគួរតែបញ្ចប់ការណែនាំខ្លួនរបស់ពួកគាត់ក្នុងរយៈពេលតិចជាងមួយនាទី។
    d. បន្ទាប់ពីគូនីមួយៗបានណែនាំគ្នាទៅវិញទៅមកហើយ អ្នកដែលនៅរង្វង់ផ្នែកខាងក្រៅធ្វើការផ្លាស់ទីមួយជំហានទៅស្តាំ ដើម្បីឱ្យពួកគេនៅទល់មុខនឹងមនុស្សម្នាក់ទៀតដែលស្ថិតនៅរង្វង់ខាងក្នុង។
    e. បន្តសកម្មភាពបែបនេះរហូតដល់ពួកគាត់ត្រលប់ទៅដៃគូដើមរបស់ពួកគាត់វិញ។
    f. អញ្ជើញឱ្យអ្នកចូលរួមអង្គុយចុះ។ សួរជុំវិញអំពីអ្វីមួយដែលអ្នកចូលរួមបានលើកឡើងដែលផ្តល់ឱ្យពួកគេនូវភាពរីករាយ។
5. ក្នុងនាមជាអ្នកសម្របសម្រួលវគ្គបណ្តុះបណ្តាល អ្នកក៏គួរតែចូលរួមសកម្មភាពនេះផងដែរ ដើម្បីអាចណែនាំខ្លួនរបស់អ្នកទៅកាន់អ្នកចូលរួម និងក៏ដូចជាស្គាល់ពួកគេផងដែរ។

**ការរំពឹងទុក និងការកំណត់គោលបំណង (១៥ នាទី)**

1. ចែកក្រដាសបិទតូច(Post-It) និងហ្វឺតដល់អ្នកចូលរួម។
2. ប្រាប់អ្នកចូលរួមឱ្យសរសេរការរំពឹងទុកមួយ ក្នុងវគ្គបណ្តុះបណ្តាលនេះនៅលើក្រដាសបិទ (Post-Its) ហើយបិទលើក្តារនៅមុខបន្ទប់។
3. ខណៈពេលដែលអ្នកចូលរួមកំពុងបិទក្រដាស(Post-Its) របស់ពួកគេនៅលើក្តារ អ្នកសម្របសម្រួលអាចប្រមូលផ្តុំបែងចែកការរំពឹងទុករបស់ពួកគេទៅតាមក្រុម ដែលមាននៅក្នុងមាតិកា វិធីសាស្ត្រ អ្នកសម្របសម្រួល អ្នកចូលរួមជាមួយគ្នា និងតាមផ្នែកផ្សេងៗទៀត។
4. នៅពេលអ្នកចូលរួមទាំងអស់បានដាក់បិទក្រដាស់ Post-Its របស់ពួកគេនៅលើក្តារខៀន ធ្វើការសង្ខេបអំពីការរំពឹងទុក និងបញ្ជាក់បន្ថែម ប្រសិនបើមានចំណុចណាមិនច្បាស់លាស់។

5. បន្តការចែករំលែកគោលបំណងនៃវគ្គបណ្តុះបណ្តាលនេះ ធ្វើដូច្នេះ អ្នកអាចបញ្ជាក់បានភ្លាមៗ នូវអ្វីៗដែលវគ្គបណ្តុះបណ្តាលនឹងគ្របដណ្តប់ និងអ្វីៗដែលនឹងមិនធ្វើ។
6. ចែករំលែកទិដ្ឋភាពទូទៅនៃកម្មវិធីនេះ នៅក្នុងបីថ្ងៃបន្ទាប់។

**វិន័យក្នុងកិច្ចប្រជុំ** (10 minutes)

ការកំណត់វិន័យក្នុងវគ្គបណ្តុះបណ្តាល គឺមានសារៈសំខាន់ណាស់ ដើម្បីជួយធានាបរិយាកាសក្នុងការសិក្សាប្រកបដោយអំណោយផល សម្រាប់អ្នកចូលរួម។ សួរទៅកាន់អ្នកចូលរួមនូវអ្វីដែលពួកគេគិតថា គួរតែត្រូវបានបញ្ចូលនៅក្នុងវិន័យក្នុងវគ្គបណ្តុះបណ្តាល ដែលនឹងត្រូវអនុវត្តតាមដោយអ្នកចូលរួមទាំងអស់។ វិន័យទូទៅ សម្រាប់អនុវត្តក្នុងវគ្គបណ្តុះបណ្តាល រួមបញ្ចូលដូចខាងក្រោម៖

1. ត្រូវឱ្យទាន់ពេលវេលា
2. ត្រូវបិទសម្លេងទូរស័ព្ទដៃ ហើយចៀសវាងការប្រើប្រាស់ទូរស័ព្ទក្នុងពេលប្រជុំ លុះត្រាតែមានការអាសន្ន
3. ត្រូវចេះគោរពអ្នកដទៃ
4. រក្សាការសម្ងាត់នូវរឿងផ្ទាល់ខ្លួន ដែលត្រូវបានចែករំលែកដោយអ្នកចូលរួម
5. ត្រូវចូលរួមយ៉ាងសកម្មក្នុងវគ្គបណ្តុះបណ្តាល

អ្នកសម្របសម្រួលវគ្គ ឬអ្នកចូលរួមអាចបន្ថែមចំណុចមួយចំនួនទៅក្នុងបញ្ជីតាមតម្រូវការជាក់ស្តែង។ ហើយត្រូវបានណែនាំផងដែរ ថាវិន័យទាំងនេះ ត្រូវតែសរសេរនៅលើក្រដាសផ្ទាំងស ហើយបិទនៅផ្នែកម្ខាងនៃបន្ទប់ សម្រាប់រយៈពេលទាំងមូល នៃវគ្គបណ្តុះបណ្តាល ដើម្បីរំលឹកដល់អ្នកចូលរួម។ ក្នុងនាមជាអ្នកព្រមព្រៀងចំពោះវិន័យទាំងនេះ សូមអញ្ជើញអ្នកចូលរួមឱ្យចុះហត្ថលេខាលើក្រដាសផ្ទាំងស នៅជុំវិញតារាងវិន័យដែលបានសរសេរឡើង។

## ខ. ស្ថានភាពជំងឺរបេង និងសិទ្ធិមនុស្ស

**គោលបំណង៖** ផ្តល់នូវទិដ្ឋភាពទូទៅនៃស្ថានភាពជំងឺរបេងនាពេលបច្ចុប្បន្ន នៅក្នុងប្រទេសឬតំបន់ ដែលជាបរិបទសម្រាប់ការបណ្តុះបណ្តាល។

ពេលវេលា៖ ៤៥ នាទី

សម្ភារៈ៖

1. កុំព្យូទ័រ
2. ម៉ាស៊ីនបញ្ចាំង LCD

ដើម្បីកំណត់បរិបទ និងពន្យល់ពីតម្រូវការចាំបាច់នៃវគ្គបណ្តុះបណ្តាលនេះ ប្រធានបទនៃការកំណត់បរិបទជំងឺរបេងគួរតែត្រូវបានធ្វើឡើង។ សកម្មភាពនេះ អាចជាការបង្ហាញយ៉ាងសាមញ្ញអំពីស្ថានភាពជំងឺរបេងនាពេលបច្ចុប្បន្ន នៅក្នុងប្រទេស និង/ឬ នៅក្នុងតំបន់របស់អ្នក ទៅតាមតម្រូវការជាក់ស្តែង។ ប្រសិនអាច វាជាការសំខាន់ដែលត្រូវបញ្ចូលព័ត៌មានទាក់ទងនឹងសិទ្ធិមនុស្ស នៅក្នុងបទបង្ហាញរបស់អ្នកអំពីស្ថានភាពជំងឺរបេង។ បទបង្ហាញ (Powerpoint) អាចប្រើប្រាស់បាន ដើម្បីណែនាំអំពីប្រធានបទនេះ។ ព័ត៌មានសំខាន់ៗ ដែលមាននៅក្នុងបទបង្ហាញមានដូចខាងក្រោម៖

1. អត្រាអាំងស៊ីដង់ និងប្រេវ៉ាឡង់អំពីជំងឺរបេង
2. សហគមន៍ដែលរងផលប៉ះពាល់ដោយសារជំងឺរបេងច្រើនជាងគេ
3. មូលហេតុនៃការរីករាលដាលជំងឺរបេង នៅក្នុងប្រទេស ឬតំបន់
4. អន្តរាគមន៍ដែលកំពុងត្រូវបានអនុវត្តដោយរាជរដ្ឋាភិបាល និងភាគីពាក់ព័ន្ធ ដើម្បីដោះស្រាយបញ្ហារបេង
5. បញ្ហាប្រឈម និងភាពខ្វះចន្លោះ នៅក្នុងអន្តរាគមន៍ជំងឺរបេងដែលមានស្រាប់

ស្លាយធ្វើការបង្ហាញអំពីមូលហេតុនៃការរីករាលដាល នៃជំងឺរបេងនៅក្នុងប្រទេស ក៏ដូចជាភាពចន្លោះប្រហោងនៃការឆ្លើយតបទៅនឹងជំងឺរបេង ហើយអាចបើកការពិភាក្សាអំពីបញ្ហាសិទ្ធិមនុស្សដែលសហគមន៍រងផលប៉ះពាល់ដោយជំងឺរបេងត្រូវបានជួបប្រទះ និងបង្ហាញពីវិសាលភាពដែលរាជរដ្ឋាភិបាលបានបរាជ័យក្នុងការលើកកម្ពស់ ការពារ និងបំពេញសិទ្ធិរបស់ប្រជាពលរដ្ឋដែលនាំឱ្យមានការកើនឡើងនៃចំនួនប្រជាពលរដ្ឋមានជំងឺរបេង។

## គ. មូលដ្ឋានចំណេះដឹងអំពីជំងឺរបេង

គោលបំណង៖ ដើម្បីផ្តល់ឱ្យអ្នកចូលរួមនូវមូលដ្ឋានព័ត៌មាន អំពីជំងឺរបេងថាជាឆ្លង ឬជំងឺ។

ពេលវេលា៖ ១ ម៉ោង

សកម្មភាព៖

1. សកម្មភាពក្រុម៖ រង្វិលជុំជាកង់រទេះ
2. ការពិភាក្សារួម (ពេញអង្គ)

3. ស្លាយបង្ហាញ (ជាជម្រើស)

សម្ភារៈ៖

1. ហ្វឺត
2. ក្រដាសផ្ទាំង
3. ស្កុតបិទ
4. កុំព្យូទ័រ និងម៉ាស៊ីនបញ្ចាំងស្លាយ LCD សម្រាប់ធ្វើបទបង្ហាញ PowerPoint (ជាជម្រើស)

## អ្វីៗដែលត្រូវធ្វើមុនវគ្គបណ្តុះបណ្តាល

មុនពេលរៀបចំវគ្គបណ្តុះបណ្តាលជាក់ស្តែង អ្នកត្រូវរៀបចំរង្វង់មូលជាកង់រទេះរបស់អ្នក។ សកម្មភាពនេះត្រូវបានគេហៅថារង្វង់កង់រទេះ (carousel) ពីព្រោះដំណើរការនេះមើលទៅពិតជាដូច រទេះជិះសេះកម្សាន្តដែលមានចលនាវិលជុំ (ឬរទេះរង្វិលជុំ នៅក្នុងបរិបទខ្លះ) អ្នកនឹងស្នើសុំឱ្យអ្នកចូលរួមផ្លាស់ប្តូរពីស្ថានីយ៍ (កន្លែង) មួយទៅមួយទៀត នៅក្នុងរង្វង់ជុំវិញបន្ទប់។ ការរៀបរង្វង់មូលនេះនឹងមានស្ថានីយ៍ចំនួនប្រាំពីរ (៧) ដែលត្រូវបានរៀបចំជារង្វង់មូលជុំវិញនៅក្នុងបន្ទប់បណ្តុះបណ្តាល។ ស្ថានីយ៍នីមួយៗនឹងមានសំនួរមួយដែលអ្នកចូលរួមនឹងត្រូវឆ្លើយក្នុង ពេលធ្វើសកម្មភាពនេះ។

ជំហានរៀបចំ៖

1. រៀបចំក្រដាសផ្ទាំងសចំនួន ៧ផ្ទាំង។ ក្រដាស់ទាំងនេះ នឹងជាស្ថានីយ៍នៅក្នុងរង្វង់របស់អ្នក។
2. រៀបចំសំណួរដែលអ្នកនឹងត្រូវដាក់នៅលើស្ថានីយ៍នីមួយៗ។ សរសេរ ឬព្រីនចេញនូវសំណួរទាំងនោះឱ្យបានត្រឹមត្រូវ ដោយមានសំណួរមួយនៅក្នុងក្រដាសមួយសន្លឹក។ ត្រូវសរសេរអក្សរជំល្មម ដើម្បីបំពេញក្រដាស់ទាំងមូល។ ទាំងនេះ គឺជាសំណួរ
    a. ជំងឺរបេង គឺជាអ្វី?
    b. តើជំងឺរបេងឆ្លងយ៉ាងដូចម្តេច?
    c. តើរោគសញ្ញានៃជំងឺរបេងមានអ្វីខ្លះ?
    d. តើអ្នកនរណាខ្លះ ងាយរងគ្រោះខ្លាំងជាងគេដោយសារជំងឺរបេង?
    e. តើខ្ញុំដឹងថាមានជំងឺរបេងដោយរបៀបណា?
    f. តើខ្ញុំព្យាបាលជំងឺរបេងយ៉ាងដូចម្តេច?
    g. តើខ្ញុំអាចការពារខ្លួន ពីជំងឺរបេងតាមរបៀបណាខ្លះ?

*បញ្ចូលគំនូរឧទាហរណ៍នៃស្ថានីយ៍កង់រទេះ

3. វាជាការប្រសើរ ប្រសិនបើ មានការរៀបចំរង្វង់មូលមុនពេលអ្នកចូលរួម ចូលក្នុងបន្ទប់បណ្តុះបណ្តាល។ នេះនឹងចំណាយពេលប្រហែល ១០នាទី ដើម្បីរៀបចំ។
4. យកក្រដាសផ្ទាំងសទៅបិទនៅលើជញ្ជាំងជុំវិញបន្ទប់បណ្តុះបណ្តាល។ ត្រូវប្រាកដថាពីការបែងចែកក្រដាស់ទាំងនោញ ដូច្នេះវាអាចត្រូវបានរៀបចំនៅចម្ងាយប្រហាក់ប្រហែលពីគ្នា ហើយបង្កើតជារង្វង់ជុំវិញបន្ទប់។
5. យកសំណួរនីមួយៗ ដាក់បិទនៅពីលើក្រដាសផ្ទាំងនោះ - សំណួរមួយក្នុង ស្ថានីយ៍មួយ- តាមលំដាប់លំដោយនៃសំណួរខាងលើដោយប្រព្រឹត្តទៅតាមទ្រនិចនាឡិកា។ រាប់ស្ថានីយ៍ក្រដាស់ផ្ទាំងសពីលេខ១ ដល់លេខ៧ ។
6. បន្ទាប់ពីដាក់សំនួរនៅតាមស្ថានីយ៍នីមួយៗ សូមគ្របដណ្តប់ជាមួយនឹងក្រដាសសទទេសិន។

## សេចក្តីណែនាំសម្រាប់អនុវត្តសកម្មភាព

1. ចាប់ផ្តើមសកម្មភាពដោយបែងចែកអ្នកចូលរួមចម្រុះគ្នាជា ៧ក្រុម។ ប្រាប់ទៅអ្នកចូលរួមដែលមានលេខដូចគ្នាឱ្យចូលរួមក្នុងក្រុមតែមួយជាមួយគ្នា។
2. ប្រាប់ទៅក្រុមនីមួយៗឱ្យឈរនៅមុខស្ថានីយ៍តាមលំដាប់លំដោយ។ ក្រុមទី១ នឹងឈរនៅមុខប្រកាសជាមួយនឹងសំណួរទីមួយ។ ក្រុមទី២ ឈរនៅមុខសំនួរទី២ ហើយបន្តបន្ទាប់រហូតដល់ក្រុមទាំងអស់ត្រូវបានឈរទៅតាមស្ថានីយ៍របស់ពួកគេ។
3. ផ្តល់ហ្វឹតទៅដល់ក្រុមនីមួយៗ។ ត្រូវរំលឹកដល់អ្នកចូលរួម កុំឱ្យប៉ះពាល់សំណួរដែលគ្របដណ្តប់ក្រដាសពីលើរហូត ដល់ទាល់តែការណែនាំសម្រាប់សកម្មភាពនោះ។
    a. នៅពេលទទួលបានសញ្ញា ថាក្រុមនីមួយៗអាចបើកមើលសំណួរបាន នោះក្រុមអាចបើកសំណួរអានឱ្យសមាជិកក្រុមស្តាប។ បន្ទាប់មក ពួកគេនឹងត្រូវសម្រេចយល់ព្រមលើចម្លើយតែមួយគត់ ហើយសរសេរចម្លើយនោះ នៅលើក្រដាសផ្ទាំងធំ។ ក្រុមនីមួយៗត្រូវបានអនុញ្ញាតឱ្យសរសេរចម្លើយតែមួយទេ។ ផ្តល់ពេលដល់អ្នកចូលរួមប្រមាណជាមួយនាទី សម្រាប់អនុវត្តសកម្មភាពនេះ។
    b. បន្ទាប់ពីមួយនាទី និយាយថា "ផ្លាស់ទី!"។ នៅចំណុចនេះ ក្រុមនីមួយៗនឹងផ្លាស់ទីទៅស្ថានីយបន្ទាប់នៅខាងស្តាំដៃរបស់ពួកគេ។ នៅស្ថានីយ៍បន្ទាប់ពួកគេនឹងធ្វើជំហានខាងលើម្តងទៀត។
    c. ធ្វើសកម្មភាពដូចគ្នានេះ រហូតដល់ក្រុមទាំងអស់មានឱកាសសរសេរចម្លើយរបស់ពួកគេ នៅគ្រប់ស្ថានីយ៍ទាំងអស់។
    d. ត្រូវប្រាកដថា ក្រុមទាំងអស់មិនមានចម្លើយដូចដែលក្រុមផ្សេងទៀតបានសរសេរទុកមុននោះទេ។ ធ្វើដូច្នេះ នឹងលើកទឹកចិត្តក្រុមទាំងអស់គិតអំពីចម្លើយផ្សេងៗគ្នា។ ប្រសិនបើ មិនអាចគិតពីចម្លើយផ្សេងទៀតទេ ពួកគេអាចទុកចន្លោះមួយនៅក្បែរលេខ ដែលត្រូវនឹងកន្លែងចម្លើយរបស់ពួកគេ។
    e. នៅពេលក្រុមនីមួយៗ បានវិលជុំវិញរង្វង់រួចអស់ហើយ អញ្ជើញឱ្យពួកគេត្រលប់ទៅកន្លែងអង្គុយវិញ។ ស្ថានីយ៍នីមួយៗនឹងត្រូវមាន ៧ចំណុច (រាប់បញ្ចូលទាំងក្រុមដែលមិនបានផ្តល់ចម្លើយ និងក្រុមដែលមិនមានចម្លើយហើយមានតែចន្លោះ)។

4. ពិនិត្យមើលចម្លើយតាមស្ថានីយ៍នីមួយៗ។ ចាប់ផ្តើមពីស្ថានីយ៍ដែលមានសំនួរទី ១ ហើយបន្តទៅស្ថានីយ៍ទាំងអស់តាមលំដាប់លំដោយ។
5. បញ្ជាក់ចម្លើយត្រឹមត្រូវ និងឆ្លើយតបទៅនឹងចម្លើយមិនត្រឹមត្រូវ។ លើកទឹកចិត្តឱ្យអ្នកចូលរួមសួរសំណួរប្រសិនបើមាន។
6. ប្រើស្លាយបង្ហាញ ប្រសិនបើចាំបាច់ ដើម្បីផ្តល់ព័ត៌មានមូលដ្ឋានអំពីជំងឺរបេង ប៉ុន្តែត្រូវប្រាកដថា ស្លាយបង្ហាញទាំងនោះ នឹងធ្វើតាមលំដាប់នៃសំណួរនៅលើវង្វង់។ ប្រសិនបើគ្មានបទស្លាយបង្ហាញទេ សូមរៀបចំឯកសារសម្រាប់អ្នកចូលរួមនៅមុនវគ្គ និងចែកជូនពួកគេ បន្ទាប់ពីកិច្ចពិភាក្សានេះ។ អ្នកសម្របសម្រួល អាចប្រើព័ត៌មាននៅក្នុងផ្នែកបន្ទាប់ ដែលមានចំណងជើងថា *"ព័ត៌មានអប្បបរស្តង់ដារសម្រាប់ផ្តល់ជាតុចូល និងពិភាក្សា"* ។
7. អញ្ជើញឱ្យអ្នកចូលរួមសួរសំណួរ ឬផ្តល់មតិយោបល់។

## ព័ត៌មានអប្បបរស្ដង់ដារសម្រាប់ផ្ដល់ជាតុចូល និងពិភាក្សា ចំពោះមូលដ្ឋានចំណេះដឹងអំពីជំងឺរបេង (សម្រាប់ជាឯកសារចែកដល់អ្នកចូលរួម ឬស្លាយបង្ហាញ)

### តើអ្វី ជាជំងឺរបេង(TB)?

ជំងឺរបេង គឺជាជំងឺឆ្លង ដែលបង្កឡើងដោយបាក់តេរីមួយឈ្មោះថា "មីកូបាក់តេរីយ៉ូមទុយប៊ែរគុយឡូសីស" (Mycobacterium Tuberculosis) ។ ជំងឺរបេងសួតកើតឡើងនៅពេលដែលសួតឆ្លងមេរោគដោយបាក់តេរីនេះ។ នៅពេលដែលជំងឺរបេងប៉ះពាល់ដល់សរីរាង្គផ្សេងទៀត ឬផ្នែកខ្លះនៃរាងកាយដូចជា ឆ្អឹង សន្លាក់តម្រងនោម ខួរក្បាល ឬប្រដាប់បន្ដពូជ វាត្រូវបានគេហៅថា ជំងឺរបេងដែលកើតឡើងនៅក្នុងប្រព័ន្ធសរីរាង្គផ្សេងៗក្រៅពីសួត(extra-pulmonary TB)។

### ជំងឺរបេងមានទម្រង់ផ្សេងៗគ្នាៈ

1. ការឆ្លងមេរោគរបេងគ្មានរោគសញ្ញា - Latent TB infection (LTBI) – មនុស្សម្នាក់អាចមានបាក់តេរីរបេងនៅក្នុងខ្លួនប៉ុន្តែវាអសកម្ម។ នេះមានន័យថាគ្មានរោគសញ្ញាទេ។ លទ្ធផលនៃការថតកាំរស្មីអ៊ិចក៏អាចបញ្ជាក់ថា អវិជ្ជមាន។
2. របេងងាយទទួលថ្នាំ - Drug susceptible TB (DS TB) – សំដៅទៅលើទម្រង់នៃជំងឺរបេងដែលបាក់តេរីងាយនឹងជាក្រោយការប្រើថ្នាំ ដូច្នេះបើប្រើបានត្រឹមត្រូវនឹងបានជាសះស្បើយពីជំងឺរបេង។
3. ជំងឺរបេងដែលធន់នឹងឱសថ - Drug resistant TB (DR TB) - សំដៅទៅលើទម្រង់នៃជំងឺរបេងដែលបាក់តេរីមានភាពធន់នឹងថ្នាំរបេងយ៉ាងតិចមួយ។ ថ្នាំរបេងសំខាន់គឺ អីសូនីញ៉ាសីត (isoniazid), រីហ្វំពីស៊ីន (rifampicin), អេតំប៊ុយតុល (ethambutol) និង ពីរ៉ាហ្សីណាមីត (pyrazinamide) ។ ហើយក៏មានឱសថថ្មីៗដែលអាចរកបានច្រើនដែរប៉ុន្តែតម្លៃអាចថ្លៃជាង និងប្រហែលជាអាចមិនទាន់ចុះបញ្ជីនៅឡើយទេនៅក្នុងទម្រង់ថ្នាំរបស់ប្រទេស។
4. របេងស៊ាំថ្នាំច្រើនប្រភេទ - Multi-drug resistant TB (MDR TB) – នេះគឺជាទំរង់ជំងឺរបេងដែលបាក់តេរីមានភាពធន់ទ្រាំទៅនឹងឱសថ យ៉ាងតិចថ្នាំអីសូនីញ៉ាសីត (isoniazid) និង រីហ្វំពីស៊ីន (rifampicin) ជាថ្នាំជំងឺរបេងពីរដែលមានប្រសិទ្ធភាពបំផុត។ ការព្យាបាលជំងឺរបេងនេះនឹងមិនឆ្លើយតបទៅនឹងរបបនៃការព្យាបាលស្តង់ដារដែលមានរយៈពេល ៦ ខែទេ។
5. របេងដែលស៊ាំនឹងថ្នាំយ៉ាងទូលំទូលាយ - Extensively drug resistant TB (XDR TB) – ទម្រង់នៃជំងឺរបេងនេះគឺជាកន្លែងដែលបាក់តេរីមានភាពធន់ទ្រាំទៅនឹងថ្នាំ យ៉ាងតិចថ្នាំអីសូនីញ៉ាសីត (isoniazid) និង រីហ្វំពីស៊ីន (rifampicin) ។ បន្ថែមពីលើនោះយ៉ាងហោចណាស់ លុយរ៉ូគីណូឡូន (fluoroquinolones) មួយ និងយ៉ាងហោចណាស់មួយក្នុងចំណោមថ្នាំទី ២ ដែលចាក់ថ្នាំរបេងដូចជា អាមីកាស៊ីន(amikacin) កានាមីស៊ីន

(kanamycin) ឬ កាព្រីយ៉ូមស៊ីន(capreomycin)។ ការព្យាបាលជំងឺរបេងប្រភេទនេះមិនឆ្លើយតបទៅនឹងរបបព្យាបាលរយៈពេល ៦ ខែតាមស្តង់ដារធម្មតាទេ។

6. របេងដែលស៊ាំនឹងថ្នាំទាំងស្រុង - Totally drug resistant TB (TDR) – ទម្រង់របេងដែលបាក់តេរីមានភាពធន់នឹងថ្នាំជួរទី ១ និងទី ២ និងហ្លួយរ៉ូគីណូឡូន (fluoroquinolones)។

## តើជំងឺរបេងឆ្លងដោយរបៀបណា?

ជំងឺរបេងឆ្លងតាមរយៈខ្យល់។ មនុស្សម្នាក់អាចឆ្លងជំងឺរបេងសួត នៅពេលមនុស្សម្នាក់ស្រូបចូលដំណក់ទឹករំអិលដែលផ្ទុកបាក់តេរី។ ទឹករំអិលដែលឆ្លងជំងឺរបេង អាចត្រូវបានបណ្តេញចេញទៅក្នុងខ្យល់នៅពេលមនុស្សម្នាក់មានជំងឺរបេងហើយក្អក កណ្តាស់ ឬខ្ជាត។ បាក់តេរីនេះអាចតាំងទីលំនៅក្នុងសួតហើយអាចបណ្តាលឱ្យមានជំងឺរបេងសួត។ វាក៏អាចត្រូវបានដឹកតាមរយៈចរន្តឈាមទៅកាន់សរីរាង្គដទៃទៀតនៃរាងកាយហើយអាចបណ្តាលឱ្យមានជំងឺរបេងសួតបន្ថែម។

មនុស្សម្នាក់ដែលបានស្រូបយកជាតិរំអិលឆ្លងមេរោគរបេង មិនវិវត្តទៅជាការឆ្លងមេរោគរបេងសកម្មទេ។ បាក់តេរីអាចស្ថិតនៅក្នុងខ្លួនរងចាំប្រព័ន្ធភាពស៊ាំរបស់មនុស្សចុះខ្សោយដូច្នេះវាអាចក្លាយសកម្ម ឬវិវត្តទៅជាជំងឺរបេង។ ខាងក្រោមនេះគឺជាការយល់ច្រឡំជាទូទៅអំពីជំងឺរបេងដែលអ្នកត្រូវកែៈ

1. ជំងឺរបេងគឺជាតំណពូជ។
2. ជំងឺរបេងអាចឆ្លងតាមរយៈប្រដាប់ប្រដារសំលៀកបំពាក់ឬកួយ។
៣. ជំងឺរបេងអាចឆ្លងតាមរយៈការចាប់ដៃ ឬអោបអ្នកដែលមានជំងឺរបេង។

## តើជំងឺរបេងក្នុងសួតមានរោគសញ្ញាអ្វីខ្លះ?

1. ក្អកសកម្ម និងជាប់រយៈពេលជាងពីរសប្តាហ៍
2. ឈាមនៅក្នុងស្លេស
3. ឈឺទ្រូង
4. គ្រុនក្តៅ
5. បាត់បង់ចំណង់អាហារ
6. ស្រកទម្ងន់
7. ពិបាកដកដង្ហើម

## តើនរណាខ្លះ ដែលងាយរងគ្រោះនឹងជំងឺរបេង?

មនុស្សគ្រប់គ្នាងាយនឹងឆ្លងជំងឺរបេង ពីព្រោះមនុស្សគ្រប់គ្នាដកដង្ហើមតាមខ្យល់។ ទោះយ៉ាងណាមានសហគមន៍មនុស្សដែលមានហានិភ័យក្នុងការឆ្លងជំងឺរបេងជាងគេ ឬប្រជាជនសំខាន់ចំពោះជំងឺរបេង[14]។
ទាំងនេះគឺជាៈ

1. មនុស្សដែលមានប្រព័ន្ធភាពស៊ាំខ្សោយ។ ដូចជាៈ
   a. អ្នកដែលមានផ្ទុកមេរោគអេដស៍ ទឹកនោមផ្អែម និងជំងឺដែលចុះខ្សោយភាពស៊ាំផ្សេងទៀត។
   b. មនុស្សដែលមានអាហារូបត្ថម្ភខ្សោយ។
   c. មនុស្សចាស់។
2. អ្នកដែលជក់បារីច្រើនពេក ឬប្រើប្រាស់គ្រឿងស្រវឹង និងគ្រឿងញៀន។
3. មនុស្សដែលរស់នៅ និងធ្វើការក្នុងកន្លែងបិទជិត ដូចជា កម្មកររ៉ែ កម្មកររោងចក្រ
4. មនុស្សនៅក្នុងពន្ធនាគារ ឬ ត្រូវបានឃុំខ្លួន
5. ប្រជាជនចល័ត ជនចំណាកស្រុក និងប្រជាជននិរទេស
6. ប្រជាជនជនជាតិដើមភាគតិច។

## តើខ្ញុំដឹងថាមានជំងឺរបេងដោយរបៀបណា?

ជំងឺរបេងសួតត្រូវបានធ្វើរោគវិនិច្ឆ័យដោយការធ្វើតេស្តកំហាក និងការថតកាំរស្មីអ៊ិច ។ តេស្តដែលពេញនិយមជាងគេគឺ ការធ្វើតេស្តពង្រីកអាស៊ីតនុយក្លេអ៊ែរដែលមានមូលដ្ឋានលើប្រអប់(CBNAAT) Xpert MTB/RIF ។ ចំពោះអ្នកផ្ទុកមេរោគអេដស៍(PLHIV) ត្រូវបានណែនាំការធ្វើតេស្តបន្ថែមដោយប្រើ TB LAM (ការធ្វើតេស្ត lipoarabinomannan) ។ ជំងឺរបេងសួតបន្ថែម (Extra-pulmonary TB) ត្រូវបានធ្វើរោគវិនិច្ឆ័យដោយការពិនិត្យលើតំបន់ដែលរងផលប៉ះពាល់ជាក់លាក់ និងយកសំណាកទៅពិនិត្យនៅក្រោមមីក្រូទស្សន៍។ការធ្វើតេស្តទាំងនេះរួមជាមួយរោគសញ្ញាអាចកំណត់ពីការឆ្លងមេរោគរបេងសកម្ម ឬ ជំងឺរបេង។ នៅពេលដែលគេបានធ្វើរោគវិនិច្ឆ័យឃើញថាមានជំងឺរបេង ការធ្វើតេស្តភាពដើម្បីផ្លាស់ប្តូរថ្នាំគួរតែត្រូវបានអនុវត្ត ដើម្បីកំណត់ថាតើមនុស្សម្នាក់មានភាពប្រែប្រួលថ្នាំ ឬ មានជំងឺរបេងស៊ាំនឹងថ្នាំ (drug resistant-TB) ដែរឬទេ។

គួរកត់សម្គាល់ថាការធ្វើរោគវិនិច្ឆ័យជំងឺរបេងចំពោះក្មេងៗពិតជាពិបាកខ្លាំងណាស់។ នេះបណ្តាលមកពីការលំបាកក្នុងការប្រមូលកំហាកពីកុមារ រួមទាំងទារកផង។ លើសពីនេះទៅទៀតបើទោះជាមានកំហាកប្រមូលបានក៏ដោយ ការធ្វើតេស្តកំហាកនឹងប្រែជាអវិជ្ជមានដោយសារចំនួនបាក់តេរីអាចតូចពេកសម្រាប់ការធ្វើតេស្តដើម្បីផ្តល់លទ្ធផលត្រឹមត្រូវ។

[14] Stop TB Partnership Key Populations Brief. http://www.stoptb.org/news/stories/2016/ns16_018.asp

Bacillus Calmette-Guérin (BCG) នៅតែជាវ៉ាក់សាំងដែលត្រូវបានណែនាំសម្រាប់ទារកនិងកុមារអាយុក្រោម ៥ ឆ្នាំ។

## តើជំងឺរបេង ត្រូវធ្វើការព្យាបាលយ៉ាងដូចម្តេច?

ជំងឺរបេងគឺជាជំងឺដែលអាចព្យាបាលបាន។ ថ្នាំរបេងអាចរកបានដោយឥតគិតថ្លៃនៅតាមមណ្ឌលសុខភាពសាធារណៈ។ ការព្យាបាលជំងឺរបេងដែលងាយនឹងទទួលថ្នាំត្រូវចំណាយពេលពីប្រាំមួយ (៦) ទៅប្រាំបី (៨) ខែ។ ចំពោះជំងឺរបេងដែលស៊ាំនឹងថ្នាំការព្យាបាលត្រូវចំណាយពេលយូរពី ១៨ ខែដល់ ២៤ ខែ។ ការព្យាបាលរួមមានការរួមបញ្ចូលគ្នានៃថ្នាំ - Isoniazid, Rifampicin, Ethambutol និង Pyrazinamide ។

ចំពោះជំងឺរបេងដែលធន់នឹងថ្នាំ (drug-resistant TB) ការព្យាបាលត្រូវការពេលយូរ ដោយជាទូទៅចាប់ពី ១៨ ខែដល់ ២៤ ខែ។ ទោះយ៉ាងណា ថ្នាំថ្មីដូចជា Bedaquiline, Delamanid, Clofazime និង Linezolid អាចកាត់បន្ថយរយៈពេលមកត្រឹម ៩ខែ ខណៈពេលកំពុងប្រើវិធីព្យាបាលតាមមាត់ គឺជាម៉ូលេគុលតូចដែលត្រូវបានគេយកតាមមាត់។ ចំពោះជំងឺរបេងដែលស៊ាំនឹងថ្នាំយ៉ាងទូលំទូលាយ (XDR TB) ថ្នាំ Pretomanid ត្រូវបានអនុម័តណែនាំឲ្យប្រើប្រាស់ក្នុងពេលថ្មីៗនេះ។

ការប្រកាន់ខ្ជាប់ការព្យាបាលមានសារៈសំខាន់ខ្លាំងណាស់ក្នុងការព្យាបាលជំងឺរបេង។ ប៉ុន្តែមានពេលខ្លះនៅពេលដែលអ្នកដែលមានជំងឺរបេងពិបាកក្នុងការប្រកាន់ខ្ជាប់ ឬ ពិបាកក្នុងការទ្រំទ្រដល់ចប់ការព្យាបាលព្រោះផលប៉ះពាល់ (ឧទាហរណ៍ស្បែករមាស់ កន្ទួល ចង់ក្អួត ទឹកនោមមានពណ៌ងងឹតជាងមុន រាក មានអារម្មណ៍តឹងណែននៅចុងដៃចុងជើង ហើយក៏អាចនាំឱ្យមានផលប៉ះពាល់ដែលគ្រោះថ្នាក់ជាងនេះទៅទៀត ដូចជារលាកថ្លើម និង ការបាត់បង់ការស្តាប់ បណ្តោះអាសន្ន ឬ អចិន្ត្រៃយ៍) អាចពិបាកក្នុងការគ្រប់គ្រង ឬ ដោយសារតែការធ្វើដំណើរប្រចាំថ្ងៃទៅកាន់កន្លែងព្យាបាលរំខានដល់ការរស់នៅរបស់ពួកគេ។ ការចេញវេជ្ជបញ្ជាមិនត្រឹមត្រូវ ការបាត់បង់ការព្យាបាល ឬការបញ្ឈប់ការព្យាបាលអាចបណ្តាលឱ្យបាក់តេរីរបេងក្លាយទៅជាស៊ាំនឹងថ្នាំ។ នៅពេលរឿងនេះកើតឡើងថ្នាំដែលត្រូវការដើម្បីព្យាបាលពួកគាត់ត្រូវតែខ្លាំងជាងប៉ុន្តែមានជាតិពុលច្រើន។ ការព្យាបាលជំងឺរបេងដែលធន់នឹងថ្នាំក៏ថ្លៃជាងថ្នាំរបេងធម្មតាដែរ ហើយក៏នឹងត្រូវការចំណាយពេលព្យាបាលយូរ។

ដើម្បីជួយធានានូវការប្រកាន់ខ្ជាប់ការព្យាបាលអ្នកដែលមានជំងឺរបេងត្រូវបានលើកទឹកចិត្តឱ្យមានដៃគូព្យាបាល ឬការគាំទ្រនៅពេលព្យាបាល។ ដៃគូព្យាបាលនេះត្រូវបានគេរំពឹងថានឹងគាំទ្រអ្នកដែលមានជំងឺរបេង រំលឹកពួកគាត់ឱ្យលេបថ្នាំរបស់ពួកគាត់ និងគាំទ្រពួកគាត់ក្នុងការគ្រប់គ្រងទិដ្ឋភាពផ្សេងទៀតនៃការព្យាបាល រួមទាំងផលប៉ះពាល់នៃថ្នាំ និងផលប៉ះពាល់នៅក្នុងជីវិតប្រចាំថ្ងៃរបស់ពួកគាត់។

## តើខ្ញុំការពារខ្លួន ពីការឆ្លងជំងឺរបេងដោយរបៀបណា?

1. ប្រព័ន្ធភាពស៊ាំខ្លាំងអាចការពារមនុស្សម្នាក់ពីការឆ្លងមេរោគរបេង។
2. វាចាំបាច់ក្នុងការសម្រាកឱ្យបានគ្រប់គ្រាន់។

3. មានរបបអាហារល្អ និងមានជីវជាតិ។
4. បញ្ឈប់ការជក់បារី ចៀសវាងគ្រឿងស្រវឹងនិងថ្នាំផ្សះ។
5. បន្ទាប់ពីការព្យាបាលរយៈពេលខ្លីមនុស្សដែលទទួលរងពីជំងឺរបេងលែងឆ្លងទៀតហើយ។ ដូច្នេះការប្រកាន់ខ្ជាប់នូវការព្យាបាលអាចការពារការចម្លងជំងឺរបេង។
6. ខ្ទប់ច្រមុះ និងមាត់នៅពេលក្អកដើម្បីការពារការរីករាលដាលនៃជំងឺរបេងបន្ថែមទៀត ប្រសិនបើអ្នកមានរោគសញ្ញាទាក់ទងនឹងជំងឺរបេង។ ប្រសិនបើមានម៉ាសបិទមុខ និងអាចប្រើប្រាស់បានសូមពាក់វា។ ក្រោយបង្អួចឱ្យបើកចំហ និងធានាឱ្យមានខ្យល់ចេញចូលល្អ ជាពិសេសនៅកន្លែងដែលមានមនុស្សច្រើន។

## ប្រភពពីអង្គការ Stop TB Partnership

អង្គការ Stop TB Partnership បានបង្កើតកម្មវិធី App ដែលរួមបញ្ចូលនូវមូលដ្ឋានព័ត៌មានអំពីជំងឺរបេង។ កម្មវិធីនេះមានឈ្មោះថា OneImpact ដែលបច្ចុប្បន្ននេះ កំពុងត្រូវបានអនុវត្តនៅក្នុងប្រទេសឥណ្ឌូនេស៊ី និងនៅកម្ពុជា។ អ្នកដែលមានទូរស័ព្ទអាចទាញយកកម្មវិធីដោយចូលទៅកាន់គេហទំព័ រhttps://stoptbpartnershiponeimpact.org/ or through the App Store

អង្គការ Stop TB Partnership ក៏បានបង្កើតផ្ទាំងគ្រប់គ្រងព័ត៌មាន ដើម្បីពិនិត្យលើវឌ្ឍនភាពរបស់ប្រទេសនានា នៅក្នុងការឆ្លើយតបទៅនឹងជំងឺរបេងរបស់ពួកគេ។ តំណនេះអាចត្រូវបានណែនាំក្នុងពេលពិភាក្សា៖ http://www.stoptb.org/resources/cd/

## សារស្នូល៖

1. ជំងឺរបេង គឺជាជំងឺឆ្លង ប៉ុន្តែវាអាចព្យាបាល និងការពារបាន។
2. ការព្យាបាលជាប់លាប់ គឺជាគន្លឹះក្នុងការព្យាបាលជំងឺរបេងជាសះស្បើយ ការពារការកើតឡើងវិញ ក៏ដូចជាការការពារនៃការរាលដាលមេរោគផងដែរ។
3. វាជាការសំខាន់ ក្នុងការស្វែងយល់ពីមូលហេតុដែលបុគ្គលមានជំងឺរបេង ហើយមិនអាចបញ្ចប់ការព្យាបាលរបស់ពួកគេ ដូច្នេះអ្នកផ្តល់សេវាសុខភាព អាចបញ្ចូលសេវាជទៃទៀត ដែលដោះស្រាយភាពលំបាក ឬបញ្ហាប្រឈមទាំងនេះ និងដោះស្រាយនូវឧបសគ្គ ដែលអ្នកជំងឺជួបប្រទះក្នុងពេលព្យាបាល។

## ឯកសារយោងបន្ថែម

ការពិត ១០យ៉ាងអំពីជំងឺរបេង WHO កញ្ញា 2018. https://www.who.int/features/factfiles/tuberculosis/en/
ការពិតអំពីមូលដ្ឋានជំងឺរបេង CDC March 2016. https://www.cdc.gov/tb/topic/basics/default.htm

## ឃ. វគ្គភ្ជាប់ទំនាក់ទំនងៈ បញ្ហាដែលទាក់ទងនឹងជំងឺរបេងនានា នៅសហគមន៍

គោលបំណងៈ ដើម្បីជម្រុញឱ្យអ្នកចូលរួមចាប់ផ្តើមគិត អំពីបញ្ហាដែលប្រឈមដោយជំងឺរបេង។

ពេលវេលា: ៣០ នាទី

ជំហានៈ

1. សូមប្រើប្រាស់សំណួរខាងក្រោម ក្នុងការឈានទៅសកម្មភាពបំផុសគំនិត។ ចំណាំថា សំណួរទាំងនេះបង្កើតឡើងដោយយោងទៅលើចម្លើយរបស់អ្នកចូលរួម។
    a. ក្នុងចំណោមអ្នកទាំងអស់គ្នា តើមានអ្នកស្គាល់នរណាមានមាន ឬធ្លាប់មានជំងឺរបេងឬទេ?
    b. តាមគំនិតរបស់អ្នក តើសហគមន៍ គិតដូចម្តេចខ្លះចំពោះអ្នកមានជំងឺរបេង?
    c. តើអ្នកគិតយ៉ាងណាខ្លះ ចំពោះផលប៉ះពាល់ នៃការយល់ឃើញទាំងនេះចំពោះអ្នកជំងឺរបេង?
    d. តើអ្នកគិតយ៉ាងណាខ្លះ ចំពោះផលប៉ះពាល់ នៃការយល់ឃើញទាំងនេះចំពោះអ្នកជំងឺរបេងនៅក្នុងតំបន់ ឬប្រទេសរបស់អ្នក?
2. ប្រសិនបើ អាចជួយបាន អ្នកអាចប្រើប្រាស់សាច់រឿង ឬករណីសិក្សាមួយខាងក្រោម។
    a. ចន ឬជេន(ឈ្មោះតួអង្គ) ត្រូវបានគេធ្វើរោគវិនិច្ឆ័យថាមានជំងឺរបេង។ ប្រសិនបើអ្នកជិតខាងរបស់គាត់ដឹងអំពីការឆ្លងមេរោគរបេងរបស់គាត់ តើអ្នកគិតថាពួកគេនឹងមានប្រតិកម្មយ៉ាងណា? តើពួកគេនឹងគិតយ៉ាងណាចំពោះគាត់? តើពួកគេចាត់ទុកគាត់យ៉ាងណាដែរ?
    b. ប្រសិនបើអ្នកជិតខាង/សហគមន៍មានប្រតិកម្ម ឬការឆ្លើយតបបែបអវិជ្ជមានចំពោះចន/ជេន ដោយសារតែការឆ្លងមេរោគរបេងរបស់គាត់ តើនឹងមានអ្វីកើតឡើងចំពោះចន/ជេន? តើគាត់នឹងមានប្រតិកម្មយ៉ាងណា? តើគាត់/នាងនឹងធ្វើអ្វី ឬមិនធ្វើអ្វី?
    c. ប្រសិនបើ មនុស្សកាន់តែច្រើនឡើងឆ្លងជំងឺរបេងដូចជាករណី ចន/ជេន ហើយមនុស្សនៅជុំវិញពួកគេនូវតែបន្តធ្វើដាក់តាមរបៀបដែលចន/ជេនត្រូវបានអ្នកជិតខាងធ្វើដាក់ តើអ្នកគិតថា នឹងមានអ្វីកើតឡើងចំពោះស្ថានភាពជំងឺរបេងនៅតាមតំបន់ ឬប្រទេសទាំងមូល?
3. គូសបញ្ជាក់ការឆ្លើយតបរបស់អ្នកចូលរួម ដែលឆ្លុះបញ្ចាំងពីបទពិសោធន៍នៃការរើសអើង ឬការបំពាន។
4. នេះជាឱកាសមួយ ដែលអ្នកចូលរួមនឹងបើកចំហអំពីបទពិសោធន៍ផ្ទាល់ខ្លួនរបស់ពួកគេ។ ថ្លែងអំណរគុណរនូវរាល់ការចែករំលែកពិសោធន៍ទាំងនោះ ហើយរំលឹកពួកគេថា នឹងមានពេលច្រើនទៀតនៅវគ្គបន្ទាប់ ដើម្បីនិយាយពីបទពិសោធន៍ផ្ទាល់ខ្លួនរបស់ពួកគេ។
5. បញ្ចប់វគ្គបំផុសគំនិតដោយធ្វើការសេចក្តីសង្ខេប នៃបញ្ហាដែលបានចែករំលែកដោយអ្នកចូលរួម និងរំលឹកឡើងវិញ អំពីបញ្ហាទាំងនោះ ដែលបានជួបប្រទះជាទូទៅ ដោយអ្នកជំងឺរបេងនៅកន្លែងផ្សេងគ្នា និងប្រទេស។

## ង. ជំងឺរបេង និងសិទ្ធិមនុស្ស

គោលបំណង៖ ដើម្បីលើកកម្ពស់ការយល់ដឹងរបស់អ្នកចូលរួមលើបញ្ហាសិទ្ធិមនុស្សនានា ដែលបានជួបប្រទះដោយអ្នកជំងឺរបេង។

ពេលវេលា៖ ៦ ម៉ោងនិង ៣០ នាទី

សកម្មភាព៖

1. ការសរសេរលិខិត (Letter-writing)
2. ការចែករំលែកជាក្រុម (Group Sharing)
3. វគ្គដោះបន្ទុក និងការធ្វើសមាធិ (Unloading and Meditation Session)
4. ការងារជាក្រុម (Group Work)
5. ការសម្ដែងតួរ (Role-playing)
6. ការពិភាក្សា និងស្លាយបង្ហាញ (Discussion and Slide presentation)

សម្ភារៈ៖

1. ក្រដាសសរសេរ
2. ប៊ិចពណ៌
3. ក្រដាសពណ៌ ឬក្រដាសបិទតូច (post-its)
4. ប៊ិចហ្វឺត
5. ស្កុត
6. តន្ត្រីសម្រាប់សមាធិ ជ្រើសរើសបទមួយជាមួយនឹងសម្លេងទឹកហូរ
7. កុំព្យូទ័រយួរដៃ និងម៉ាស៊ីនបញ្ចាំង។

ជំហាន៖

### សកម្មភាពការសរសេរលិខិត (៦០ នាទី)

1. ចែកក្រដាសសរសេរ និងប៊ិចពណ៌ដល់អ្នកចូលរួម។
2. ណែនាំអ្នកចូលរួមឱ្យចែករំលែកបទពិសោធន៍របស់ពួកគេ នៅពេលដែលមានជំងឺរបេងដោយសរសេរលិខិតទៅនរណាម្នាក់ ដែលពួកគេជឿទុកចិត្ត។ ពួកគេអាចជ្រើសរើសនរណាម្នាក់ ដែលចង់សរសេរទៅកាន់។ ជូនដំណឹងដល់ពួកគេថា ពួកគេនឹងអានសំបុត្ររបស់ខ្លួនទៅកាន់សមាជិកក្រុមផ្សេងទៀតនៅក្នុងវគ្គបន្ទាប់។
3. ដើម្បីជួយដល់អ្នកចូលរួមរៀបចំអ្វីៗ ដែលពួកគេចង់ចែករំលែក គួរផ្ដល់ឱ្យនូវសំណួរតម្រង់ទិសដូចខាងក្រោម៖
    a. តើអ្វីខ្លះ ដែលជាការលំបាកឬឧបសគ្គបំផុត សម្រាប់អ្នកនៅពេលអ្នកមានជំងឺរបេង?

b. តើអ្នកភ័យខ្លាចអំពីអ្វីខ្លះ ចំពោះការកើតរោគរបេង?

4. ក្នុងករណីដែលអ្នកចូលរួមជាអ្នកងាយរងគ្រោះ ប៉ុន្តែមិនបានកើតជំងឺរបេង អ្នកគួរផ្តល់នូវសំណួរតម្រង់ទិសដូចខាងក្រោម៖
    a. តើអ្នកនឹងធ្វើអ្វីខ្លះ ប្រសិនបើអ្នកបានរកឃើញថាអ្នកមានជំងឺរបេង?
    b. តើអ្នកនឹងឆ្លើយតបយ៉ាងដូចម្តេចដែរ? ហេតុអ្វី?
    c. តើអ្វីខ្លះ អ្នកគិតថាពិបាកបំផុតសម្រាប់អ្នក ប្រសិនបើអ្នកត្រូវបានគេធ្វើរោគវិនិច្ឆ័យថាមានជំងឺរបេង?
5. ទុកពេលឱ្យអ្នកចូលរួមមួយម៉ោង ដើម្បីធ្វើការឆ្លុះបញ្ចាំង និងសរសេរសំបុត្ររបស់ពួកគេ។

## ការចែករំលែកជាក្រុម (៦០ នាទី)

1. ចែកអ្នកចូលរួមជា ៤ ក្រុម
2. ប្រាប់ក្រុមនីមួយៗឱ្យអង្គុយជិតគ្នាជារង្វង់។ ត្រូវប្រាកដថា ក្រុមទាំងអស់មានកន្លែងទំនេរចន្លោះគ្រប់គ្រាន់ដើម្បីកាត់បន្ថយសំលេងរំខានក្នុងកំឡុងពេលធ្វើសកម្មភាព។
3. អ្នកចូលរួមម្នាក់ៗនឹងដាក់វេនគ្នាអានសំបុត្ររបស់ពួកគេទៅកាន់មិត្តរួមក្រុម។
4. ទុកពេលមួយម៉ោងសម្រាប់អ្នកចូលរួមទាំងអស់អានសំបុត្ររបស់ពួកគេ។

## វគ្គការបន្ធូរអារម្មណ៍ និងការធ្វើសមាធិ (១៥ នាទី)

ការសរសេរសំបុត្រហើយអានទៅឱ្យអ្នកដទៃស្តាប់ អាចធ្វើឱ្យអារម្មណ៍មិនល្អចំពោះអ្នកចូលរួម។ អ្នកត្រូវផ្តល់ពេលវេលាខ្លះដល់ពួកគេ ដើម្បីបញ្ចេញអារម្មណ៍តានតឹងទាំងនេះមុននឹងឈានទៅវគ្គបន្ត។ សកម្មភាពនេះនឹងជួយដល់អ្នកចូលរួម "ទម្លាក់បន្ទុក" រឿងរ៉ាវអ្វីផ្សេងៗ ដែលអាចលេចចេញពីសកម្មភាពមុន។ សូមកត់សម្គាល់ថា មានអ្នកចូលរួមមួយចំនួន អាចចងចាំបទពិសោធន៍ឈឺចាប់អំឡុងពេលសរសេរសំបុត្រ ឬសកម្មភាពចែករំលែកជាក្រុម។ គួរណែនាំឱ្យមានបុគ្គលិកសង្គម ឬអ្នកប្រឹក្សាម្នាក់ ដើម្បីជួយអ្នកចូលរួមក្នុងដំណើរការអារម្មណ៍ ឬបទពិសោធន៍លំបាកទាំងនោះ។

1. ស្នើឱ្យអ្នកចូលរួមយកកៅអីបង្កើតជារង្វង់ ហើយអង្គុយចុះ។
2. សួរពួកគេថា តើមាននរណាម្នាក់ក្នុងចំណោមអ្នកចូលរួម ដែលចង់ចែករំលែកអារម្មណ៍ នៅពេលសរសេរសំបុត្រ និងចែករំលែកពីសកម្មភាពរបស់ពួកគេឬទេ។ លើកទឹកចិត្តអ្នកចូលរួម និយាយអំពីអារម្មណ៍ទាំងនោះដោយរំលឹកអ្នកចូលរួមថា បន្ទប់នេះជាកន្លែងដែលមានសុវត្ថិភាព ហើយអ្នកចូលរួមទាំងអស់ បានយល់ព្រមគោរពមតិយោបល់ និងអារម្មណ៍របស់គ្នាទៅវិញទៅមក។ អ្នកក៏អាចសួរសំណួរពីអារម្មណ៍របស់ពួកគេ នៅពេលដែរកំពុងស្តាប់អ្នកចូលរួមផ្សេងទៀតអានអក្សររបស់ពួកគេផងដែរ។
3. ជាគំនិតល្អក្នុងការចង្អុលបង្ហាញពីបទពិសោធន៍រួម ក្នុងចំណោមអ្នកចូលរួមទាំងអស់ ដូចករណីដែលមាននេះ។ រំលឹកចំណុចទាំងនេះ អាចជាមូលដ្ឋានគ្រឹះសម្រាប់ពួកគេ រួមគ្នាជាសហគមន៍រឹងមាំមួយ ដែលគាំទ្រគ្នាទៅវិញទៅមក។

4. បន្ទាប់ពីអ្នកចូលរួមបានចែករំលែកបង្ហាញពីគំនិត ឬអារម្មណ៍របស់ពួកគេរួចហើយ សូមឱ្យអ្នកចូលរួមទាំងអស់ក្រោកឈរឡើង។ អ្នកសម្របសម្រួល (ឬអ្នកប្រឹក្សា ឬបុគ្គលិកសង្គមកិច្ច ដែលអាចត្រូវបានអញ្ជើញសម្រាប់វគ្គនេះ) អាចដឹកនាំអ្នកចូលរួមធ្វើលំហាត់ដកដង្ហើម៖ អញ្ជើញអ្នកចូលរួមឱ្យបិទភ្នែក ហើយចាប់ផ្តើមដកដង្ហើមដើម្បីធ្វើឱ្យខ្លួនឯងមានចិត្តស្ងប់ ហើយដកដង្ហើមចេញ ដើម្បីបញ្ចេញបន្ទុកអារម្មណ៍ ឬផ្លូវចិត្ត។ ធ្វើសកម្មភាពបែបនេះម្តងហើយម្តងទៀតឱ្យបានច្រើនដងតាមដែលអាចធ្វើបាន។ អ្នកសម្របសម្រួលអាចចាក់ភ្លេងបន្ធូរអារម្មណ៍នៅពេលដែលកំពុងប្រតិបត្តលំហាត់នេះ។
5. បន្ទាប់ពីការធ្វើលំហាត់ដកដង្ហើមរួចហើយ ប្រាប់អ្នកចូលរួមឱ្យលើកដៃឡើងទៅលើអាកាសហើយក្រលាស់។ ធ្វើដូចគ្នាជាមួយជើងនីមួយៗផងដែរ។ ប្រាប់ពួកគេឱ្យស្រមៃថា នៅពេលដែលពួកគេកំពុងក្រលាស់ដៃ និងជើង ពួកគេកំពុងតែរលាក់ចេញនូវបទពិសោធន៍ និងអារម្មណ៍អវិជ្ជមាន ដែលពាក់ព័ន្ធនឹងផ្លូវចិត្តរបស់ពួកគេ។
6. បន្ទាប់ពីនេះ សួរពួកគេថា តើអ្នកមានអារម្មណ៍យ៉ាងណា? ត្រូវស្វែងយល់ថា តើមាននរណាខ្លះ ត្រូវការពេលវេលាបន្ថែមទៀតសម្រាប់បន្ធូរអារម្មណ៍ទេ? ប្រសិនបើមាន ឱ្យអ្នកចូលរួមដែលត្រូវការពេលវេលាបន្ថែមសម្រាប់បន្ធូរអារម្មណ៍ ហើយជាគំនិតល្អក្នុងការសម្រាក ១៥ នាទី។
7. មុននឹងអនុញ្ញាតឱ្យអ្នកចូលរួមសម្រាក អញ្ជើញពួកគេឱបគ្នាជាក្រុម ដែលជានិមិត្តរូបនៃការគាំទ្រសហគមន៍ចំពោះគ្នាទៅវិញទៅមក។
8. ប្រធានបទនេះ អាចត្រូវបានធ្វើឡើងតាមវិធីផ្សេងៗគ្នា អាស្រ័យលើអ្វីដែលជាវប្បធម៌សមស្របទៅនឹងស្ថានភាពអារម្មណ៍របស់អ្នកចូលរួម បន្ទាប់ពីសកម្មភាពអានសំបុត្រហើយ។ អ្វីដែលសំខាន់ គឺអ្នកចូលរួមអាចបញ្ចេញនូវអារម្មណ៍អវិជ្ជមាន ដែលចេញមកពីការសរសេរ និងចែករំលែកអំពីបទពិសោធន៍លំបាកទាក់ទងនឹងជំងឺរបេង និងស្មារតីចែករំលែកបទពិសោធន៍ដែលមិនមែនជារបស់ពួកគេផ្ទាល់ ដែលមិនមែនជារបស់ពួកគេនៅក្រុមទាំងមូល ។

## ការងារក្រុម ដើម្បីកំណត់បញ្ហាប្រឈម និងលទ្ធផលនៃបញ្ហាប្រឈមទាំងនេះ (៦០ នាទី)

1. ឱ្យអ្នកចូលរួមត្រលប់ទៅក្រុមតូចរបស់ពួកគេវិញ។
2. ផ្តល់ជូនក្រុមនីមួយៗនូវក្រដាសបិទតូច(Post-It) ឬក្រដាសពណ៌ និងហ្វឺត។
3. ប្រើក្រដាសបិទមួយពណ៌(Post-It) សម្រាប់អ្នកចូលរួមកត់ត្រាបទពិសោធន៍លំបាក ឬបញ្ហាប្រឈម ដែលពួកគាត់បានជួបប្រទះនៅពេលពួកគេមានជំងឺរបេង។ នៅពេលដែលពួកគេធ្វើរួច ប្រាប់អ្នកចូលរួមឱ្យប្រើប្រាស់ក្រដាសបិទ(Post-It)មួយពណ៌ផ្សេងទៀត ដើម្បីសរសេរពីផលប៉ះពាល់ នៃការលំបាក/បញ្ហាប្រឈមទាំងនោះ ទៅលើជីវិតរបស់ពួកគេ។
4. ទុកពេលឱ្យអ្នកចូលរួម ៣០នាទី សម្រាប់ការងារក្រុមនេះ។
5. បន្ទាប់ពី ៣០ នាទី ឱ្យក្រុមនីមួយៗចែករំលែកនូវអ្វី ដែលពួកគេបានសរសេរនៅលើក្រដាសបិទ(Post-Its) របស់ពួកគេ។ ចាប់ផ្តើមជាមួយបទពិសោធន៍លំបាក ឬឧបសគ្គ ហើយបន្ទាប់មកផលលំបាក។

6. នៅពេលអ្នកចូលរួមកំពុងចែករំលែកលទ្ធផលនៃការងារក្រុមរបស់ពួកគេ ប្រាប់ពួកគេឱ្យបិទចម្លើយទាំងនោះនៅលើក្តារព័ត៌មាន ឬជញ្ជាំង។
7. សង្ខេបលទ្ធផល ដោយដាក់នូវបទពិសោធន៍ដូចគ្នាជាក្រុម ហើយចង្អុលបង្ហាញពីបទពិសោធន៍ប្លែកៗផងដែរ។ ទោះបីជា បទពិសោធន៍ទាំងនេះត្រូវបានជួបប្រទះដោយអ្នកចូលរួមតែពីរ ឬបីនាក់ក៏ដោយ វាក៏មានសារសំខាន់ដែរ។
8. បន្ទាប់ពីអ្នកសម្របសម្រួលបានសង្ខេបគ្រប់យ៉ាយរួចអស់ សូមជូនដំណឹងដល់អ្នកចូលរួមថា អ្នកនឹងប្រើមតិពីបទពិសោធន៍របស់ពួកគេសម្រាប់វគ្គបន្ទាប់។
9. អញ្ជើញអ្នកចូលរួមឱ្យសួរសំណួរ ឬយោបល់បើមាន។

ប្រសិនបើ របៀបវារៈដែលបានរៀបចំបានដំណើរការ នោះថ្ងៃដំបូងនៃវគ្គបណ្តុះបណ្តាលត្រូវបានបញ្ចប់។ បើមិនដូច្នោះទេ គួរតែមានការសម្រាកប្រហែល ៣០នាទីមុន នៅមុនប្រធានបទបន្ទាប់។ ក្នុងកំឡុងពេលសម្រាកនេះ អ្នកសម្របសម្រួល ឬក្រុមអ្នកបណ្តុះបណ្តាលនឹងត្រូវដំណើរការដូចខាងក្រោម៖

1. ចំណាយពេលខ្លះ ដើម្បីរៀបចំចម្លើយនៅក្រដាសបិទ(Post-It) ជាក្រុមនៅលើជញ្ជាំង។ ប្រមូលផ្តុំ ឬធ្វើចំណាត់ថ្នាក់ឡើងវិញ នូវការឆ្លើយតបលើប្រធានបទខាងក្រោម៖
    - **សកម្មភាពនៃការរើសអើងដោយសារស្ថានភាពជំងឺរបេង** - ទាំងនេះ គឺជាសកម្មភាពខុសពីធម្មតាដែលប្រព្រឹត្តលើអ្នកមានជំងឺរបេង ហើយជាធម្មតាស្ថិតក្នុងមធ្យោបាយអវិជ្ជមាន ពីព្រោះពួកគេមានជំងឺរបេង ឬដោយសារតែពួកគេត្រូវបានគេដឹង ឬសង្ស័យថាមានជំងឺរបេង។ ជាឧទាហរណ៍ ដូចជាត្រូវបានដកសិទ្ធិពីការដាក់ពាក្យសុំការងារតែម្នាក់ឯងដោយសារតែនិយោជក បានរកឃើញមុនថាអ្នកដាក់ពាក្យមាន ឬមានសង្ស័យថាមានជំងឺរបេង។
    - **ការរំលោភសិទ្ធិមនុស្សដែលមិនមែនជាសកម្មភាពនៃការរើសអើង** - ទាំងនេះ គឺជាសកម្មភាពនៃការរើសអើងដែលអាចកើតឡើងដោយរដ្ឋាភិបាល ឬមន្ត្រីរបស់រដ្ឋាភិបាល ដូចជា ប៉ូលីស អ្នកផ្តល់សេវាសុខភាពសាធារណៈ និង អ្នកដទៃទៀត។ ឧទាហរណ៍៖ នៅពេលដែលអ្នកជំងឺរបេងមិនអាចទទួលបានថ្នាំដោយសារតែមិនមាននៅក្នុងឃ្លាំងក្នុងមណ្ឌលសុខភាពដែលនៅជិតបំផុតរបស់ពួកគេ ត្រូវបានចាត់ទុកថាជាការរំលោភសិទ្ធិមនុស្សផ្សេងទៀតដែលមិនមែនជាសកម្មភាពរើសអើង។
    - **បញ្ហាប្រឈមឬការលំបាកផ្សេងទៀត** - ប្រសិនបើអ្នកមិនប្រាកដអំពីអំពើរើសអើងណាមួយ សូមដាក់វានៅក្រោមប្រភេទនេះ។ ឧទាហរណ៍: ផលប៉ះពាល់អវិជ្ជមាននៃថ្នាំអាចចាត់ទុកថាជាការលំបាក។

2. គ្រប់ក្រដាសបិទ(Post-Its) ដែលជះឥទ្ធិពលនៃបទពិសោធន៍លំបាក ក៏គួរតែត្រូវបានដាក់ជាក្រុមតាមប្រធានបទដូចខាងក្រោម៖
    - ផ្នែករាងកាយ - ឧទាហរណ៍៖ ផលប៉ះពាល់ខាងរាងកាយបណ្តាលមកពីថ្នាំ ដូចជារាគ ឬ ទឹកនោមងងឹត
    - ផ្នែកផ្លូវចិត្ត ឬអារម្មណ៍ - ឧទាហរណ៍៖ ការបាក់ទឹកចិត្ត ការថប់បារម្ភ និងភាពអស់សង្ឃឹម

- ផ្នែកសង្គម - ឧទាហរណ៍៖ អារម្មណ៍ឯកោត្រូវបានគ្រួសារបដិសេធ
- ផ្នែកហិរញ្ញវត្ថុ ឬសេដ្ឋកិច្ច - ឧទាហរណ៍៖ ផលប៉ះពាល់មហន្តរាយនៅពេលកំពុងព្យាបាលជំងឺរបេង
- ផ្សេងទៀត - ប្រសិនបើអ្នកមិនអាចចាត់ថ្នាក់ប្រភេទផលប៉ះពាល់ណាមួយសូមដាក់វានៅក្រោមប្រភេទនេះ

ទុកក្រដាសបិទ(Post-Its) ដែលត្រូវបានដាក់ជាក្រុមនៅលើជញ្ជាំង។ ប្រាប់ឱ្យអ្នកចូលរួមត្រលប់មកបន្ទប់វិញ។

1. យោងទៅលើក្រដាសបិទ(Post-Its) នៅលើជញ្ជាំង។ ពន្យល់ដល់អ្នកចូលរួមពីរបៀបដែលក្រដាសបិទ (Post-Its) ត្រូវបានរៀបចំឡើងវិញ ឱ្យទៅជាប្រធានបទផ្សេងៗគ្នា។ និយាយពីប្រធានបទផ្សេងៗគ្នាដែល Post-Its ត្រូវបានដាក់បញ្ចូលគ្នា។
2. ណែនាំពាក្យ "រំលោភសិទ្ធិមនុស្ស" និង "សកម្មភាពនៃការរើសអើង" និងកំណត់ពាក្យទាំងនេះ ដោយប្រើប្រាស់ប្រយោគនៅលើក្តារព័ត៌មានជាឧទាហរណ៍។

## ការសម្តែងតួរ (១២០នាទី)

1. ចែកអ្នកចូលរួមជាពីរក្រុមធំ(២)តាមការស្ម័គ្រចិត្ត ។
2. ប្រាប់ឱ្យក្រុមនីមួយៗ ជ្រើសរើសយកមួយក្នុងចំណោម ការរំលោភសិទ្ធិមនុស្ស ឬ សកម្មភាពនៃរើសអើង ដែលបានសរសេរនៅលើក្រដាសបិទ(Post-Its)។
3. ប្រាប់ក្រុមនីមួយៗឱ្យបែងចែកខ្លួនឯងបន្ថែមទៀតជាពីរក្រុមរង។ ចាត់តាំងក្រុមរងមួយជា "ការរំលោភបំពាន" និងក្រុមរងផ្សេងទៀតជា "គម្រូល្អ" ។ ក្រុមរង "រំលោភបំពាន" នឹងបង្កើតការសម្តែង ៣នាទី អំពីបទពិសោធន៍ដែលបានជ្រើសរើស។ ក្រុមរង "គម្រូល្អ" នឹងបង្កើតការសម្តែងរយៈពេល ៣នាទី អំពីបទពិសោធន៍ដូចគ្នាប៉ុន្តែលើកនេះពួកគេនឹងផ្លាស់ប្តូរឈុតឆាកទៅជាអ្វីដែលពួកគាត់គិតថាជាឈុតឆាកល្អ។ នេះអាចជាឈុតឆាកដែលគ្មានអំពើរើសអើង ឬជាដំណោះស្រាយឆ្លើយតបទៅនឹងអំពើរើសអើង ឬការរំលោភសិទ្ធិមនុស្ស។ ប្រើឧទាហរណ៍ខាងក្រោមនេះ៖
    a. វគ្គសម្តែងលើកដំបូងនឹងបង្ហាញថាជេន(ឈ្មោះតួអង្គ) ត្រូវបានបញ្ឈប់ពីការងាររបស់នាង នៅពេលដែលនិយោជករបស់នាង បានដឹងថានាងត្រូវបានគេធ្វើរោគវិនិច្ឆ័យថាមានជំងឺរបេង។
    b. ការសម្តែងទីពីរនឹងបង្ហាញថានៅពេលនិយោជករបស់ជេនបានដឹងថានាងមានជំងឺរបេងហើយ និយោជករបស់នាងបានធ្វើឱ្យប្រាកដថា គ្លីនិករបស់ក្រុមហ៊ុនបានផ្តល់ថ្នាំព្យាបាលជំងឺរបេងដល់នាងដើម្បីឱ្យនាងអាចបន្តធ្វើការបាន។
4. ផ្តល់ពេល ៤៥ នាទីដល់ក្រុមនីមួយៗ ដើម្បីរៀបចំ និងអនុវត្តតួនាទីរបស់ពួកគាត់
5. ក្រុមនីមួយៗនឹងធ្វើការផ្លាស់ប្តូរបង្ហាញពីតួនាទីរបស់ពួកគាត់ម្តងមួយៗ។ ចាប់ផ្តើមជាមួយនឹងការរំលោភបំពានបន្ទាប់មក គម្រូមកពីក្រុមមួយទៀត។

## ការចូលរួមបញ្ចូលមតិ និងការពិភាក្សា (៣០ នាទី)

បន្ទាប់ពីការសម្តែងតួរត្រូវបានបញ្ចប់ ធ្វើពិភាក្សាអំពីការរំលោភបំពានណាមួយ ដែលត្រូវបានបង្ហាញក្នុងការសម្តែងតួរ និងបញ្ជាក់ឱ្យច្បាស់ថា ទាំងនេះពិតជាការរំលោភបំពាន។

1. ប្រាប់ឱ្យអ្នកចូលរួមវិលត្រឡប់ទៅកិច្ចពិភាក្សារួមវិញ។ ដឹកនាំវគ្គបំផុសគំនិត ជាមួយអ្នកចូលរួមដោយប្រើប្រាស់សំណួរណែនាំខាងក្រោមៈ
    a. តើឈុតអំពីគម្រូល្អ បានបង្ហាញនៅក្នុងការសម្តែងតួរ អាចអនុវត្តបានក្នុងជីវិតពិតឬទេ?
    b. ប្រសិនបើមអនុវត្តបានមែន តើមានអ្វីខ្លះ ដែលចាំបាច់ត្រូវមាន ដើម្បីធ្វើឱ្យសកម្មភាពដ៏ប្រសើរទាំងនេះអាចអនុវត្តទៅបាន?
    c. បើមិនដូច្នោះទេ តើអ្វីដែលរារាំងសកម្មភាពទាំងនេះ មិនឱ្យកើតឡើងក្នុងជីវិតពិត?
    d. តើអ្នកនរណាខ្លះ ដែលធ្វើឱ្យប្រាកដថា សកម្មភាពគម្រូល្អទាំងនេះអាចអនុវត្តទៅបាន?
2. ប្រើការស្លាយបង្ហាញ ដោយណែនាំនិយមន័យនៃសិទ្ធិមនុស្ស ហើយនរណាជាម្ចាស់កម្មសិទ្ធិទាំងនេះ និងនរណាជាអ្នកមានកាតព្វកិច្ច ដើម្បីបំពេញសិទ្ធិ។ អ្នកអាចប្រើព័ត៌មាននៅក្នុងទំព័របន្ទាប់ ដែលមានចំណងជើងថា *ព័ត៌មានអប្បបរស្តង់ដារសម្រាប់ផ្តល់ជាតុចូល និងពិភាក្សាអំពីជំងឺរបេង និងសិទ្ធិមនុស្ស សម្រាប់ជាឯកសារយោង( Minimum Standard Information for Input and Discussion on TB and Human Rights for reference )។*
3. ប្រាប់ឱ្យអ្នកចូលរួមវិលត្រឡប់ទៅក្រុមរបស់ពួកគេវិញ ហើយរាយឈ្មោះសិទ្ធិទាំងអស់ដែលពួកគេគិតថាត្រូវការ ដើម្បីបំពេញនូវសកម្មភាពដ៏ល្អក្នុងការសម្តែងតួរបស់ពួកគេ។ ទុកពេល ១៥ នាទីសម្រាប់សកម្មភាពនេះ។
4. ប្រាប់ឱ្យក្រុមនីមួយៗចែករំលែកនូវអ្វី ដែលពួកគាត់មាននៅក្នុងបញ្ជីរបស់ពួកគាត់។

## ការកំណត់អត្តសញ្ញាណនៃការបំពានសិទ្ធិមនុស្ស (៣០ នាទី)

មានការយល់ច្រឡំជាទូទៅអំពីអ្វីដែលជាការបំពានសិទ្ធិមនុស្ស។ ជារឿងធម្មតាទេ ដែលមនុស្សនិយាយថា អ្នកជិតខាងរបស់ពួកគេរំលោភសិទ្ធិរបស់គេ តាមរយៈផ្សព្វផ្សាយពាក្យចចាមអារ៉ាមអំពីស្ថានភាពជំងឺរបេងរបស់ពួកគេ។ ប៉ុន្តែវាមានសារៈសំខាន់ណាស់ សម្រាប់អ្នកចូលរួមក្នុងការស្វែងយល់នូវឧទាហរណ៍ទាំងនេះ ក្លាយជាការរំលោភសិទ្ធិមនុស្ស ដូច្នេះនៅពេលដែលពួកគេចាប់ផ្តើមសិក្សា នៅក្នុងការចងក្រងឯកសារសិទ្ធិមនុស្ស និងការងារតស៊ូមតិពួកគេ ហើយពួកគេ គឺមានភាពច្បាស់លាស់អំពីអ្នកនរណាគេដែលជាអ្នកទទួលខុសត្រូវ។

ជំហានៈ

1. គូសតារាងម៉ាទ្រីចមួយនៅលើក្តារខៀនដែលមានជួរឈរបី។ សរសេរនៅជួរឈរទី១"ទង្វើ" ជួរឈរទី ២ "ជនបង្ក" និងជួរឈរទី ៣ "ការទទួលខុសត្រូវរបស់រដ្ឋ" ។
2. ប្រាប់ឱ្យអ្នកចូលរួមជ្រើសរើសអំពើរើសអើងមួយដែលអ្នកចូលរួមបានកំណត់។ យកក្រដាសបិទ(post-it) ដាក់វានៅក្រោមជួរដំបូងរបស់តារាងម៉ាទ្រីច។

3. ប្រាប់ឱ្យអ្នកចូលរួមកំណត់ថា នរណាជាតួរសម្តែងដែលកំពុងរំលោភបំពាន ឬកំពុងធ្វើសកម្មភាពរំលោភបំពានទាំងនេះ។
4. ប្រាប់អ្នកចូលរួមនូវអ្វីដែលរាជរដ្ឋាភិបាលបានអនុវត្ត ឬមិនបានអនុវត្ត ដែលធ្វើឱ្យអ្នកជំងឺរបេងត្រូវបានបញ្ឈប់ពីការងារដោយសារតែស្ថានភាពរបេងរបស់ពួកគេ។ សរសេរការឆ្លើយតបទាំងនេះ នៅក្រោមជួរឈរទីបី។
5. អ្នកអាចប្រើឧទាហរណ៍នេះ៖ និយោជិកម្នាក់ត្រូវបានបញ្ឈប់ពីការងារដោយសារស្ថានភាពជំងឺរបេង (ជួរទី ១ - ទង្វើ) ។ តួរសម្តែងដែលទទួលខុសត្រូវ ក្នុងការធ្វើឱ្យរឿងនេះកើតឡើង គឺនិយោជក ឬក្រុមហ៊ុន (ជួរឈរទី ២ - ជនបង្ក) ទង្វើនេះបានកើតឡើងដោយសារតែរាជរដ្ឋាភិបាលមិនបានដាក់ចេញនូវគោលនយោបាយដែលការពារអ្នកជំងឺរបេងពីការរើសអើងនៅកន្លែងធ្វើការ (ជួរទី ៣ - ការទទួលខុសត្រូវរបស់រដ្ឋ) ។ ប្រសិនបើមានគោលការណ៍ពិតប្រាកដ ប៉ុន្តែអ្នកមានជំងឺរបេងនៅតែត្រូវបានបញ្ឈប់ពីការងារទៀតនោះ មានន័យថា រាជរដ្ឋាភិបាលបរាជ័យក្នុងការអនុវត្តគោលនយោបាយនេះ។
6. ពន្យល់ថា ថ្វីបើនិយោជកបញ្ឈប់បុគ្គលនោះពីការងារដោយសារតែគាត់មានជំងឺរបេងក៏ដោយ និយោជកមិនបានតាំងចិត្តប្រព្រឹត្តអំពើរំលោភសិទ្ធិមនុស្សទេ។ សូមរំលឹកពួកគេថា ចំពោះទង្វើរើសអើងជាការបំពានសិទ្ធិមនុស្ស ហើយរដ្ឋ ឬរដ្ឋាភិបាលត្រូវមានកាតព្វកិច្ចទទួលខុសត្រូវ ក្នុងការលើកកម្ពស់កិច្ចការពារ និងបំពេញនូវសិទ្ធិរបស់ប្រជាពលរដ្ឋ។
7. អញ្ជើញសំណួរពីអ្នកចូលរួម ហើយពិភាក្សាអំពីបញ្ហានេះបន្ថែមប្រសិនបើចាំបាច់។
8. បន្តជាមួយស្លាយបង្ហាញស្លាយរបស់អ្នកសម្របសម្រួល ដើម្បីពន្យល់ពីគោលការណ៍សិទ្ធិមនុស្ស។
9. អញ្ជើញរកសំណួរ ឬយោបល់។

*បញ្ចូលគំនូរតាមការណែនាំពីខាងលើ*

**ការកំណត់អត្តសញ្ញាណអ្នកមានកាតព្វកិច្ច (៣០ នាទី)**

1. ណែនាំអ្នកចូលរួមឱ្យត្រលប់ទៅក្រុមរបស់ពួកគេម្តងទៀត ដើម្បីធ្វើការកំណត់អត្តសញ្ញាណភាគីរាជរដ្ឋាភិបាលនានា ដែលមានការទទួលខុសត្រូវ ដើម្បីធានាថាគម្រូល្អទាំងនោះអាចក្លាយជាការពិត។ ប្រាប់អ្នកចូលរួមឱ្យសរសេរអំពីភាគីរដ្ឋាភិបាលនាន ហើយដាក់ប្រកាសទាំងនេះនៅលើក្តារខៀន។
2. បន្ទាប់ពីប្រហែល ១០-១៥ នាទី សូមអញ្ជើញក្រុមនីមួយៗចែករំលែកបញ្ជីរបស់ពួកគេ។

## ព័ត៌មានស្តង់ដារអប្បបរមាសម្រាប់ការបញ្ចូលមតិ និងការពិភាក្សាអំពីជំងឺរបេង និងសិទ្ធិមនុស្ស (សម្រាប់ជាឯកសារចែកដល់អ្នកចូលរួម ឬស្លាយបង្ហាញ)

**សិទ្ធិមនុស្ស** គឺជាសិទ្ធិពីកំណើត និងសេរីភាពដែលមនុស្សគ្រប់រូបត្រូវតែមាន និងទទួលបានដោយគុណធម៌ដែលបានកើតមកជាមនុស្ស។ ទាំងនេះ គឺជាឧបករណ៍គាំពារដែលបង្កើតឡើង ដើម្បីការពារ បុគ្គលពីអំពើហឹង្សាដោយចៃដន្យ និងការធ្វេសប្រហែសណាមួយ។

សិទ្ធិមនុស្ស គឺជាស្តង់ដារបទដ្ឋានដែលរដ្ឋត្រូវអនុវត្តដោយខ្លួនឯង នៅពេលណាមានការពាក់ព័ន្ធជាមួយពលរដ្ឋរបស់ពួកគេ។ នេះបញ្ជាក់ថា មានភាគីពីរចូលរួមក្នុងការសម្រេច និងការគោរពសិទ្ធិមនុស្ស។ ភាគីទាំងពីរ គឺអ្នកកាន់កាប់សិទ្ធិ និងអ្នកមានកាតព្វកិច្ច។ **អ្នកកាន់កាប់សិទ្ធិ ឬម្ចាស់សិទ្ធិ គឺជាពលរដ្ឋ ឬបុគ្គល ដែលពួកគេទាំងនោះមានការទទួលខុសត្រូវ ចំពោះកិច្ចការពារ ការអនុវត្ត និងការទាមទារសិទ្ធិរបស់ពួកគេ។ ម៉្យាងវិញទៀតអ្នកមានកាតព្វកិច្ច គឺជារដ្ឋ និងមនុស្សគ្រប់រូប ដែលបង្កើតជាផ្នែកមួយនៃរចនាសម្ព័ន្ធរបស់រាជរដ្ឋាភិបាល ដោយសារពួកគេទាំងអស់មានកាតព្វកិច្ចក្នុងការគោរព ការការពារ និងការបំពេញនូវសិទ្ធិមនុស្សរបស់អ្នកកាន់កាប់សិទ្ធិ។**

បញ្ជាក់កាន់តែច្បាស់ មនុស្សម្នាក់ដែលមានជំងឺរបេង គឺជាអ្នកកាន់កាប់សិទ្ធិ ខណៈដែលវេជ្ជបណ្ឌិតនៅគ្លីនិកសុខភាពសាធារណៈ ដែលគ្រប់គ្រងកន្លែងព្យាបាលដោយផ្ទាល់ (DOTS) គឺជាអ្នកមានកាតព្វកិច្ច។

តើកាតព្វកិច្ចទាំងនេះ គឺជាអ្វី?

- ការគោរព - អ្នកមានកាតព្វកិច្ច គួរចៀសវាងការជ្រៀតជ្រែក ជាមួយការពេញចិត្តនៃការទទួលបាននៃសិទ្ធិនានា។ សម្រាប់អ្នកមានជំងឺរបេង នេះមានន័យថារាជរដ្ឋាភិបាលមិនត្រូវប្រកាន់យកគោលនយោបាយ ដែលរារាំងពួកគេពីការទទួលបានសិទ្ធិរបស់ពួកគេនោះទេ ដូចជាសិទ្ធិធ្វើការងារ និងសិទ្ធិទទួលបានសេវាសុខភាព។
- ការគាំពារ - អ្នកមានកាតព្វកិច្ច គួរការពារអ្នកដទៃពីការជ្រៀតជ្រែកក្នុងការទទួលបានសិទ្ធិមនុស្ស។ សម្រាប់អ្នកមានជំងឺរបេង នេះមានន័យថារដ្ឋត្រូវប្រកាន់យកគោលនយោបាយ ដែលនឹងដាក់ទណ្ឌកម្មមនុស្សដែលរើសអើងដល់អ្នកមានជំងឺរបេង។
- ការបំពេញ - អ្នកមានកាតព្វកិច្ច គួរប្រកាន់យកវិធានការណ៍សមស្របឆ្ពោះទៅរកការសម្រេចបានពេញលេញនៃសិទ្ធិមនុស្ស។ ឧទាហរណ៍៖ រាជរដ្ឋាភិបាលត្រូវអនុម័តច្បាប់ជាតិស្តីពីរបេង ដែលអនុញ្ញាតឱ្យប្រជាពលរដ្ឋទទួលបានសិទ្ធិទទួលអប់រំ និងការពារពីការរើសអើង។

## គោលការណ៍សិទ្ធិមនុស្ស

- ការប្រកាន់ខ្ជាប់ ៖ ដោយគុណធម៌ ក្នុងនាមជាមនុស្សជាតិ យើងត្រូវមានសិទ្ធិ។ នេះមានន័យថា ចំពោះអ្នកជំងឺរបេង និងសហគមន៍ដែលរងផលប៉ះពាល់នោះ គឺមនុស្សគ្រប់រូប ទោះបីជាមានជំងឺរបេងក៏ត្រូវមានសិទ្ធិដែរ។
- ភាពជាសាកល៖ មនុស្សម្នាក់ៗមានសិទ្ធិមនុស្ស សំដៅលើសមភាព និងការមិនរើសអើង ។ នេះមានន័យថា សិទ្ធិរបស់អ្នកមានជំងឺរបេង ត្រូវតែគោរពដោយមិនគិតពីកន្លែងដែលពួកគេរស់នៅ ឬស្ថានភាពរបស់ពួកគេ។
- ភាពមិនអាចប្តូរបាន៖ សិទ្ធិមិនអាចត្រូវបានយកចេញពីមនុស្សដោយចៃដន្យឡើយ។ នេះមានន័យថា អ្នកជំងឺរបេង សូម្បីតែព្យាបាលក៏មានសិទ្ធិដែរ ហើយសិទ្ធិនោះត្រូវតែគោរពគ្រប់ពេលវេលា។ សិទ្ធិរបស់ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ដោយសារជំងឺរបេង ដូចជាអ្នកទោសត្រូវតែទទួលបានការគោរព ទោះបីជាពួកគេត្រូវបានគេឃុំខ្លួនក៏ដោយ។
- ភាពផ្តាច់មុខ៖ មាននៅក្នុងឋានានុក្រមនៃសិទ្ធិ។ នេះមានន័យថា ក្នុងការបំពេញនូវសិទ្ធិសុខភាពរបស់អ្នកជំងឺរបេង និងអ្នកដែលរងផលប៉ះពាល់ដោយសារជំងឺរបេង រដ្ឋត្រូវតែបំពេញនូវសិទ្ធិធ្វើការងារ ឬសិទ្ធិទទួលបានការអប់រំរបស់គ្រួសារ ក៏ដូចជាសេរីភាពរបស់ពួកគេពីការរើសអើងណាមួយ។
- ភាពទាក់ទងគ្នា និងការពឹងពាក់គ្នាទៅវិញទៅមក៖ សិទ្ធិមនុស្សតែមួយ មិនមិនអាចដោះស្រាយក្នុងមធ្យោបាយមួយបានឡើយ។ ស្រដៀងគ្នាទៅនឹងភាពមិនអាចបែងចែកបាន ការបំពេញសិទ្ធិមនុស្សតែមួយដោយមិនបំពេញនូវសិទ្ធិមនុស្សផ្សេងទៀត មានន័យថារដ្ឋនៅតែរំលោភសិទ្ធិទាំងនេះ។

**គណនេយ្យភាព** គឺជាគោលការណ៍សំខាន់មួយនៃសិទ្ធិមនុស្ស ដែលប្រកាន់យកដោយរដ្ឋ ដែលជាអ្នកទទួលខុសត្រូវចំពោះការគោរព និងការបំពេញនូវសិទ្ធិមនុស្ស។ នេះមានន័យថា រដ្ឋអាចទទួលខុសត្រូវចំពោះសកម្មភាព និងភាពអសកម្មភាពនានារបស់ពួកគេ ទាក់ទងនឹងកាតព្វកិច្ចរបស់ពួកគេ ទៅនឹងការទទួលបានសិទ្ធិមនុស្ស។ លើសពីនេះ វាក៏ជាកាតព្វកិច្ចរបស់រដ្ឋផងដែរ ដើម្បីធានាថាមានយន្តការ និងនីតិវិធីដែលអាចចូលដំណើរការបានប្រកបដោយប្រសិទ្ធភាព និងឯករាជ្យ សម្រាប់ការដោះស្រាយដែលអ្នកមានកាតព្វកិច្ចអាចចូលរួមបាន។ សហគមន៍របេងក៏អាចជួយឱ្យមានគណនេយ្យភាពផងដែរ ដោយតាមដានថា តើរដ្ឋកំពុងបំពេញតាមការប្តេជ្ញាចិត្តផ្អែកលើច្បាប់ និងគោលនយោបាយដែលពួកគេបានធ្វើ ឬយ៉ាងណា។

## គោលការណ៍នៃសមភាព និងការមិនរើសអើង៖

គោលការណ៍នៃសមភាព និងការមិនរើសអើង ត្រូវបានឆ្លុះបញ្ចាំងនៅក្នុងកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិមនុស្សជាមូលដ្ឋាន ដូចជាសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌។ តាមពិតឯកសារអន្តរជាតិទាំង ៣ នេះមានមាត្រា ២ ទូទៅដែលចែងថា៖

"រដ្ឋភាគី ត្រូវធានាការអនុវត្តកតិកាសញ្ញាបច្ចុប្បន្ន ដើម្បីធានាថាសិទ្ធិដែលបានចែង នឹងត្រូវបានអនុវត្តដោយគ្មានការរើសអើង លើគ្រប់ទម្រង់ដូចជា ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា នយោបាយ ឬគំនិតផ្សេងទៀត កំណើតដើម ឬសង្គម ទ្រព្យសម្បត្តិ កំណើត ឬស្ថានភាពផ្សេងទៀត" ។

## និយមន័យបន្ថែមទៀតស្តីពីការរើសអើង៖

ការរើសអើងអាចត្រូវបានបង្ហាញដោយផ្ទាល់ ឬដោយប្រយោល។

- **ការរើសអើងដោយផ្ទាល់** កើតមានឡើងនៅពេលដែលបុគ្គលម្នាក់ត្រូវបានគេ មិនសូវពេញចិត្តជាងមនុស្សម្នាក់ផ្សេងទៀតនៅក្នុងស្ថានភាពស្រដៀងគ្នា ដោយសារហេតុផលទាក់ទងនឹងការរើសអើង ពោលគឺនៅពេលសមាជិកគ្រួសាររបស់អ្នកមានជំងឺរបេង ដោយដាក់ពួកគាត់ឱ្យនៅដាច់ដោយឡែកពីគេ ហើយបែងចែកអ្វីៗទាំងអស់នៅផ្ទះសម្រាប់អ្នកជំងឺរបេងនោះ។
- **ការរើសអើងដោយប្រយោល** សំដៅទៅលើច្បាប់ គោលនយោបាយ ឬការអនុវត្តន៍ដែលមើលទៅដូចជាហាក់ដូចជាមានអព្យាក្រឹតភាព ប៉ុន្តែមានផលប៉ះពាល់មិនស្មើគ្នាលើការអនុវត្តសិទ្ធិនៃកតិកាសញ្ញា ដែលត្រូវបានសម្គាល់ដោយមូលដ្ឋាននៃការរើសអើង។ ឧទាហរណ៍៖ មានគោលនយោបាយដែលតម្រូវឱ្យនិស្សិតថ្មីទាំងអស់ត្រូវឆ្លងកាត់ការពិនិត្យសុខភាព ដែលជាផ្នែកមួយនៃការចូលរៀននៅសាកលវិទ្យាល័យ។ ទោះបីជាគោលនយោបាយនេះ មានបំណងលើកកម្ពស់ការយល់ដឹងអំពីសុខភាពក៏ដោយក៏សិស្សដែលមានជំងឺរបេង ឬធ្លាប់មានជំងឺរបេងអាចមានបទពិសោធន៍ក្នុងការរារាំង ឬបដិសេធការចូលសាលារៀនរហូតដល់ពួកគេបញ្ចប់របបព្យាបាលជាមុនសិន។

## វិធីសាស្ត្រផ្អែកលើសិទ្ធិមនុស្ស៖

វិធីសាស្ត្រផ្អែកលើសិទ្ធិមនុស្ស គឺកំណត់អត្តសញ្ញាណអ្នកកាន់កាប់សិទ្ធិ និងសិទ្ធិរបស់ពួកគេ និងអ្នកមានកាតព្វកិច្ចដែលត្រូវគ្នានឹងកាតព្វកិច្ចរបស់ពួកគេ និងធ្វើការងារឆ្ពោះទៅរកការពង្រឹងសមត្ថភាពអ្នកកាន់កាប់សិទ្ធិ ក្នុងការទាមទារ និងអ្នកមានកាតព្វកិច្ច ដើម្បីបំពេញកាតព្វកិច្ចរបស់ពួកគេ។

ផ្អែកលើ វិធីសាស្ត្រផ្អែកលើសិទ្ធិមនុស្ស ដែលបានរៀបចំឡើងដោយគម្រោងសកម្មភាពអភិវឌ្ឍន៍ របស់អង្គការសហប្រជាជាតិ ការផ្តោតលើវិធីសាស្ត្រនេះ គួរតែជាក្រុមដែលត្រូវបានការរើសអើង និងទន់ខ្សោយ។ គោលបំណងរបស់វា គឺជាសមិទ្ធិផលដែលកំពុងរីកចម្រើនផ្នែកសិទ្ធិមនុស្សទាំងអស់ ហើយវាផ្តល់នូវសារៈសំខាន់ស្មើគ្នាៗ ចំពោះលទ្ធផលក៏ដូចជាដំណើរការនៃការអភិវឌ្ឍ។

គោលដៅរបស់ វិធីសាស្ត្រផ្អែកលើសិទ្ធិមនុស្ស គឺការធ្វើឱ្យសម្រេចបាននូវសិទ្ធិមនុស្សបន្ថែមទៀត។ ដំណើរការដែលវាប្រើត្រូវបានដឹកនាំដោយស្តង់ដារ និងគោលការណ៍សិទ្ធិមនុស្ស ដូចជាសមភាព ការមិនរើសអើង ការចូលរួម និងគណនេយ្យភាព។ ហើយលទ្ធផលរបស់ វិធីសាស្ត្រផ្អែកលើសិទ្ធិមនុស្ស គួរតែជាការអភិវឌ្ឍសមត្ថភាពរបស់អ្នកកាន់កាប់សិទ្ធិ និងអ្នកមានកាតព្វកិច្ច។

វិធីសាស្ត្រផ្អែកលើសិទ្ធិមនុស្ស ចំពោះជំងឺរបេងត្រូវបានជម្រុញទៅមុខ នៅក្នុងយុទ្ធសាស្ត្រណៃរ៉ូប៊ីស្តី (Nairobi Strategy )ពីជំងឺរបេង និងសិទ្ធិមនុស្ស និងសេចក្តីប្រកាសអំពីសិទ្ធិរបស់មនុស្សដែលរងផលប៉ះពាល់ដោយជំងឺរបេង។ ចំពោះអ្នកជាប់ពន្ធធនាគារ និងជនអន្តោប្រវេសន៍ វាត្រូវបានគេស្វែងយល់លម្អិតបន្ថែមទៀត។ សេចក្តីផ្តើមនៃគំនិតរបស់ វិធីសាស្ត្រផ្អែកលើសិទ្ធិមនុស្ស មិនមែនជារឿងថ្មីចំពោះជំងឺរបេងនោះទេ ប៉ុន្តែវាទាមទារឱ្យមានការខិតខំប្រឹងប្រែងដើម្បីឱ្យវាអាចដំណើរការបានទូទាំងកម្មវិធីជាតិកំចាត់របេងផងដែរ។

នៅក្នុងឆ្នាំ ២០១៨ រដ្ឋជាសមាជិករបស់អង្គការសហប្រជាជាតិ បានធ្វើការប្តេជ្ញាចិត្តមួយចំនួន ហើយការប្តេជ្ញាចិត្តទាំងនោះ ត្រូវបានចែងនៅក្នុងសេចក្តីប្រកាសនយោបាយស្តីពីការប្រយុទ្ធប្រឆាំងនឹងជំងឺរបេង។ ការប្តេជ្ញាចិត្តទាំងនេះរួមមានគោលបំណង ដើម្បីព្យាបាលអ្នកជំងឺរបេង ៤០លាននាក់ នៅឆ្នាំ ២០២២ ដោយជោគជ័យ ការព្យាបាលកុមារដែលមានជំងឺរបេងចំនួន ៣.៥ លាននាក់នៅត្រឹមឆ្នាំ ២០២២ អនុវត្តរបេងបង្ការរួមទាំងអ្នកផ្ទុកមេរោគអេដស៍ចំនួន ៦លាននាក់នៅឆ្នាំ ២០២២ ប្តេជ្ញាប្រមូលគៀងគរថវិកាយ៉ាងតិច ១៣ពាន់លានដុល្លារ ក្នុងមួយឆ្នាំរហូតដល់ឆ្នាំ ២០២២ ដើម្បីធ្វើឱ្យមាននិរន្តភាពថវិកាសម្រាប់ការឆ្លើយតបជំងឺរបេងក៏ដូចជា ២ពាន់លានដុល្លារ សម្រាប់ការងារលើផ្នែកស្រាវជ្រាវ និងការអភិវឌ្ឍ។

សម្រាប់អត្ថបទដើម អាចស្វែងរកបានតាមរយៈតំណភ្ជាប់នេះ (https://www.un.org/pga/72/wp-content/uploads/sites/51/2018/09/Co-facilitators-Revised-text-Political-Declaraion-on-the-Fight-against-Tuberculosis.pdf )

ខណៈពេលដែល អង្គការ Stop TB Partnership បានសង្ខេបការប្តេជ្ញាចិត្តទាំងនេះទៅជាឯកសារងាយស្រួលអានដែលអាចចូលមើលបាននៅទីនេះ៖

http://www.stoptb.org/assets/documents/global/advocacy/unhlm/UNHLM_Targets&Commitments.pdf

## សរុបសេចក្តី:

1. យើងទាំងអស់គ្នា រួមទាំងអ្នកដែលមានជំងឺរបេង ឬអ្នកដែលរងផលប៉ះពាល់ដោយសារជំងឺរបេងទាំងអស់សុទ្ធតែមានសិទ្ធិមនុស្សស្មើៗគ្នា។
2. សុខភាពក៏ជាសិទ្ធិមួយរបស់មនុស្សដែរ។ នេះរួមបញ្ចូលទាំងសិទ្ធិក្នុងការទទួលបានសេវាថែទាំសុខភាព ដែលមានគុណភាព ព័ត៌មានសុខភាព សិទ្ធិក្នុងការព្យាបាល និងសិទ្ធិមិនមានការមាក់ងាយ និងការរើសអើងដោយសារស្ថានភាពសុខភាព ក្នុងចំណោមអ្នកដទៃទៀត។
3. ក្របខណ្ឌសិទ្ធិមនុស្សផ្តល់នូវក្របខណ្ឌសម្រាប់ដោះស្រាយបញ្ហានៅក្នុងជំងឺរបេង។
4. ការរើសអើងដោយផ្អែកលើការឆ្លងជំងឺរបេង គឺជាការរំលោភសិទ្ធិមនុស្ស ប្រសិនបើនេះ ជាសកម្មភាពរបស់រដ្ឋ ឬតួអង្គរដ្ឋ ឬប្រសិនបើរដ្ឋ មិនមានវិធានការណ៍ណាមួយ ដើម្បីការពារសិទ្ធិរបស់អ្នកដែលមានជំងឺរបេង។

អានបន្ថែម៖

វិទ្យាស្ថានអូនីល (O'Neill Institute) ឆ្នាំ ២០១៨ ការធ្វើចំណាកស្រុកជំងឺរបេង និងច្បាប់៖ តម្រូវការបន្ទាន់សម្រាប់វិធីសាស្ត្រផ្អែកលើសិទ្ធិ។ https://oneill.law.georgetown.edu/media/Migration-Tuberculosis-and-the-Law-An-Urgent-Need-for-a-Rights-Based-Approach.pdf

អង្គការ Treatment Action Group ឆ្នាំ ២០១៩ ដឹងពីសិទ្ធិរបស់អ្នក៖ ការការពារជំងឺរបេង ការណែនាំ និងការព្យាបាល។

http://www.treatmentactiongroup.org/sites/default/files/know_your_rights_english_aug_19_final.pdf

វិទ្យាស្ថានអូនីល ឆ្នាំ ២០១៩ ជំងឺរបេងនៅក្នុងពន្ធនាគារ៖ សេចក្តីណែនាំរបស់ប្រជាពលរដ្ឋចំពោះច្បាប់។ https://oneill.law.georgetown.edu/media/TB-in-Prisons-Web.pdf

## ច. ការគៀងគរសហគមន៍រងផលប៉ះពាល់ដោយសារជំងឺរបេង ដើម្បីចងក្រងឯកសារអំពីសិទ្ធិមនុស្ស

គោលបំណង៖ កសាងសមត្ថភាពរបស់អ្នកចូលរួមក្នុងការចងក្រងឯកសារអំពីការរំលោភសិទ្ធិមនុស្ស នៅក្នុងបរិបទជំងឺរបេង។

ពេលវេលា៖ ៣ ម៉ោង ៣០ នាទី

សកម្មភាព៖

1. ការពិភាក្សា ឬស្លាយបង្ហាញ
2. សម្ភាសន៍សាកល្បង
3. ការបញ្ចូលមតិ និងពិភាក្សា

សម្ភារៈ៖

1. ក្រដាសផ្ទាំងសធំ
2. ប៊ិចហ្វឺត
3. ស្កុត
4. ក្រដាសបិត (Post-Its) ឬក្រដាសពណ៌ដែលមានទំហំប្រហាក់ប្រហែលគ្នា
5. ឧបករណ៍ចងក្រងឯកសារគម្រូ
6. កុំព្យូទ័រ និងម៉ាស៊ីនបញ្ចាំង

**ជំហាន៖**

សម្រាប់គោលបំណងនៃវគ្គបណ្តុះបណ្តាលនេះ ជាការល្អបំផុត ដែលគួរផ្តល់ឱ្យអ្នកចូលរួមនូវឧបករណ៍ចងក្រងឯកសារសាមញ្ញមួយ ដែលអាចជួយពួកគេកត់ត្រានូវបទពិសោធន៍ផ្ទាល់ខ្លួន អំពីការរំលោភសិទ្ធិមនុស្ស ឬអ្នកដែលជួបប្រទះដោយមិត្តភក្តិអ្នកជិតខាង ឬសមាជិកគ្រួសារផ្សេងទៀតរបស់ពួកគាត់។ មានព័ត៌មានដូចខាងក្រោម នៅក្នុងឧបករណ៍ចងក្រងឯកសារជាអប្បបរមា។ អ្នកក៏អាចប្រើគម្រូនៅក្នុងឧបសម្ព័ន្ធទី២ សម្រាប់ជាឯកសារយោងនេះដែរ។

I. ព័ត៌មានផ្ទាល់ខ្លួន

1. ឈ្មោះបុគ្គលដែលបានជួបប្រទះការរំលោភបំពាននេះ
2. ទីលំនៅ
3. អាយុ
4. អត្តសញ្ញាណយេនឌ័រ

5. ស្ថានភាពអាពាហ៍ពិពាហ៍/ស៊ីវិល
6. ចំនួនអ្នកអាស្រ័យក្រោមការគ្រប់គ្រង
7. កម្រិតអប់រំ
8. ប្រភពចំណូល
9. ប្រាក់ចំណូលប្រចាំខែ គិតជាមធ្យម

របាយការណ៍អាំងស៊ីដង់ (ភាពរងគ្រោះ)

1. កាលបរិច្ឆេទនិងពេលវេលានៃឧប្បត្តិហេតុ
2. ទីកន្លែងដែលឧប្បត្តិហេតុកើតឡើង
3. តើអ្នកណាដែលបានប្រព្រឹត្តការបំពាន
4. តើមានអ្វីកើតឡើង (និទានកថានៃឧប្បត្តិហេតុ

## សម្ភាសន៍សាកល្បង (៩០ នាទី)

(បញ្ចូលគំនូរនៅទីនេះ)

អ្នកចូលរួមមិនត្រូវបានគេរំពឹងថានឹងរៀនពីរបៀបធ្វើជាអ្នកជំនាញក្នុងការស្រាវជ្រាវ ក្នុងវគ្គបណ្តុះបណ្តាលនេះទេ។ យ៉ាងហោចណាស់ ពួកគេអាចរៀនពីរបៀបប្រើប្រាស់ឧបករណ៍ចងក្រងឯកសារ ដើម្បីលើកទឹកចិត្តឱ្យប្រែក្លាយជាទម្លាប់ក្នុងការកត់ត្រាបទពិសោធន៍របស់ពួកគេ ឬបទពិសោធន៍របស់មិត្តភក្តិ នៅពេលកំពុងដោះស្រាយជាមួយបញ្ហាជំងឺរបេង។ វាជាការសំខាន់ណាស់ ដើម្បីបញ្ជាក់ថាបទពិសោធន៍ដែលពួកគេកំពុងកត់ត្រា អាចត្រូវបានប្រើប្រាស់ ដើម្បីជូនដំណឹងអំពីអន្តរាគមន៍ផ្សេងទៀតដែលពួកគេបានស្នើនៅក្នុងសកម្មភាពមុនៗ - ការតស៊ូមតិជាពិសេស។

លំហាត់សម្ភាសន៍សាកល្បងនឹងបង្រៀនអ្នកចូលរួមពីរបៀបប្រើឧបករណ៍រៀបចំឯកសារ និងរបៀបសួរសំណួរឱ្យបានត្រឹមត្រូវ។

1. បែងចែកអ្នកចូលរួមជាគូក្រុមដោយស្ម័គ្រចិត្ត ។ គូនីមួយៗនឹងធ្វើការសម្ភាសន៍គ្នាទៅវិញទៅមក។
2. ផ្តល់ឧបករណ៍ចងក្រងឯកសារដែលអ្នកបានរៀបចំមុនពេលវគ្គបណ្តុះបណ្តាល។
3. ពន្យល់ណែនាំអ្នកចូលរួមអំពីឧបករណ៍។ អនុញ្ញាតឱ្យពួកគេស្គាល់ច្បាស់អំពីព័ត៌មានដែលត្រូវការ ដើម្បីទទួលបានពីការសម្ភាសន៍ ដែលពួកគេនឹងធ្វើ។ ស្នើឱ្យមានសំណួរ និងការបកស្រាយ។
4. បន្ទាប់ពីចំណាយពេលប្រហែល ១០នាទី ដើម្បីពន្យល់ពីឧបករណ៍ សូមប្រាប់អ្នកចូលរួមឱ្យគិត អំពីទង្វើរើសអើង ឬការរំលោភបំពានដែលពួកគាត់ជួបប្រទះ ឬស្គាល់។ នេះអាចផ្អែកលើសំបុត្រ។ ពួកគេនឹងនិយាយអំពីរឿងនេះនៅក្នុងបទសម្ភាសន៍។

5. ណែនាំគូនីមួយៗឱ្យយកកៅអីរបស់ពួកគេ ហើយរកកន្លែងនៅក្នុងបន្ទប់ដែលនឹងធ្វើលំហាត់។
6. សម្រាប់គូនីមួយៗ សូមឱ្យអ្នកចូលរួមសម្រេចចិត្តថាអ្នកណានឹងជាអ្នកសំភាសន៍ និងអ្នកណានឹងត្រូវគេសម្ភាសន៍។ បន្ទាប់មកអ្នកសំភាសន៍នឹងប្រើឧបករណ៍ ដើម្បីកត់ត្រានៃកិច្ចសម្ភាសន៍នោះ។ អនុញ្ញាតឱ្យពួកគេកត់ត្រាសម្ភាសន៍ របស់ពួកគេនៅលើឧបករណ៍ឯកសារ។
7. ផ្តល់ឱ្យអ្នកចូលរួម ១៥នាទី សម្រាប់ការសំភាសន៍ជុំទីមួយ។ បន្ទាប់ពី ១៥នាទី ប្រាប់អ្នកចូលរួមឱ្យផ្លាស់ប្តូរតួនាទី ហើយផ្តល់ពេល ១៥នាទីទៀត សម្រាប់សម្ភាសន៍ជុំទី២។
8. ផ្តល់ឱ្យអ្នកចូលរួម១០នាទី បន្ទាប់ពីការសម្ភាសន៍ ដើម្បីបញ្ចប់ការកត់ត្រារបស់ពួកគេ នៅលើឧបករណ៍ចងក្រងឯកសារ។
9. ប្រមូលផ្តុំអ្នកចូលរួម ហើយពិភាក្សាដូចតទៅ៖
    a. តើបទពិសោធន៍របស់អ្នកក្នុងការសម្ភាសន៍យ៉ាងដូចម្តេចដែរ?
    b. តើអ្នកចូលចិត្តអ្វីអំពីបទពិសោធន៍នោះ?
    c. តើអ្វីជាឧបសគ្គសម្រាប់អ្នក?
    d. តើអ្នកដោះស្រាយឧបសគ្គទាំងនោះ ក្នុងកិច្ចសម្ភាសន៍ដោយរបៀបណា?
    e. តើអ្នកត្រូវការអ្វីទៀត ដើម្បីអាចចងក្រងឯកសារអំពីការរំលោភបំពាន ដែលសហគមន៍ជួបប្រទះដោយជំងឺរបេង?
10. កត់ចំណាំចម្លើយរបស់អ្នកចូលរួម។ អ្នកសម្របសម្រួលអាចប្រើវា ដើម្បីកែលម្អឧបករណ៍ចងក្រងឯកសារ ឬផែនការសម្រាប់សកម្មភាពពង្រឹងជំនាញបន្តទៀត។
11. ប្រាប់អ្នកចូលរួម បើសិនជាមានបញ្ហានានា ដែលត្រូវបានលើកឡើងនៅក្នុងបទសម្ភាសន៍សាកល្បង ដែលត្រូវការយកចិត្តទុកដាក់ភ្លាមៗ។ ប្រសិនបើមាន ប្រាប់អ្នកចូលរួម ឱ្យជួបជាមួយក្រុមបណ្តុះបណ្តាលបន្ទាប់ពីចប់វគ្គ ដើម្បីពិភាក្សាអំពីបញ្ហានេះ។
12. ជាជម្រើស អ្នកចូលរួមអាចត្រូវបានបែងចែកជាបីក្រុម ដោយអាស្រ័យទៅលើចំនួនអ្នកចូលរួមសរុប នៅក្នុងវគ្គបណ្តុះបណ្តាល។ ជាមួយនឹងការរៀបចំនេះ បុគ្គលទីបីនឹងដើរតួជាអ្នកសង្កេតការណ៍ ខណៈដែលពីរនាក់ទៀតកំពុងធ្វើការសម្ភាសន៍សាល្បង។ ទាំងបីអ្នកនឹងនៅតែធ្វើការផ្លាស់ប្តូរគ្នាក្នុងការធ្វើជា អ្នកសម្របសម្រួល អ្នកសម្ភាសន៍ និងអ្នកសង្កេតការណ៍។ ជម្រើសនេះនឹងចំណាយពេលច្រើន ដើម្បីអនុញ្ញាតឱ្យអ្នកចូលរួមទាំងអស់ឆ្លងកាត់ការធ្វើលំហាត់។

**ព័ត៌មានស្តង់ដារអប្បបរមាសម្រាប់បញ្ចូលមតិ និងពិភាក្សាលើការចងក្រងឯកសារបញ្ហាសិទ្ធិមនុស្សនៅក្នុងបរិបទរបេង**
(សម្រាប់ការផ្តល់ជូន ឬបទបង្ហាញ Powerpoint)

ការចងក្រងឯកសារអំពីការរំលោភសិទ្ធិមនុស្ស គឺជាមធ្យោបាយដ៏ល្អមួយក្នុងការប្រមូលភស្តុតាងដែលអាចប្រើសម្រាប់ការតស៊ូមតិរបស់សហគមន៍ ដើម្បីនាំមកនូវការផ្លាស់ប្តូរដែលផ្តល់ផលប្រយោជន៍ដល់អ្នកដែលរងផលប៉ះពាល់ដោយបញ្ហាមួយចំនួន ក្នុងករណីនេះ ជាការរំលោភសិទ្ធិទាក់ទងនឹងជំងឺរបេង។ ដំណើរការនៃការចងក្រងឯកសារបទពិសោធន៍របស់សហគមន៍ដោយសហគមន៍ ក៏អាចមានសេរីភាព និងផ្តល់សិទ្ធិអំណាចដល់អ្នកដែលចែករំលែកបទពិសោធន៍របស់ពួកគេ និងអ្នកដែលកំពុងចងក្រងឯកសារផងដែរ។

ក្នុងការចងក្រងឯកសារអំពីការរំលោភបំពាន ដែលសហគមន៍បានជួបប្រទះ យើងត្រូវមានការណែនាំដូចខាងក្រោម៖

1. <u>កំណត់គោលបំណង៖</u> សូមឆ្លើយសំណួរដូចជា" ហេតុអ្វី បានជាយើងកត់ត្រាបទពិសោធន៍ទាំងនេះ?" ដើម្បីធានាថា មានហេតុផលច្បាស់លាស់ក្នុងការចងក្រងឯកសារព័ត៌មានទាំងនេះ ព្រមទាំងយល់ដឹងពីអត្ថប្រយោជន៍របស់វា។
2. <u>កំណត់ចំណុចផ្តោត និងវិសាលភាពនៃការចងក្រងឯកសារក៏មានសំខាន់ផងដែរ៖</u> នេះមានន័យថា បុគ្គលដែលប្រមូលការព័ត៌មាន ត្រូវមានភាពច្បាស់លាស់ទាក់ទងនឹងកម្រិត និងភាពស៊ីជម្រៅដែលនឹងត្រូវការចងក្រង។
3. <u>កំណត់ពីរបៀបដែលនឹងត្រូវប្រមូល៖</u> សមាជិកសហគមន៍ខ្លះ ប្រហែលជាមិនចូលចិត្តចែករំលែកអត្តសញ្ញាណរបស់ពួកគេទេ ដោយសារតែការភ័យខ្លាច ឬថប់បារម្ភ។ ក្នុងករណីនេះ អ្នកចងក្រងឯកសារត្រូវតែដឹងពីវិសាលភាពនៃការលួងលោមចិត្តរបស់បុគ្គល ដែលនឹងត្រូវចែករំលែកបទពិសោធន៍របស់ពួកគេ។ អ្នកចងក្រងឯកសារក៏ត្រូវធានាថា ត្រូវផ្តល់កន្លែងមានសុវត្ថិភាព ដល់អ្នកដែលត្រូវបានសម្ភាស ដើម្បីកាត់បន្ថយការព្រួយបារម្ភរបស់គេ។ នេះអាចទាក់ទងនឹងការសម្ភាសន៍នៅក្នុងគេហដ្ឋានរបស់អ្នកដែលត្រូវបានសម្ភាសន៍ ឬការភ្ជាប់អ្នកដែលត្រូវសម្ភាសន៍ទៅអ្នកផ្តល់សេវាសុខភាព បន្ទាប់ពីការសម្ភាសន៍ ក្នុងករណីដែលពួកគេប្រហែលជាត្រូវការការគាំទ្រខ្លះ។

នៅក្នុងការចងក្រងឯកសារ សំណុំព័ត៌មានមូលដ្ឋានបំផុត ដែលនឹងត្រូវប្រមូលគួរតែឆ្លើយតបនឹងចំណុចខាងក្រោម៖

1. នរណា៖ តើអ្នកណាជាជនរងគ្រោះ? តើអ្នកណាជាជនល្មើស?
2. អ្វី៖ តើអ្វីទៅជាការរំលោភបំពានសិទ្ធិមនុស្សដែលបានជួបប្រទះ? តើការបំពានទាំងនេះមានឥទ្ធិពលអ្វីខ្លះ?
3. កន្លែងណា៖ តើហេតុការណ៍បានកើតឡើងនៅឯណា?
4. ពេលណា៖ តើហេតុការណ៍កើតឡើងនៅពេលណា (កាលបរិច្ឆេទ និងពេលវេលា)?

5. របៀបណា៖ តើហេតុការណ៍បានកើតឡើងយ៉ាងដូចម្តេច? (ពិពណ៌នាអំពីព្រឹត្តិការណ៍ដែលបានកើតឡើង ដែលនាំឱ្យមានការរំលោភសិទ្ធិមនុស្សក៏ដូចជាលទ្ធផល)

ការមានទម្រង់នៃឧបករណ៍ចងក្រងឯកសារមានសារៈប្រយោជន៍ណាស់ សម្រាប់សហគមន៍ ក្នុងការចាប់ផ្តើមចងក្រងឯកសារនូវបទពិសោធន៍ទាំងនោះ អំពីការរំលោភសិទ្ធិមនុស្សទាក់ទងនឹងជំងឺរបេង។ សូមមើលឧបសម្ព័ន្ធទី២ សម្រាប់ឧទាហរណ៍នៃឧបករណ៍ចងក្រងឯកសារ។

## គោលការណ៍ ដើម្បីណែនាំដំណើរការនៃការចងក្រងឯកសារការរំលោភសិទ្ធិមនុស្ស

នៅក្នុងការចងក្រងឯកសារស្តីពីសិទ្ធិមនុស្ស វាមានសារៈសំខាន់ណាស់សម្រាប់អ្នកចងក្រងឯកសារ ឬអ្នកសម្ភាសក្នុងការរក្សា និងអនុវត្តគោលការណ៍មួយចំនួន ដើម្បីធានាបាននូវព័ត៌មានជាក់លាក់អំពីហេតុការណ៍នេះ។ ទាំងនេះ គឺជាគោលការណ៍មួយចំនួន ដែលនឹងត្រូវសង្កេត ក្នុងកំឡុងពេលដំណើរការចងក្រងឯកសារ៖

1. <u>មិនលំអៀង:</u> វាមានសារៈសំខាន់ណាស់ ដែលមានគោលបំណងជាក់លាក់ នៅពេលចងក្រងឯកសារអំពីការរំលោភសិទ្ធិមនុស្ស។ ត្រូវប្រកាន់ខ្ជាប់នូវព័ត៌មាន និងព្រឹត្តិការណ៍ជាក់ស្តែង ដែលត្រូវបានចែករំលែកដោយសហគមន៍។ ស៊ើបអង្កេតបន្ថែមប្រសិនបើចាំបាច់ ប៉ុន្តែត្រូវប្រកាន់យកការពិត (ឧទាហរណ៍៖ បន្ទាប់ពីសំណុំសំណួរដែលបានរៀបរាប់ខាងលើ)។
2. <u>ភាពត្រឹមត្រូវ:</u> ដូចសកម្មភាពប្រមូលទិន្នន័យផ្សេងទៀតដែរ វាមានសារៈសំខាន់ណាស់ ដើម្បីធានាថាព័ត៌មានដែលប្រមូលបានមានភាពជាក់លាស់ ឬត្រឹមត្រូវ។ ការកេងបន្លំការពិត ឬរាយការណ៍ព័ត៌មានមិនពិត អាចនាំឱ្យបាត់បង់សុចរិតភាព និងភាពជឿជាក់ នៃដំណើរការចងក្រងឯកសារ ព្រមទាំងការតស៊ូមតិ ដែលនឹងត្រូវធ្វើបន្ទាប់ពីនោះ។ ប្រសិនបើ អ្នកសម្ភាសន៍មានការពិបាកក្នុងរំលឹកឡើងវិញ ឬពិបាកក្នុងការចងចាំព័ត៌មានលម្អិត សូមចងក្រងជាឯកសារទាំងនោះ ឬត្រលប់មកអ្នកសម្ភាសន៍វិញ ប្រសិនបើចាំបាច់។
3. <u>ភាពជាក់លាក់:</u> ជាចាំបាច់ក្នុងការធ្វើឱ្យប្រាកដថា ការចងក្រងឯកសារនៃបទពិសោធន៍ ដែលមានលក្ខណៈលម្អិតតាមដែលអាចធ្វើបាន។ ព័ត៌មានលម្អិតអាចជួយក្នុងការធ្វើឱ្យលទ្ធផលនៃការចងក្រងឯកសារ កាន់តែទាក់ទាញ និងជឿជាក់។ ខណៈពេលដែល ឧបករណ៍ចងក្រងឯកសារមួយចំនួន ដូចមានចែងក្នុងសៀវភៅណែនាំនេះ អាចមានលក្ខណៈស្តើង នោះអ្នកសម្ភាសន៍មានសេរីភាពក្នុងការបន្ថែមសម្លឹកសម្រាប់ការចងក្រងឯកសារនេះ។ អ្នកសម្ភាសន៍អាចភ្ជាប់រូបថត និងវត្ថុអនុស្សាវរីយ៍ផ្សេងទៀតផងដែរ ប្រសិនបើមានប្រយោជន៍។

ការពិចារណាអំពីក្រមសីលធម៌ មានសារៈសំខាន់ផងដែរដូចជា ការធានានូវភាពត្រឹមត្រូវនៃព័ត៌មានដែលត្រូវបានប្រមូល តាមរយៈការចងក្រងឯកសារសិទ្ធិមនុស្ស។ នៅពេលមានគម្រោងចងក្រងឯកសារសិទ្ធិមនុស្សទាក់ទងនឹងជំងឺរបេង សូមធានាចំណុចខាងក្រោម៖

1. ការបញ្ជាក់ការយល់ព្រម: មុនពេលចាប់ផ្ដើមកិច្ចសម្ភាសន៍ អ្នកត្រូវប្រាកដថា អ្នកបានពន្យល់ព័ត៌មានចាំបាច់ទាំងអស់ ដូចជាអ្នកនរណា តើអ្នកតំណាងឱ្យនរណា និងគោលបំណងនៃការសម្ភាសន៍ជាដើម ដែលនឹងអនុញ្ញាតឱ្យមនុស្សដែលត្រូវសម្ភាសន៍ ផ្ដល់ការយល់ព្រមក្នុងកិច្ចសម្ភាសន៍។ អ្នកអាចបង្កើតទម្រង់យល់ព្រម ដែលអ្នកសម្ភាសន៍ និងអ្នកត្រូវបានសម្ភាសន៍ នឹងចុះហត្ថលេខាមុនពេលចាប់ផ្ដើម។ ក្នុងទម្រង់យល់ព្រមនឹងរួមបញ្ចូលព័ត៌មានចាំបាច់ដូចជា ឈ្មោះបុគ្គល/ស្ថាប័នដែលកំពុងធ្វើការសម្ភាសន៍ គោលបំណងសម្ភាសន៍ និងរបៀបប្រើប្រាស់ព័ត៌មានដែលប្រមូល។ ទម្រង់យល់ព្រម ក៏បង្ហាញពីសិទ្ធិរបស់បុគ្គល ដែលត្រូវបានសម្ភាសន៍ ដូចជា ការការពារព័ត៌មានផ្ទាល់ខ្លួន សិទ្ធិក្នុងការដកខ្លួនចេញពីដំណើរការសម្ភាសន៍ និងសិទ្ធិក្នុងការពិនិត្យឡើងវិញនូវលទ្ធផលរបស់កិច្ចសម្ភាសន៍។ ទម្រង់នេះគួរតែរួមបញ្ចូលនូវវិធានការណ៍ ដែលអ្នកសម្ភាសន៍នឹងចាត់វិធានការណ៍ ដើម្បីការពារទិន្នន័យដែលបានមកពីអ្នកត្រូវបានសម្ភាសន៍ ក៏ដូចជាការទទួលខុសត្រូវរបស់អ្នកសម្ភាសន៍ ឬស្ថាប័នដែលកំពុងសិក្សា ដើម្បីប្រើប្រាស់ទិន្នន័យ សម្រាប់គោលបំណងដែលមានចែងក្នុងទម្រង់យល់ព្រម។ គម្រូនៃទម្រង់យល់ព្រមអាចស្វែងរកបាននៅឧបសម្ព័ន្ធ៣ ។
2. ភាពឯកជន និងការសម្ងាត់: អ្នកត្រូវធានាថា ដំណើរការនៃការចងក្រងឯកសារសិទ្ធិមនុស្សនេះ មិនបាននាំឱ្យមានការរំលោភលើសិទ្ធិឯកជនភាពរបស់បុគ្គលដែលអ្នកសម្ភាសន៍នោះទេ។ អ្នកត្រូវពន្យល់ទៅកាន់អ្នកត្រូវបានសម្ភាសន៍ ថាអ្នកនឹងចាត់វិធានការណ៍ចាំបាច់ទាំងអស់ ដើម្បីរក្សាការសម្ងាត់នៃព័ត៌មានកំពុងប្រមូល។
3. ស្វ័យភាពរបស់អ្នកសម្ភាស: សូមចងចាំពីការពិតដែលថា បុគ្គលដែលយើងចង់សម្ភាសន៍មានស្វ័យភាពពេញលេញលើកម្រិតនៃការចូលរួម ដែលពួកគេចង់មាននៅក្នុងដំណើរការចងក្រងឯកសារ និងសកម្មភាពនានាដែលនឹងក្លាយជាលទ្ធផល។ អ្នកដែលត្រូវបានសម្ភាសន៍ មានសិទ្ធិដកខ្លួនចេញ ពីដំណើរការនៅពេលណាក៏បាន ប្រសិនបើ គាត់ផ្លាស់ប្ដូរចិត្ត ហើយអ្នកត្រូវតែគោរពការសម្រេចចិត្តមួយនោះ។
4. សំណង: នេះអាស្រ័យលើបរិបទ និងធនធានដែលមាន។ ប៉ុន្តែអ្វីដែលសំខាន់ ដែលត្រូវពិចារណានោះ គឺថាអ្នកកំពុងតែប្រើប្រាស់ពេលវេលារបស់អ្នកត្រូវបានសម្ភាសន៍ ហើយអ្នកកំពុងតែស្នើសុំឱ្យពួកគេ រំលឹកនូវបទពិសោធន៍ឈឺចាប់មួយចំនួនដែលពួកគេអាចមាន។ នៅក្នុងការដោះដូរនេះ ជាការអនុវត្តល្អក្នុងការផ្ដល់អ្វីមួយដល់អ្នកត្រូវបានសម្ភាសន៍ត្រឡប់ទៅវិញ។ នេះមិនចាំបាច់ជារូបិយវត្ថុទេ។ អ្នកក៏មិនចង់បានការចោទប្រកាន់ពីបទសូកប៉ាន់ដល់អ្នកត្រូវបានសម្ភាសន៍ផងដែរ។ អាហារសម្រន់ ឬប្រាក់ឧបត្ថម្ភសម្រាប់ការធ្វើដំណើរអាចជាសំណងសមរម្យ។

## គន្លឹះក្នុងការសម្ភាសន៍

ទាំងនេះ គឺជាគន្លឹះខ្លះៗ ដែលអាចមានប្រយោជន៍នៅពេលអ្នកធ្វើកិច្ចសម្ភាសន៍៖

1. បង្កើតទំនាក់ទំនងជាមួយអ្នកត្រូវបានសម្ភាសន៍។ ជម្រាបសួរពួកគេ ។ ណែនាំខ្លួនរបស់អ្នក។ សួរពួកគេ ថាតើពួកគេសុខសប្បាយទេ។

2. ពន្យល់ពីគោលបំណង និងដំណើរការសកម្មភាពចងក្រងឯកសាររបស់អ្នក។ នេះក៏អាចជាពេលដែលអ្នកណែនាំទម្រង់ការបញ្ជាក់ការយល់ព្រម សម្រាប់ហត្ថលេខារបស់អ្នកចូលរួមសម្ភាសន៍។
3. សួរសំណួររបស់អ្នកឱ្យច្បាស់ ម្តងមួយៗ។ ជៀសវាងការបំភ័យអ្នកត្រូវបានសម្ភាសន៍ជាមួយសំណួរជាបន្តបន្ទាប់ក្នុងពេលតែមួយ។
4. ត្រូវយកចិត្តទុកដាក់ និងប្រុងប្រយ័ត្នចំពោះការប្រាស្រ័យទាក់ទងមិនមែនពាក្យសម្តីៈ អ្នក និងអ្នកត្រូវបានសម្ភាសន៍របស់អ្នក។ ពេលខ្លះសកម្មភាពនិយាយខ្លាំង ជាងពាក្យ។
5. នៅពេលជាក់លាក់ណាមួយ ក្នុងកំឡុងពេលសម្ភាសន៍ និងជាពិសេសនៅចុងបញ្ចប់ សូមសរសេរឡើងវិញ និង/ឬសង្ខេបការឆ្លើយតបរបស់អ្នកត្រូវបានសម្ភាសន៍ ដើម្បីធ្វើឱ្យពួកគេមានសុពលភាព។
6. កុំភ្លេចនិយាយអរគុណ ដល់អ្នកត្រូវបានសម្ភាសន៍ ក្រោយបញ្ចប់។ ស្នើសុំព័ត៌ឱ្យមានទំនាក់ទំនង ក្នុងករណីអ្នកត្រូវម្តងទៀត។
7. ប្រសិនបើចាំបាច់ សូមពន្យល់ពីដំណើរការនៃការបញ្ជូនព័ត៌មាន ទៅកាន់អ្នកផ្តល់សេវាកម្ម។

*សារស្នូល*

1. ការចងក្រងឯកសារអំពីការរំលោភសិទ្ធិមនុស្សដែលទាក់ទងនឹងជំងឺរបេង ជាមូលដ្ឋានគ្រឹះសម្រាប់ការបង្កើតការឆ្លើយតបដោយផ្អែកលើសិទ្ធិមនុស្ស ចំពោះការឆ្លើយតបនឹងជំងឺរបេង។
2. សហគមន៍មានកន្លែងដ៏ល្អបំផុត សម្រាប់ការចងក្រងឯកសារទាក់ទងនឹងជំងឺរបេង។
3. ការចងក្រងឯកសារស្តីពីសិទ្ធិមនុស្សទាក់ទងនឹងជំងឺរបេង គួរតែត្រូវបានដឹកនាំដោយគោលការណ៍សីលធម៌ និងមូលដ្ឋានសិទ្ធិ។

សម្រាប់អ្នកដែលមានស្មាតហ្វូន អ្នកអាចណែនាំឱ្យពួកគេទាញយកកម្មវិធី https://stoptbpartnershiponeimpact.org/ ដោយកម្មវិធីនេះ ផ្តល់នូវឧទាហរណ៍អំពីរបៀបដែលបញ្ហាទាក់ទងនឹងសិទ្ធិមនុស្សមួយចំនួន ត្រូវបានត្រួតពិនិត្យ និងកត់ត្រានៅក្នុងប្រទេសមួយចំនួនដូចជានៅកម្ពុជា និងឥណ្ឌូនេស៊ី។

## ឆ. ការតម្រង់ទិសលើការតស៊ូមតិ

គោលបំណងៈ ដើម្បីពង្រឹងសមត្ថភាពអ្នកចូលរួម ក្នុងការតស៊ូមតិ ដែលឆ្លើយតបទៅនឹងការរំលោភសិទ្ធិមនុស្សដែលសហគមន៍បានប្រឈម។

ពេលវេលាៈ ៥ ម៉ោង ៣០ នាទី

សកម្មភាពៈ

1. ស្លាយបង្ហាញ

2. សកម្មភាពក្រុម
3. ការពិភាក្សា

សម្ភារ:៖

1. កុំព្យូទ័រ និងម៉ាស៊ីនបញ្ចាំង
2. ក្រដាសផ្ទាំងសធំ
3. ប៊ិចហ្វឺត
4. ក្រដាសបិត (Post-Its) ឬ ក្រដាសពណ៌ដែលមានទំហំប្រហាក់ប្រហែលគ្នា
5. ស្កុត

**ជំហាន៖**

**ការចែករំលែក និងការបំផុសគំនិត (១៥ នាទី)**

1. ចែកក្រដាសបិទ (Post-It) ឬក្រដាសពណ៌ដល់អ្នកចូលរួម។
2. ប្រាប់ឱ្យអ្នកចូលរួមសរសេរនៅលើក្រដាសពណ៌រាល់សកម្មភាពតស៊ូមតិ ដែលពួកគេបានចូលរួមពីមុន។ ប្រសិនបើ អ្នកចូលរួមមិនដែលចូលរួមក្នុងសកម្មភាពតស៊ូមតិណាមួយ ឬមិនច្បាស់ថា តើសកម្មភាពដែលពួកគេបានចូលរួម គឺជាសកម្មភាពតស៊ូមតិ អនុញ្ញាតឱ្យពួកគេសរសេរសកម្មភាពណាក៏ដោយ។
3. សុំឱ្យអ្នកចូលរួមបិទក្រដាសរបស់ពួកគេនៅលើក្ដារ។
4. ធ្វើចំណាត់ថ្នាក់ក្រដាសពណ៌យោងតាមសកម្មភាពតស៊ូមតិ និងសកម្មភាពមិនតស៊ូមតិ។ ឧទាហរណ៍៖ សកម្មភាពជាក្រុម ដែលរួមបញ្ចូលទាំងការចែករំលែកព័ត៌មានការអប់រំ ឬការពង្រឹងសមត្ថភាពទៅជាក្រុមមួយ ហើយដាក់សកម្មភាពទាក់ទងនឹងការតស៊ូមតិគោលនយោបាយនៅក្នុងក្រុមផ្សេងទៀត។
5. ជូនដំណឹងដល់អ្នកចូលរួមថា តើមួយណាជាសកម្មភាពតស៊ូមតិ និងមួយណាមិនមែន។ ឧទាហរណ៍៖ ជាទូទៅមានការយល់ខុសក្នុងចំណោមសមាជិកសហគមន៍ ដែលចូលរួមក្នុងកម្មវិធីរបេង ដើម្បីសំដៅលើខ្លួនឯងថា ជាអ្នកតស៊ូមតិ នៅពេលដែលការពិត ពួកគេអាចជាអ្នកប្រឹក្សាយោបល់ ឬជាអ្នកអប់រំ។ ប្រើ*ព័ត៌មានអប្បបរស្តង់ដារសម្រាប់ផ្តល់ធាតុចូល និងពិភាក្សាអំពីជំងឺរបេង និងសិទ្ធិមនុស្ស សម្រាប់ជាឯកសារយោង (Minimum Standard Information for Input and Discussion on TB and Human Rights for reference)* នៅក្នុងទំព័របន្ទាប់ សម្រាប់ជាឯកសារយោង។

**ការពិភាក្សា (១៥ នាទី)**

1. ណែនាំអ្នកចូលរួមក្នុងការពិភាក្សាអំពីការតស៊ូមតិ។ អ្នកអាចប្រើស្លាយបង្ហាញ ប្រសិនបើចាំបាច់។ ប្រើព័ត៌មានស្តង់ដារអប្បបរមា សម្រាប់បញ្ចូលមតិ និងពិភាក្សាលើការតស៊ូមតិជាការណែនាំ។

2. សួរអ្នកចូលរួមម្តងទៀតថា តើក្នុងចំណោមពួកគេ បានចូលរួមក្នុងសកម្មភាពតស៊ូមតិដែរឬទេ? ប្រសិនបើមានអ្នកចូលរួមដែលធ្លាប់ចូលរួមក្នុងសកម្មភាពតស៊ូមតិពីមុន សូមឱ្យពួកគេពីនាក់ចែករំលែកបទពិសោធន៍ដល់អ្នកចូលរួមដទៃទៀត។
3. អញ្ជើញសំណួរពីអ្នកចូលរួម និងជួយសម្រួលដល់ការពិភាក្សា។ សួរពួកគេនូវសំណួរខាងក្រោម៖
   a. តើអ្វីជាការសំខាន់ ដែលធ្វើឱ្យអ្នកចូលរួមក្នុងការងារតស៊ូមតិ?
   b. តើមានបញ្ហាប្រឈមអ្វីខ្លះ ក្នុងការងារតស៊ូមតិ?
   c. គិតអំពីការឆ្លើយតបនឹងរបេងនាពេលបច្ចុប្បន្ន។ តើផ្នែកណាខ្លះ ដែលអ្នកគិតថា ការតស៊ូមតិនឹងមានប្រយោជន៍?

## ការងារក្រុម (៩០ នាទី)

1. ចែកអ្នកចូលរួមជា ៤ ក្រុម។
2. ផ្តល់ក្រុមនីមួយៗនូវ ក្រដាសផ្ទាំងសធំ ប៊ិចហ្វឺត និងក្រដាសពណ៌បិត (Post-Its).
3. ណែនាំដល់ពួកគេនូវក្របខណ្ឌតស៊ូមតិ។ អ្នកអាចប្រើប្រាស់*ព័ត៌មានអប្បបរមាស្តង់ដារសម្រាប់ផ្តល់ជាតុចូល និងពិភាក្សាលើការតស៊ូមតិ* ជាការណែនាំបាន។
4. ណែនាំក្រុម ឱ្យបំពេញជំហានផ្សេងៗគ្នានៅក្នុងក្របខ័ណ្ឌតស៊ូមតិ ដោយប្រើព័ត៌មានដែលបានបង្កើតដោយសកម្មភាពមុនៗ ។
   a. អ្នកចូលរួមអាចជ្រើសរើសពីក្រដាសបិត(Post-It) អំពីសកម្មភាពនៃការរើសអើង និងការរំលោភសិទ្ធិមនុស្ស ឬការចងក្រងឯកសារស្តីពីការរំលោភសិទ្ធិមនុស្ស ចំពោះបញ្ហា ដែលពួកគេចង់ឱ្យដោះស្រាយជាមួយនឹងការតស៊ូមតិ។
   b. ប្រធានបទ ដែលអ្នកចូលរួមបានសរសេរអំពីបទពិសោធន៍របស់ពួកគេ កំណត់សកម្មភាពនៃការរើសអើង និងការរំលោភបំពាន ថា គឺជាផ្នែកមួយនៃការវិភាគបញ្ហា។
   c. ការងារក្រុម ដែលអ្នកចូលរួមជាអ្នកកំណត់អត្តសញ្ញាណ អ្នកបំពេញកាតព្វកិច្ច ឬភាគីពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល ដែលមានកាតព្វកិច្ចដោះស្រាយការរំលោភសិទ្ធិមនុស្ស អាចផ្តល់បញ្ជីឈ្មោះដែលអាចធ្វើទៅបានជាសម្ព័ន្ធ និងគោលដៅតស៊ូមតិ។
   d. ក្រុមទាំងនោះក៏នឹងត្រូវកំណត់ណធនធាននានា ដែលពួកគេត្រូវការ ដើម្បីអនុវត្តការតស៊ូមតិរបស់ពួកគេ។ រំលឹកអ្នកចូលរួមថា ធនធានមិនត្រូវបានកំណត់ចំពោះមូលនិធិតែមួយមុខនោះទេ។ មនុស្សដែលនឹងត្រូវធ្វើការងារជាក់ស្តែង អង្គការដៃគូ ការផ្គត់ផ្គង់ដែលមាន សម្ភារៈ និងកន្លែងការិយាល័យ ក៏ជាធនធានផ្សេងៗផងដែរ។
5. បន្ទាប់ពីក្រុមទាំងអស់បានរៀបចំលទ្ធផលរបស់ពួកគេហើយ សូមឱ្យក្រុមនីមួយៗចែករំលែក។ អញ្ជើញឱ្យមានមតិយោបល់ និងសំណួរពីក្រុមផ្សេងទៀត។ អ្នកសម្របសម្រួលក៏គួរចែករំលែកមតិយោបល់លើលទ្ធផលនៃការងារជាក្រុម ដើម្បីធានាថាអ្នកចូលរួមត្រូវបានណែនាំអំពីរបៀបធ្វើការតស៊ូមតិ។

## សុន្ទរកថាខ្លីដែលបង្ហាញគំនិត (90 minutes)

ជំនាញតស៊ូមតិ ត្រូវបានពង្រឹងបន្ថែមនៅពេលអ្នកចូលរួមមានឱកាសអនុវត្តនូវចំណេះដឹង និងជួយដល់ផែនការការងាររបស់ពួកគេ អំពីអ្វីដែលពួកគេបានសិក្សាកន្លងមក។ សុន្ទរកថាខ្លី ដែលបង្ហាញគំនិតនេះ គឺជាលំហាត់រហ័សមួយ ដែលអនុញ្ញាត ឱ្យអ្នកចូលរួមធ្វើឱ្យច្បាស់លាស់នូវសារតស៊ូមតិរបស់ពួកគេ ហើយបង្ហាញវាដល់អ្នកពាក់ព័ន្ធដោយពេលវេលាមានកំណត់។

1. ចំពោះក្រុមដូចគ្នា សូមផ្តល់ពេល ៦០នាទីដល់អ្នកចូលរួម ដើម្បីរៀបចំការសម្តែងសុន្ទរកថាខ្លីរបស់ពួកគេ។
2. ប្រាប់ឱ្យក្រុមបង្កើតឈុតឆាក ឬសេណារីយ៉ូដែលពួកគេនឹងជួបគោលដៅជាក់លាក់មួយ (ជំហានទី៤ នៃក្របខណ្ឌតស៊ូមតិ) ដើម្បីលើកយកបញ្ហា ឬបញ្ហាជាក់លាក់មួយ (ជំហានទី២) និងបង្ហាញដំណោះស្រាយជាក់លាក់មួយ (ជំហានទី៣) ដោយមានគោលបំណង នៃការបញ្ចុះបញ្ចូលចំពោះគោលដៅ ដើម្បីគាំទ្រការងាររបស់ពួកគេ និងចែករំលែកផែនការរបស់ពួកគេបន្ទាប់ពីនោះ (ជំហានទី ៦ និងទី ៧) ។
3. ទុកពេលខ្លះឱ្យក្រុមទាំងអស់ ហាត់សមសុន្ទរកថាខ្លីរបស់ពួកគេ។
4. បន្ទាប់ពីការរៀបចំរួច ក្រុមនីមួយៗនឹងធ្វើការផ្លាស់ប្តូរតួនាទីសម្តែងតួ ជាសុន្ទរកថាខ្លីរបស់ពួកគេ។
5. អញ្ជើញសំណួរ និងយោបល់ពីអ្នកចូលរួមផ្សេងទៀត។ ក្នុងនាមជាអ្នកសម្របសម្រួល ចែករំលែកមតិយោបល់អំពីប្រសិទ្ធភាពនៃសុន្ទរកថាខ្លី ដែលអ្នកចូលរួមកំពុងធ្វើបទបង្ហាញក៏ប្រសើផងដែរ។
6. សួរអ្នកចូលរួម ថាតើពួកគេមានអារម្មណ៍យ៉ាងណា ចំពោះការធ្វើសុន្ទរកថាខ្លីនេះ។ ស្វែងយល់ពីអ្វីផ្សេងទៀត ដែលពួកគេត្រូវការ ដើម្បីបង្កើនជំនាញតស៊ូមតិរបស់ពួកគេ។

## ផែនការសកម្មភាពតស៊ូមតិ (៩០ នាទី)

1. ឱ្យអ្នកចូលរួមត្រឡប់ទៅក្រុមរបស់ពួកគេវិញ។
2. ផ្តល់ជូនពួកគេនូវក្រដាសផ្ទាំងសធំ ប៊ិចហ្វឺត ក្រដាសបិត និងស្កុត។
3. ចែករំលែកជាមួយក្រុមនីមួយៗនូវទម្រង់ផែនការតស៊ូមតិ (ឧបសម្ព័ន្ធ ៤) ។ ពិភាក្សាលើយោបល់បញ្ចូលទៅក្នុងផែនការតស៊ូមតិ នឹងបានមកពីក្របខណ្ឌផែនការតស៊ូមតិ ដែលពួកគេបានបង្កើតដំបូង ប៉ុន្តែនឹងអនុញ្ញាតឱ្យពួកគេផ្តោតលើរយៈពេលជាក់លាក់មួយ (ឧទាហរណ៍មួយឆ្នាំ) សម្រាប់ការអនុវត្ត។
4. ណែនាំក្រុមទាំងអស់ឱ្យបំពេញជួរឈរនៃទម្រង់ផែនការ ដោយប្រើលទ្ធផលនៃសកម្មភាពពីមុននេះ ដោយមានរយៈពេល ១ឆ្នាំ។
5. ឱ្យក្រុមទាំងអស់ ចែករំលែកលទ្ធផលរបស់ពួកគេ នៅពេលបានបំពេញចប់។
6. ផ្តល់មតិត្រឡប់ទៅពួកគេវិញ ចំពោះលទ្ធផលរបស់ក្រុមពួកគេ។

## ការពិភាក្សារួម(ពេញអង្គ) (៣០ នាទី)

1. ប្រមូលផ្តុំអ្នកចូលរួម ហើយធ្វើការសង្ខេបសៀវភៅណែនាំនេះ។ អ្នកអាចប្រើប្រាស់នូវចំណុចខាងក្រោម ដើម្បីចាប់ផ្តើមការពិភាក្សា៖
    a. តើអ្នកគិតយ៉ាងណាចំពោះបទពិសោធន៍ ក្នុងការឆ្លងកាត់វគ្គបណ្តុះបណ្តាលនៅថ្ងៃនេះ?
    b. តើអ្នកចូលចិត្តសកម្មភាពអ្វីខ្លះ?
    c. តើអ្វីខ្លះ ជាផលពិបាកបំផុតសម្រាប់អ្នក?
    d. តើអ្នកយកឈ្នះឧបសគ្គទាំងនោះដោយរបៀបណា?
    e. តើអ្នកគិតថា ខ្លួនឯងជាអ្នកតស៊ូមតិមួយរូបឬទេ?
    f. តើមានអ្វីខ្លះទៀត ដែលអ្នកត្រូវការ ដើម្បីតស៊ូមតិ?
2. កត់ចំណាំការឆ្លើយតបរបស់អ្នកចូលរួម។ អ្នកអាចប្រើប្រាស់វា ដើម្បីធ្វើឱ្យប្រសើរឡើងនូវវគ្គបណ្តុះបណ្តាលអំពីការតស៊ូមតិ នាពេលខាងមុខ ឬដើម្បីរៀបចំផែនការកសាងសមត្ថភាពជំនាញបន្ត។

## ព័ត៌មានស្ដង់ដារអេប្បបរមាសម្រាប់ការបញ្ចូលមតិ និងការពិភាក្សាអំពីជំងឺរបេង និងសិទ្ធិមនុស្ស
## (សម្រាប់ជាឯកសារចែកដល់អ្នកចូលរួម ឬស្លាយបង្ហាញ)

### តើអ្វីគឺជាការតស៊ូមតិ?

ការតស៊ូមតិ គឺជាដំណើរការនៃការបញ្ចុះបញ្ចូល ឬជះឥទ្ធិពលដល់មនុស្ស ដែលមានជំហរធ្វើឱ្យមានការផ្លាស់ប្ដូរ ឬទាញយកចេញនូវកម្មវិធី ច្បាប់ និងគោលនយោបាយ។ ជាធម្មតាវាត្រូវបានធ្វើឡើងដោយក្រុម ដែលចែករំលែកបញ្ហា និងកង្វល់ស្រដៀងគ្នា។

### តើអ្វី ជាគោលបំណងនៃការតស៊ូមតិ?

ការតស៊ូមតិងាយស្រួលនឹងយល់ច្រឡំជាមួយការអប់ រំឬសកម្មភាពលើកកម្ពស់ការយល់ដឹងនានា។ មិនដូចសកម្មភាពទាំងនោះទេ គោលបំណងលើកកម្ពស់ចំណេះដឹង ឬការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីបញ្ហាមួយចំនួន ការតស៊ូមតិមានគោលបំណងជាក់លាក់ ដើម្បីមានឥទ្ធិពលដល់ការបង្កើត ឬការផ្លាស់ប្ដូរផ្នែកច្បាប់ គោលនយោបាយ និងកម្មវិធី។ ឧទាហរណ៍ៈ ការបញ្ចុះបញ្ចូល ដើម្បីបង្កើតច្បាប់ជាតិស្ដីពីជំងឺរបេង គឺជាសកម្មភាពតស៊ូមតិ។ ការធ្វើសិក្ខាសាលាស្ដីពីជំងឺរបេងតែម្នាក់ឯង មិនមែនជាសកម្មភាពតស៊ូមតិទេ។ ទោះយ៉ាងណាសិក្ខាសាលាអាចជាសកម្មភាពគាំទ្រនិងបំពេញបន្ថែមសកម្មភាពតស៊ូមតិ។

### តើអ្នកណាជាគោលដៅនៃការតស៊ូមតិ?

វិធីសាស្ត្រមួយ ដើម្បីកំណត់ថាតើសកម្មភាពមួយណា គឺជាសកម្មភាពតស៊ូមតិ គឺយើងត្រូវដឹងថា តើគោលដៅជានរណាខ្លះ។ ការតស៊ូមតិ ផ្ដោតសំខាន់ទៅលើអ្នកដែលមានអំណាច និងឥទ្ធិពល ដើម្បីធ្វើការផ្លាស់ប្ដូរ ឬទាញយកចេញ ឬកែសម្រួលនូវគោលនយោបាយ ច្បាប់ ឬកម្មវិធី។ ឧទាហរណ៍ៈ ការតស៊ូមតិផ្ដោតលើអ្នកតាក់តែងច្បាប់ (អ្នកដែលបង្កើតច្បាប់) ចៅក្រមនៃតុលាការកំពូល (អ្នកដែលបង្កើតយុត្តិធម៌សាស្ត្រ) មេភូមិ (អ្នកដែលបង្កើតគោលការណ៍ និងគោលនយោបាយភូមិ) ឬមន្ត្រីជំនាញរបស់ក្រសួង (អ្នកដែលសម្រេចចិត្តលើប្រភេទកម្មវិធី ថាគួរត្រូវបានអនុវត្ត និងផ្ដល់មូលនិធិ)។

**តើការតស៊ូមតិត្រូវបានធ្វើយ៉ាងដូចម្តេច?**

មានជំហានមួយចំនួនដើម្បីអនុវត្តការតស៊ូមតិដូចបានរៀបរាប់លម្អិតនៅក្នុងក្របខ័ណ្ឌផែនការតស៊ូមតិ។

**ក្របខណ្ឌផែនការនៃការតស៊ូមតិ**

| | |
|---|---|
| ជំហានទី៨ | អនុវត្ត ពិនិត្យតាមដាន និងវាយតម្លៃ |
| ជំហានទី ៧ | បង្កើតផែនការសកម្មភាព |
| ជំហានទី ៦ | កំណត់ធនធាននានាសម្រាប់តស៊ូមតិ |
| ជំហានទី ៥ | កំណត់ដៃគូ ឬសម្ព័ន្ធក្នុងការតស៊ូមតិ |
| ជំហានទី ៤ | កំណត់គោលដៅតស៊ូមតិរបស់អ្នក |
| ជំហានទី ៣ | បង្កើតគោលបំណងជាក់លាក់សម្រាប់កិច្ចការតស៊ូមតិរបស់អ្នក |
| ជំហានទី ២ | ធ្វើការវិភាគ និងស្រាវជ្រាវលើបញ្ហា |
| ជំហានទី ១ | ជ្រើសរើសបញ្ហា |

**ជំហានទី ១៖ ការជ្រើសរើស ឬកំណត់បញ្ហា** - វាពិតជាសំខាន់ និងចាំបាច់ក្នុងការជ្រើសរើសបញ្ហាដែលមានភាពប្រាកដនិយម ដើម្បីអនុវត្តតាមរយៈការតស៊ូមតិ។ មិនត្រូវការនិយាយទេ គឺត្រូវជ្រើសរើសបញ្ហា ដែលអ្នក ឬក្រុមរបស់អ្នកចង់មានការផ្លាសប្តូរ ។ បើមិនដូច្នោះទេ អ្នកអាចបាត់បង់ចំណាប់អារម្មណ៍នៅពេលកំពុងធ្វើវា។ ចូរចងចាំថា ការតស៊ូមតិត្រូវការពេលវេលា ប៉ុន្តែពួកគេក៏នាំមកនូវការផ្លាស់ប្តូរជាមួយនឹងផលប៉ះពាល់ធំបំផុតផងដែរ។

**ជំហានទី ២៖ ការវិភាគ និងស្រាវជ្រាវលើបញ្ហា** - វាចាំបាច់ត្រូវមានចំណេះដឹងអំពីគ្រប់ទិដ្ឋភាពនៃបញ្ហា ដែលជាប្រធានបទនៃការតស៊ូមតិរបស់អ្នក។ ដូចគ្នានេះផងដែរ អ្នកមិនអាចទទួលបានយុទ្ធនាការតស៊ូមតិដោយជោគជ័យនោះទេ បើសិនជាគ្មានភស្តុតាង ដើម្បីគាំទ្រ។ ជំហាននេះអាចត្រូវចំណាយពេលយ៉ាងយូរ ព្រោះតម្រូវឱ្យប្រមូលទិន្នន័យ ពីប្រភពផ្សេងៗគ្នា និងកែច្នៃវាជាព័ត៌មានដែលអ្នកអាចប្រើសម្រាប់ការតស៊ូមតិរបស់អ្នក។

**ជំហានទី ៣៖ កំណត់គោលបំណងជាក់លាក់នៃការតស៊ូមតិ** - នៅពេលបង្កើតគោលបំណងតស៊ូមតិរបស់អ្នក សូមចងចាំការណែនាំដូចខាងក្រោម: S-M-A-R-T ។

- S-pecific (**ជាក់លាក់**)–គោលបំណងត្រូវតែផ្តោតលើបញ្ហា ឬកង្វល់ជាក់លាក់មួយ ដើម្បីកុំឱ្យមានបញ្ហាលើសលប់ពេកលើប្រភេទសកម្មភាពដែលត្រូវធ្វើ។

- M-easurable (**អាចវាស់វែងបាន**)– កំណត់គោលបំណងដែលអ្នក ឬអង្គការរបស់អ្នកអាចកំណត់លទ្ធផលជាក់ស្តែងបាន។ នេះ អាចជាលក្ខខណ្ឌនៃកិច្ចប្រជុំដែលបានកំណត់ ឬកិច្ចព្រមព្រៀងដែលអាចរាប់ជាសមិទ្ធផលបាន។ មិនថាលទ្ធផលតូចកម្រិតណានោះទេ ការដែលមានគោលបំណងដែលអាចវាស់វែងបាន នឹងធានាថាអ្នកកំពុងដើរលើផ្លូវត្រូវ ដើម្បីសម្រេចគោលបំណងរបស់អ្នក។
- A-ppropriate (**សមស្រប**)– កំណត់គោលបំណងតស៊ូមតិដែលនឹងបង្កើតផលប៉ះពាល់ធំបំផុត និងពាក់ព័ន្ធបំផុត។ ក្នុងន័យដូចគ្នានេះដែរសកម្មភាពដែលស្ថិតនៅក្រោមគោលដៅនីមួយៗក៏ត្រូវតែពាក់ព័ន្ធទៅនឹងគោលបំណងផងដែរ ដើម្បីបង្កើតលទ្ធផលខ្លាំងបំផុត។
- R-ealistic (**សមហេតុផល**)– កំណត់គោលបំណងដែលអ្នក ឬស្ថាប័នរបស់អ្នកអាចទៅដល់បាន។ វាប្រហែលជាលើសលប់ពេកក្នុងការកំណត់គោលបំណងដូចជា "ដើម្បីផ្លាស់ប្តូរការឆ្លើយតបទៅនឹងជំងឺរបេង"។
- T-ime-bound (**ពេលវេលាកំណត់**)- កំណត់ពេលវេលាជាក់លាក់មួយ សម្រាប់គោលបំណងការតស៊ូមតិរបស់អ្នក។ ខណៈពេលដែលការតស៊ូមតិផ្ទាល់ត្រូវការពេលយូរ (សូម្បីតែច្រើនឆ្នាំ ឬច្រើនទសវត្សរ៍) ដើម្បីបង្កើតលទ្ធផលបាន ការកំណត់ពេលវេលាជាក់លាក់នឹងអាចធ្វើឱ្យប្រាកដថាសកម្មភាពរបស់អ្នកត្រូវអាចនឹងដើរស្របគ្នាជាមួយគោលដៅតស៊ូមតិដែលអ្នកចង់ផ្តោត។

**ជំហានទី ៤. កំណត់គោលដៅតស៊ូមតិ** - គោលដៅ គឺជាមនុស្សដែលមានអំណាច ឬឥទ្ធិពល ដើម្បីនាំមកនូវការផ្លាស់ប្តូរដែលយើងចង់បាន។ មានគោលដៅផ្ទាល់ - អ្នកដែលបង្កើតច្បាប់គោលនយោបាយកម្មវិធី និងមានគោលដៅមិនផ្ទាល់ - អ្នកដែលអាចមានឥទ្ធិពលឬដាក់សម្ពាធលើគោលដៅផ្ទាល់។

**ជំហានទី ៥. ការកំណត់អត្តសញ្ញាណសម្ព័ន្ធ និងគូប្រជែង**- យុទ្ធនាការតស៊ូមតិភាគច្រើន ត្រូវបានយកឈ្នះដោយការខិតខំរួមគ្នារបស់មនុស្សជាច្រើន។ វាជួយឱ្យមានសម្ព័ន្ធ ឬដៃគូអាចជួយក្នុងយុទ្ធនាការរបស់អ្នកបាន។ ផ្ទុយទៅវិញ អ្នកក៏ត្រូវគិតទុកជាមុនពីក្រុមមនុស្សដែលនឹងប្រឆាំងនឹងយុទ្ធនាការរបស់អ្នកផងដែរ។ ការរំពឹងទុក វត្តមានរបស់ពួកគេមានន័យថា អ្នកអាចរៀបចំ និងត្រៀមខ្លួនរួចសម្រេចសម្រាប់ពួកគេ។

**ជំហានទី 6. ការកំណត់ធនធាននានាសម្រាប់ការតស៊ូមតិ** - យុទ្ធនាការតស៊ូមតិត្រូវការធនធាន។ វាត្រូវការពេលវេលា និងការខំប្រឹងប្រែងផងដែរ។ ខាងក្រោមនេះ គឺជាទម្រង់ផ្សេងៗនៃធនធានដែលអ្នកប្រហែលជាត្រូវការ៖

1. ធនធានហិរញ្ញវត្ថុ
2. ធនធានមនុស្ស
3. ចំណេះដឹង និងជំនាញ
4. ទិន្នន័យ ឬព័ត៌មាន

5. សម្ភារៈ និងធនធានផ្សេងទៀត។

នៅពេលកំណត់ធនធាននានាហើយ ត្រូវប្រាកដថា មានកំណត់ចំណាំអំពីប្រភេទធនធានដែលអ្នក ឬក្រុម ឬអង្គភាពរបស់អ្នកមានរួចហើយ និងធនធាន ដែលអ្នកនៅតែត្រូវការគៀងគរបន្ថែម។ ចំណុចនេះ គឺជាការពិចារណាដ៏សំខាន់មួយនៅពេលដែលអ្នកកំពុងធ្វើផែនការរបស់អ្នក។

**ជំហានទី ៧. ការធ្វើផែនការតស៊ូមតិ** - ផែនការតស៊ូមតិនឹងជួយណែនាំអ្នក នៅពេលដែលអ្នកអនុវត្តយុទ្ធនាការតស៊ូមតិរបស់អ្នក។ អ្នកអាចប្រើទម្រង់សាមញ្ញសម្រាប់ផែនការរបស់អ្នក។ ព័ត៌មានសំខាន់ដែលអ្នកត្រូវឆ្លុះបញ្ចាំងលើទម្រង់ផែនការរបស់អ្នកគឺ៖

1. សកម្មភាពដែលអ្នកត្រូវធ្វើ ពាក់ព័ន្ធនឹងការតស៊ូមតិរបស់អ្នក
2. តើសកម្មភាពទាំងនៅ នឹងជួយអ្នកសម្រេចគោលដៅរបស់អ្នកដោយរបៀបណា?
3. ធនធាននានា ដែលអ្នកត្រូវមាន ដើម្បីធ្វើសកម្មភាពទាំងនេះ
4. នរណាទទួលខុសត្រូវចំពោះសកម្មភាពទាំងនោះ
5. ពេលវេលាជាក់លាក់នៃសកម្មភាពរបស់អ្នក
6.

សូមមើលឧបសម្ព័ន្ធទី ៤ សម្រាប់គំរូផែនការតស៊ូមតិគំរូ។

**ជំហានទី ៨ ការអនុវត្ត ការត្រួតពិនិត្យ និងវាយតម្លៃ** - នៅពេលដែលអ្នកបានឆ្លងកាត់ជំហានទាំងអស់ខាងលើរួចមក និងបានធានានូវអ្វីគ្រប់យ៉ាងដែលត្រូវការ អ្នកត្រៀមខ្លួន ដើម្បីអនុវត្តសកម្មភាពតស៊ូមតិរបស់អ្នក។ ត្រូវប្រាកដថា អ្នកពិនិត្យ និងតាមដានការអនុវត្តសកម្មភាពរបស់អ្នកឱ្យបានទៀងទាត់។ សកម្មភាពនេះ នឹងធានាថាអ្នកកំពុងដើរលើផ្លូវត្រូវ ដឹងអំពីបញ្ហាប្រឈមដែលកំពុងប្រឈម ហើយអ្នកអាចឆ្លើយតបទៅនឹងបញ្ហាទាន់ពេលវេលា។ នៅចុងបញ្ចប់នៃយុទ្ធនាការ វាក៏មានសារៈសំខាន់ផងដែរ ដើម្បីវាយតម្លៃសកម្មភាពទាំងមូល ដើម្បីកំណត់ថា តើអ្នកបានសម្រេចគោលដៅ ឬទេ តើមានអ្វីដែលជួយសម្រួល ឬរារាំងដល់សមិទ្ធិផលទាំងនោះ និងមានផែនការធ្វើយ៉ាងណាឱ្យកាន់តែប្រសើរឡើង នៅក្នុងយុទ្ធនាការបន្ទាប់របស់អ្នក។

## ជំពូកទី ៣៖ ការបិទវគ្គបណ្ដុះបណ្ដាល

ផ្នែកនេះនឹងផ្ដល់ព័ត៌មានលម្អិត នៅពេលអ្នកបញ្ចប់វគ្គបណ្ដុះបណ្ដាល។ មិនថាម៉ូឌុលណា ដែលអ្នកបានប្រើប្រាស់នៅក្នុងសៀវភៅណែនាំនេះទេ វាមានសារៈសំខាន់ណាស់ក្នុងការចាប់ផ្ដើមដំណើរការនៃវគ្គបណ្ដុះបណ្ដាល ហើយមានការបញ្ចប់ជាផ្លូវការដោយសមរម្យ នោះនឹងផ្ដល់ឱ្យអ្នកចូលរួម និងអ្នករៀបចំនូវកន្លែងពិភាក្សា និងចែករំលែកផែនការបន្ទាប់ពីវគ្គបណ្ដុះបណ្ដាល។

ដូចដែលបានរៀបរាប់រួចមកហើយ វគ្គបណ្ដុះបណ្ដាលនេះ គួរតែជាផ្នែកមួយនៃកម្មវិធីរបេងទូលំទូលាយណាមួយ ហើយមិនត្រូវចាត់ទុកថាជាសកម្មភាពដាច់ដោយឡែកឡើយ។ មុនពេលអ្នកបិទវគ្គបណ្ដុះបណ្ដាល សូមផ្ដល់ដំណឹងដល់អ្នកចូលរួមថា ទោះបីជាវគ្គបណ្ដុះបណ្ដាលបានបញ្ចប់ក៏ដោយ វាមិនមានន័យថានេះជាការបញ្ចប់នៃការចូលរួមរបស់អ្នកជាមួយពួកគេទេ។

គោលបំណង៖ បិទវគ្គបណ្ដុះបណ្ដាលជាផ្លូវការ
ពេលវេលា៖ ៧៥ នាទី
សកម្មភាព៖

1. សំយោគ
2. ក្រោយការធ្វើតេស្ដ
3. ការវាយតម្លៃវគ្គបណ្ដុះបណ្ដាល
4. ការផ្ដល់វិញ្ញាបនបត្រ

សម្ភារៈ៖

1. កម្រងសំណួរក្រោយការធ្វើតេស្ដ
2. ទម្រង់វាយតម្លៃការបណ្ដុះបណ្ដាល
3. ប៊ិច
4. វិញ្ញាបនបត្រ

ជំហាន៖

### សំយោគ

មានវិធីផ្សេងៗគ្នាក្នុងការសំយោគវគ្គបណ្ដុះបណ្ដាលទាំងមូល។ អ្នកអាចយកសារស្នូលពីវគ្គ ឬម៉ូឌុលទាំងអស់ដែលបានធ្វើឡើង ហើយរំលឹកឡើងវិញជាមួយអ្នកចូលរួម។ អ្នកក៏អាចបន្ថែមចំនុចដែលទាក់ទាញបំផុត ពីការពិភាក្សា និងជួយសម្រួលដល់ការងារជាក្រុម ដើម្បីឱ្យអ្នកចូលរួមអាចមើលឃើញពីទំនាក់ទំនងគ្នាទៅវិញទៅមក និងការរួម

ចំណែករបស់ពួកគេ នៅក្នុងលទ្ធផលសរុបនៃវគ្គបណ្ដុះបណ្ដាល។ ត្រូវប្រាកដថា អំពីការមានទំនាក់ទំនងគ្នា នៃប្រធានបទនានា នៅពេលអ្នកកំពុងសំយោគ។ ប្រសិនបើអាច អ្នកអាចប្រើប្រាស់ស្លាយបង្ហាញ ដើម្បីអនុវត្ត។

## អនុវត្តការធ្វើតេស្តក្រោយ

ជាគុសំខាន់មួយនៃការបិទវគ្គបណ្ដុះបណ្ដាល គឺការអនុវត្តដំណើរការតេស្តក្រោយវគ្គ។ សកម្មភាពនេះ នឹងផ្ដល់ការពិនិត្យភ្លាមៗជាមួយអ្នកចូលរួម ដើម្បីវាស់ស្ទង់ពីការសិក្សារបស់ពួកគេ បន្ទាប់ពីវគ្គបណ្ដុះបណ្ដាលរួច។

1. ចែកចាយកម្រងសំណួរ។
2. ទុកពេលអោយអ្នកចូលរួម ១៥ នាទី ដើម្បីឆ្លើយសំណួរ។
3. ពន្យល់អ្នកចូលរួមថា នឹងមិនមានបញ្ហាទេ ប្រសិនបើពួកគាត់មិនប្រាកដពីចម្លើយរបស់ពួកគេ។
4. ទុកពេល ១៥នាទីសម្រាប់អ្នកចូលរួម ក្នុងការឆ្លើយសំណួរ។ បន្ទាប់ពីនោះប្រមូលកម្រងសំណួរ។
5. កំណត់កម្រងសំណួរទាំងនោះដោយឡែក ហើយពិនិត្យមើលនៅពេលក្រោយ។ អ្នកអាចប្រើប្រាស់របស់ទាំងនេះ សម្រាប់ការវាយតម្លៃវគ្គបណ្ដុះបណ្ដាល ជាមួយក្រុមការងាររៀបចំវគ្គផងដែរ។

## ការវាយតម្លៃវគ្គបណ្ដុះបណ្ដាល

ក្រៅពីការធ្វើតេស្តក្រោយវគ្គរួចមក ការវាយតម្លៃវគ្គបណ្ដុះបណ្ដាលក៏នឹងអនុញ្ញាត ឱ្យមានការផ្ដល់យោបល់ពីអ្នកចូលរួម ទាក់ទងនឹងបទពិសោធន៍នៃវគ្គបណ្ដុះបណ្ដាលរបស់ពួកគេដែរ។ ការវាយតម្លៃក៏អាចជួយអ្នក និងក្រុមការងាររៀបចំវគ្គផងដែរ ដើម្បីកែលម្អរបៀបសម្របសម្រួលវគ្គបណ្ដុះបណ្ដាលសម្រាប់ពេលបន្តបន្ទាប់ផងដែរ។

1. ចែកចាយទម្រង់វាយតម្លៃដល់អ្នកចូលរួមម្នាក់ៗ។
2. ផ្ដល់ឱ្យអ្នកចូលរួមប្រហែល ១៥នាទី ដើម្បីបំពេញបែបបទ។ ប្រមូលទម្រង់វាយតម្លៃដែលបានបំពេញរួច។
3. កំណត់តាមប្រភេទដោយឡែក និងពិនិត្យពេលក្រោយ។ អ្នកប្រហែលប្រើប្រាស់ការវាយតម្លៃវគ្គ ជាមួយក្រុមការងាររៀបចំវគ្គផងដែរ។

## ការទទួលវិញ្ញាបនបត្រ និងការបិទវគ្គបណ្ដុះបណ្ដាល

អ្នកអាចមានពិធីប្រគល់វិញ្ញាបនបត្រដល់អ្នកចូលរួម។ សកម្មភាពនេះ គឺសំខាន់ណាស់សម្រាប់អ្នកចូលរួម ដែលធ្វើឱ្យពួកគេមានអារម្មណ៍ថា ពួកគេបានសម្រេចអ្វីមួយ បន្ទាប់ពីការបណ្ដុះបណ្ដាល។

សុន្ទរកថាបញ្ចប់ អាចត្រូវបាននិយាយដោយអ្នកតំណាងនៃអ្នករៀបចំវគ្គបណ្ដុះបណ្ដាល។ អ្នកក៏អាចអញ្ជើញនរណាម្នាក់ មកពីកម្មវិធីជាតិរបេង(National TB Programme) អង្គការសុខភាពពិភពលោក(World Health Organization) អង្គការ(Stop TB Partnership) ម្ចាស់ជើងឯកផ្នែកជំងឺរបេង(TB legislative champion) ឬនាយកប្រតិបត្តិមូលដ្ឋាន ឬអ្នកពាក់ព័ន្ធដែលពាក់ព័ន្ធនៅក្នុងប្រទេស ឬតំបន់របស់អ្នក។

# ជំពូកទី ៤៖ ការវាយតម្លៃការបណ្តុះបណ្តាល

នៅពេលខ្លះ អ្នកសម្របសម្រួលវគ្គ មានការធ្វេសប្រហែស ចំពោះដំណើរការសំខាន់ លើការវាយតម្លៃវគ្គបណ្តុះបណ្តាលដែលពួកគេទើបតែបានធ្វើ។ ដំណើរការវាយតម្លៃការបណ្តុះបណ្តាល ជួយអ្នកកំណត់ថា តើអ្នកសម្រេចបានគោលដៅនៃការបណ្តុះបណ្តាលរបស់អ្នកហើយឬនៅ។ លើសពីនេះទៀត ដំណើរការនេះក៏ផ្តល់ឱ្យអ្នកនូវគំនិតថា តើខ្លឹមសារនៃការបណ្តុះបណ្តាលរបស់អ្នកគ្រប់គ្រាន់ ឬខ្វះខាតដែរឬទេ? តើវិធីសាស្ត្របណ្តុះបណ្តាលរបស់អ្នកមានប្រសិទ្ធភាពដែរឬទេ? ហើយថាតើក្រុមបណ្តុះបណ្តាលរបស់អ្នក (អ្នកសម្របសម្រួល អ្នកបង្ហាត់បង្រៀន អ្នករៀបចំឯកសារ បុគ្គលិកគាំទ្រ) និងវាគ្មិនជំនាញ និងប្រសិទ្ធភាពគ្រប់គ្រាន់ឬអត់។ លទ្ធផលនៃការវាយតម្លៃការបណ្តុះបណ្តាល នឹងណែនាំឱ្យកាន់តែប្រសើរឡើង ពេលអ្នកមានគម្រោងសកម្មភាពបណ្តុះបណ្តាលនាពេលអនាគត។

អ្នកនឹងត្រូវដំណើរការវាយតម្លៃរបស់អ្នកជាពីរកម្រិត គឺក្រុមអ្នករៀបចំវគ្គ ឬក្រុមអ្នកបណ្តុះបណ្តាល និងក្នុងចំណោមអ្នកចូលរួម។ ហើយក៏មានវិធីផ្សេងគ្នាក្នុងការធ្វើការវាយតម្លៃផងដែរ។

## ការវាយតម្លៃប្រចាំថ្ងៃផ្ទៃក្នុង

ជាទង្វើល្អ ក្រុមបណ្តុះបណ្តាលរបស់អ្នកគួរតែលះបង់ពេលវេលា ដើម្បីជួបជុំគ្នានៅចុងបញ្ចប់នៃថ្ងៃនីមួយៗ ដើម្បីពិភាក្សាអំពីវគ្គដែលត្រូវបានធ្វើឡើងនៅថ្ងៃនោះ។ សកម្មភាពនេះ គឺជាប្រធានបទដ៏សាមញ្ញសម្រាប់ទទួលព័ត៌មានត្រឡប់ ក្នុងការស្វែងយល់ថា តើដំណើរការនៃវគ្គបណ្តុះបណ្តាលថ្ងៃនោះបានល្អកម្រិតណា ផ្អែកតាមមតិរបស់សមាជិកក្រុមម្នាក់ៗ។ ដូច្នេះ សូមប្រាកដថា ប្រធានបទទាំងនេះនឹងត្រូវបានចងក្រងជាឯកសារយ៉ាងល្អ។ អ្នកអាចប្រើសំណួរខាងក្រោម ដើម្បីណែនាំប្រធានបទវាយតម្លៃប្រចាំថ្ងៃរបស់អ្នក៖

1. តើអ្វី បានដំណើរការល្អនៅក្នុងកិច្ចប្រជុំថ្ងៃនេះ?
2. តើអ្វី មិនបានដំណើរការល្អនៅក្នុងប្រជុំថ្ងៃនេះ?
3. តើយើងនៅតែអាច ដោះស្រាយរាល់បញ្ហាដែលកើតមានថ្ងៃនេះបានទេ? ដោយរបៀបណា? តើយើងអាចបញ្ចូលវគ្គបន្ថែម នៅថ្ងៃស្អែក ដើម្បីឆ្លើយតបនឹងបញ្ហានេះទេ?
4. ត្រូវប្រមើមើល អ្វីដែលនឹងកើតឡើងនៅថ្ងៃបន្ទាប់។

## ការវាយតម្លៃផ្នែកខាងក្នុង (ក្រុមអ្នករៀបចំវគ្គ) ក្រោយបញ្ចប់វគ្គបណ្តុះបណ្តាល

បន្ទាប់ពីបញ្ចប់វគ្គបណ្តុះបណ្តាល ក្រុមអ្នកបណ្តុះបណ្តាលត្រូវជួបប្រជុំគ្នា ដើម្បីវាយតម្លៃសកម្មភាពបណ្តុះបណ្តាលទាំងមូល។ នេះរួមបញ្ចូលទាំង ដំណាក់កាលរៀបចំវគ្គបណ្តុះបណ្តាល ការរៀបចំភស្តុភារក៏ដូចជាវគ្គបណ្តុះបណ្តាលជាក់ស្តែង។ អាចហៅបានថា ដំណើរការវាយតម្លៃនេះត្រូវមានទស្សនវិស័យកាន់តែទូលំទូលាយ។ នេះ គឺជាសំណួរមួយចំនួនដើម្បីណែនាំដំណើរការវាយតម្លៃរបស់អ្នក៖

1. ការរៀបចំ៖

a. តើយើងធ្វើអ្វីបានល្អ?

b. តើមានឧបសគ្គអ្វីខ្លះ?

c. តើយើងត្រូវកែលម្អវិធីសាស្ត្ររបៀបណាដែរ ក្នុងរៀបចំការបណ្តុះបណ្តាលនាពេលខាងមុខ?

2. ការបណ្តុះបណ្តាលត្រឹមត្រូវ៖

a. តើយើងសម្រេចបានគោលបំណងនៃវគ្គបណ្តុះបណ្តាលឬទេ? ប្រសិនបើមិនបានសម្រេចបានទាំងអស់ទេ សូមពិភាក្សាអំពីមូលហេតុ និងវិធីសាស្ត្រដែលវាអាចត្រូវបានដោះស្រាយ។

b. តើវិធីសាស្ត្រដែលយើងប្រើមានប្រសិទ្ធភាព ឬអត់?

c. តើការសម្របសម្រួលវគ្គបណ្តុះបណ្តាលមានប្រសិទ្ធភាពដែរឬអត់?

d. តើការបង្ហាញរបស់វាគ្មិនជំនាញយ៉ាងដូចម្តេចដែរ? តើវាមានប្រសិទ្ធភាពដែរឬអត់?

e. តើគុណភាព និងកម្រិតនៃការចូលរួមរបស់អ្នកចូលរួមបណ្តុះបណ្តាលយ៉ាងដូចម្តេចដែរ?

f. តើមានការប្រឈមអ្វីខ្លះ អំឡុងពេលបណ្តុះបណ្តាល?

g. តើឧបសគ្គទាំងនោះ អាចត្រូវបានប្រើប្រាស់យ៉ាងរបៀបណាដែរ ដើម្បីធ្វើឱ្យប្រសើរឡើងនូវវគ្គបណ្តុះបណ្តាលនាពេលខាងមុខទៀត?

3. ការផ្តល់ការគាំទ្រ៖

a. តើកន្លែងបណ្តុះបណ្តាល កន្លែងស្នាក់នៅ អាហារមានលក្ខណៈយ៉ាងដូចម្តេចដែរ?

b. តើការផ្តល់ការគាំទ្រមានបញ្ហាប្រឈមអ្វីខ្លះ?

c. តើទិដ្ឋភាពការផ្តល់ការគាំទ្រនៃវគ្គបណ្តុះបណ្តាល អាចត្រូវបានកែលម្អសម្រាប់វគ្គបណ្តុះបណ្តាលបន្ទាប់យ៉ាងដូចម្តេចដែរ?

## ការវាយតម្លៃវគ្គបណ្តុះបណ្តាលរបស់អ្នកចូលរួម

វាមានសារៈសំខាន់ណាស់ ក្នុងការទទួលបានមតិយោបល់ត្រឡប់ពីអ្នកចូលរួម លើទិដ្ឋភាពដូចគ្នានៃវគ្គបណ្តុះបណ្តាលទាំងមូល ដូចគ្នានឹងក្រុមអ្នកបណ្តុះបណ្តាលបានវាយវាយតម្លៃផងដែរដូចជា៖

1. សារនៃការបណ្តុះបណ្តាល
2. វិធីសាស្ត្រដែលបានប្រើប្រាស់
3. អ្នកសម្របសម្រួល និងវាគ្មិនជំនាញ។
4. ការផ្តល់ការគាំទ្រ

វាក៏សំខាន់ផងដែរក្នុងការស្នើសុំអនុសាសន៍របស់អ្នកចូលរួម អំពីរបៀបដែលវគ្គបណ្តុះបណ្តាលអាចត្រូវបានកែលម្អ ប្រសិនបើវាត្រូវបានធ្វើឡើងម្តងទៀតជាមួយអ្នកចូលរួមផ្សេងៗ។

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធ ១. កម្រងសំណួរតេស្តមុនវគ្គ / ក្រោយវគ្គ

**សិទ្ធិដកដង្ហើម៖ វគ្គបណ្តុះបណ្តាលស្តីពីសិទ្ធិមនុស្ស សម្រាប់សហគមន៍ដែលរងផលប៉ះពាល់ដោយជំងឺរបេង**

**កម្រងសំណួរតេស្តមុនវគ្គ/ក្រោយវគ្គការ**

1. ជំងឺរបេងឆ្លងតាមរយៈ_________________.
   a. ការចែករំលែកឧបករណ៍ប្រើប្រាស់
   b. ការស្រូបយកដំណក់ទឹកនៅក្នុងខ្យល់។
   c. ចាប់ដៃជាមួយមនុស្សដែលឆ្លងជំងឺរបេង។
   d. ការរួមភេទ
2. តើនរណាដែលងាយរងគ្រោះនឹងជំងឺរបេង?
   a. អ្នកជក់បារី
   b. ប្រជាពលរដ្ឋក្រីក្រ
   c. អ្នកផ្ទុកមេរោគអេដស៍
   d. ទាំងអស់ខាងលើនេះ
3. ជំងឺរបេងអាចព្យាបាលបាន៖ ត្រូវ ខុស
4. ជំងឺរបេងអាចការពារបាន៖ ត្រូវ ខុស
5. មានវិធីសាស្រព្យាបាលបង្ការរបេងថ្មីមួយ ដែលអាចការពារមនុស្សពីជំងឺរបេង។ តើវិធីសាស្ត្រនេះ ជាការចាំបាច់ត្រូវតែអនុវត្ត ដោយអ្នកដែលរងផលប៉ះពាល់ដោយជំងឺរបេងដែរ ឬទេ? ត្រូវ ខុស
6. ជំងឺរបេងឆ្លងតាមរយៈខ្យល់ ដូច្នេះវាមិនអាចទប់ស្កាត់បានទេ៖ ត្រូវ ខុស
7. តើអ្វីខាងក្រោមនេះ គឺជាឧទាហរណ៍នៃសិទ្ធិមនុស្ស៖
   a. សិទ្ធិជក់បារី
   b. សិទ្ធិទទួលបានសុខភាព
   c. សិទ្ធិធ្វើបាប អ្នកដែលបានធ្វើបាបខ្ញុំ
8. ខ្ញុំត្រូវបានគេធ្វើរោគវិនិច្ឆ័យថាមានជំងឺរបេង។ តើខ្ញុំអាចត្រូវគេបណ្តេញចេញពីការងារបានទេ?
   ត្រូវ ខុស
9. ការតស៊ូមតិ គឺជាដំណើរការនៃការផ្លាស់ប្តូរមួយណាដូចខាងក្រោម៖
   a. កម្មវិធី
   b. ច្បាប់

c. ទាំងពីរខាងលើ

d. គ្មានខាងលើ

10. មនុស្សម្នាក់ត្រូវមានអាយុចាប់ពី ១៨ ឆ្នាំឡើងទៅ ដើម្បីទទួលបានសិទ្ធិមនុស្សៈ ត្រូវ ខុស

11. តើអ្នកដែលមានជំងឺរបេង មានសិទ្ធិប្តឹងពីការរំលោភបំពានដែលពួកគេជួបប្រទះដែរឬទេ? ត្រូវ ខុស

12. ប្រទេសខ្ញុំ មិនផ្តល់អាទិភាពដល់ការអភិវឌ្ឍ ឬការធ្វើឱ្យប្រាកដថា អ្នកដែលមានជំងឺរបេងអាចទទួលបានថ្នាំថ្មី។ តើរដ្ឋាភិបាលកំពុងរំលោភសិទ្ធិខ្ញុំទេ? ត្រូវ ខុស

13. អ្នកដែលមានជំងឺរបេងជាអ្នកជំងឺ ដូច្នេះពួកគេមិនគួរអនុញ្ញាតឱ្យទៅសាលារៀនទេ។ ត្រូវ ខុស

14. អ្នកដែលមានជំងឺរបេងគួរ តែចូលរួមក្នុងការអភិវឌ្ឍកម្មវិធីដែលទាក់ទងនឹងជំងឺរបេង។ ត្រូវ ខុស

15. អ្នកដែលមានជំងឺរបេងគួរតែត្រូវបានអនុញ្ញាតឱ្យឈរឈ្មោះធ្វើការ។ ត្រូវ ខុស

## ឧបសម្ព័ន្ធទី ២. គម្រូឧបករណ៍ចងក្រងឯកសារ

### ការចងក្រងឯកសារទាក់ទងនឹងការរំលោភសិទ្ធិមនុស្សចំពោះអ្នកជំងឺរបេង

| | | |
|---|---|---|
| ឈ្មោះ: | | អាយុ |
| ទីលំនៅ | | |
| អត្តសញ្ញាណយេនឌ័រ | ស្ថានភាពអាពាហ៍ពិពាហ៍ | |
| ចំនួនសមាជិកក្នុងបន្ទុក: | | |
| ការទទួលបានការអប់រំ: | | |
| ប្រភពចំណូល | ប្រាក់ចំណូលជាមធ្យមប្រចាំខែ | |

របាយការណ៍អាំងស៊ីដង់ (ភាពរងគ្រោះពីការរំលោភបំពាន)

កាលបរិច្ឆេទ និងពេលវេលា: ____________________________________________

ទីកន្លែងនៃឧប្បត្តិហេតុ: ____________________________________________

ជនបង្ក(មួយ ឬច្រើន): ____________________________________________

ការពិពណ៌នាអំពីឧប្បត្តិហេតុ៖

________________________________________________________________

________________________________________________________________

________________________________________________________________

________________________________________________________________

________________________________________________________________

________________________________________________________________

____________________

ឈ្មោះអ្នកសម្ភាសន៍:

កាលបរិច្ឆេទសម្ភាសន៍:

ទីកន្លែងសម្ភាសន៍:

## ឧបសម្ព័ន្ធ ៣ គម្រូការបញ្ជាក់ពីការយល់ព្រម

អ្នកចូលរួមជាទីគោរព:

ពួកយើងសង្ឃឹមថាអ្នកសុខសប្បាយជាទេ!

ពួកយើងមកពី [ឈ្មោះអង្គការ] នឹងធ្វើការសម្ភាសន៍អ្នក ក្នុងគោលបំណងស្វែងរកមេធាវី ឬសំណងស្របច្បាប់សម្រាប់បទពិសោធន៍ដែលអ្នកមាន។

គោលបំណងនៃការសម្ភាសន៍នេះ គឺដើម្បី [បញ្ជាក់ពីគោលបំណងរបស់អ្នកនៅទីនេះ] ស្វែងយល់ពីបទពិសោធន៍ ដែលអ្នកបានជួបប្រទះ ហើយអ្នកចង់ស្វែងរកវិធីដោះស្រាយ និង(ខ) ស្វែងយល់ពីការគាំទ្រចាំបាច់ ដែលយើងអាចផ្តល់ជូន ដើម្បីដោះស្រាយបញ្ហារបស់អ្នក។

ការសម្ភាសន៍នេះ នឹងត្រូវធ្វើឡើងតាមការយល់ព្រមពីអ្នក។ ដូច្នេះ ការចូលរួមរបស់អ្នកក្នុងការសម្ភាសន៍នេះ ជាការស្ម័គ្រចិត្ត។ អ្នកអាចជ្រើសរើសមិនឆ្លើយសំណួរណាមួយ ដែលអ្នកគិតថាមិនសមរម្យ ឬមិនស្រួល។ យើងក៏អាចបញ្ឈប់ការសម្ភាសន៍នៅពេលណាក៏បានតាមការស្នើសុំ។

រាល់ព័ត៌មានដែលអ្នកនឹងផ្តល់ជូនក្នុងការសម្ភាសន៍នេះ គឺត្រូវបានរក្សាការសម្ងាត់បំផុត ហើយនឹងត្រូវបានប្រើប្រាស់ក្នុងគោលបំណង ដែលអ្នក និងអ្នកសំភាសន៍ ឬអង្គការ បានឯកភាពគ្នា។ យើងក៏អាចស្នើសុំឯកសារនានា ដើម្បីគាំទ្រការសម្ភាសន៍របស់អ្នកផងដែរ។ សូមជានាថា ព័ត៌មាននឹងត្រូវបានប្រើប្រាស់ ដើម្បីផ្តល់ជាបរិបទបន្ថែម ហើយនឹងមិនត្រូវបានបោះពុម្ពផ្សាយក្នុងវិធីណាមួយឡើយ។ រយៈពេលនៃការសម្ភាសន៍នឹងត្រូវកត់ត្រាទុក។

មុនពេលប្រើប្រាស់ផ្នែកណាមួយនៃការសម្ភាសន៍ តម្រូវឱ្យមានការការយល់ព្រមរបស់អ្នក។

ប្រសិនបើអ្នកយល់ព្រមចូលរួមក្នុងការសម្ភាសន៍ សូមចុះហត្ថលេខានៅខាងក្រោម។

សូមអរគុណច្រើនចំពោះការចូលរួមរបស់អ្នក។

ដោយក្តីស្មោះត្រង់

[បញ្ជាក់ឈ្មោះអ្នកសម្ភាសន៍នៅទីនេះ]

[បញ្ជាក់ឈ្មោះរបស់អង្គការ នៅទីនេះប្រសិនបើមាន]

☐ អ្នកចូលរួមយល់ព្រមសម្ភាសន៍

________________________________

ហត្ថលេខារបស់អ្នកសម្ភាសន៍ / កាលបរិច្ឆេទ

កំណត់កាលបរិច្ឆេទនិងពេលវេលា៖

☐ មូលហេតុដែលអ្នកចូលរួមមិនយល់ព្រម៖ ________________________________

## ឧបសម្ព័ន្ធ ៤៖ គម្រូនៃទម្រង់ផែនការតស៊ូមតិ

| គោលបំណង | សកម្មភាព | សម្ព័ន្ធ និងដៃគូមានសក្តានុពល | ធនធានដែលត្រូវការ | រយៈពេលកំណត់ |
|---|---|---|---|---|
| | | | | |
| | | | | |
| | | | | |
| | | | | |

## ឧបសម្ព័ន្ធទី ៥៖ របៀបវារៈនៃវគ្គបណ្តុះបណ្តាលទាំងមូល

| ពេលវេលា | ប្រធានបទ | សកម្មភាព | មនុស្សដែលចូលរួម |
|---|---|---|---|
| **ថ្ងៃទី ១** | | | |
| 8.30 – 9.00 | ការចុះឈ្មោះ | | អ្នករៀបចំកម្មវិធី |
| 9.00 – 9.40 | ការបើកកម្មវិធី | ការបើកកិច្ចស្វាគមន៍ | |
| | | ការណែនាំខ្លួនរបស់អ្នកចូលរួម | |
| | | ការរំពឹងទុក និងគោលបំណង | |
| | | វិន័យក្នុងកិច្ចប្រជុំ | |
| 9.40 – 9.50 | ការធ្វើតេស្តមុនវគ្គ | | អ្នកចូលរួម |
| 9.50 – 10.15 | ស្ថានភាពជម្ងឺរបេង | ស្លាយបង្ហាញ | អ្នកសម្របសម្រួលវគ្គ |
| 10.15 – 10.30 | សម្រាកពេលព្រឹក | | |
| 10.30 – 11.30 | របេង១០១ | សកម្មភាពបង្វិលជុំ | អ្នកសម្របសម្រួលវគ្គ<br>អ្នកចូលរួម |
| 11.30 – 12.00 | បញ្ហាទាក់ទងនឹងជំងឺរបេងនៅក្នុងសហគមន៍ | ការបំផុសគំនិត | អ្នកសម្របសម្រួលវគ្គអ្នកចូលរួម |
| 12.00 – 13.00 | សម្រាកអាហារថ្ងៃត្រង់ | | |
| 13.00 – 14.00 | ជំងឺរបេង និងសិទ្ធិមនុស្ស | ការសរសេរលិខិត | អ្នកចូលរួម |
| 14.00 – 15.00 | | ការចែករំលែកជាក្រុម | អ្នកចូលរួម |
| 15.00 – 15.15 | | ការផ្តុកនិងសមាធិ | អ្នកចូលរួម |
| 15.00 – 15.30 | សម្រាកថ្ងៃត្រង់ | | |
| 15.30 – 17.00 | ជំងឺរបេង និងសិទ្ធិមនុស្ស | ការងារជាក្រុម<br>ការបង្ហាញរួម | អ្នកចូលរួម |
| **ថ្ងៃទី ២** | | | |
| 9.00 – 9.30 | ជំងឺរបេងនិងសិទ្ធិមនុស្ស | សង្ខេបឡើងវិញ | អ្នកសម្របសម្រួលវគ្គ |

| | | | |
|---|---|---|---|
| 9.30 – 11.30 | | ការសម្តែងតួរ (សម្រាកអាហារសម្រន់) | អ្នកចូលរួម |
| 11.30 – 12.30 | | ការងារជាក្រុម៖ ការធ្វើតារាង ឬបញ្ជីនៃសិទ្ធិត្រូវបានរំលោភ<br>បទបង្ហាញជាក្រុម<br>សំយោគ | អ្នកចូលរួម |
| 12.30 – 13.30 | សម្រាកអាហារថ្ងៃត្រង់ | | |
| 13.30 – 14.30 | ការគៀងគរសហគមន៍សម្រាប់ចងក្រងឯកសារស្តីពីសិទ្ធិមនុស្ស | បទសម្ភាសន៍សាកល្បង | អ្នកសម្របសម្រួលវគ្គ |
| 14.30 – 15.30 | | | អ្នកចូលរួម |
| 15.30 – 15.45 | សម្រាកថ្ងៃត្រង់ | | |
| 15.45 – 16.45 | ការគៀងគរសហគមន៍សម្រាប់ចងក្រងឯកសារស្តីពីសិទ្ធិមនុស្ស | ការងារជាក្រុម៖ គូសផែនទីអ្នកផ្តល់សេវាកម្ម | អ្នកចូលរួម |
| 16.45 – 17.00 | | ស្លាយបង្ហាញស្តីពីការចងក្រងឯកសារស្តីពីសិទ្ធិមនុស្សនិងគន្លឹះក្នុងការសម្ភាស | អ្នកសម្របសម្រួលវគ្គ |
| **ថ្ងៃទី ៣** | | | |
| 9.00 – 9.30 | ការគៀងគរសហគមន៍សម្រាប់ចងក្រងឯកសារស្តីពីសិទ្ធិមនុស្ស | សង្ខេបឡើងវិញ | អ្នកសម្របសម្រួលវគ្គ |
| 9.30 – 10.15 | ការតស៊ូមតិ | ស្លាយបង្ហាញ | អ្នកសម្របសម្រួលវគ្គ |
| 10.15 – 10.30 | **សម្រាកពេលព្រឹក** | | |
| 10.30 – 12.30 | ជំនាញក្នុងការតស៊ូមតិ | ការងារជាក្រុម៖ ការផ្លាស់ប្តូរពីបញ្ហាទៅជាការឆ្លើយតប | អ្នកចូលរួម |
| 12.30 – 13.30 | សម្រាកអាហារថ្ងៃត្រង់ | | |
| 13.30 – 15.30 | ជំនាញក្នុងការតស៊ូមតិ | ការងារជាក្រុម៖ ការធ្វើផែនការតស៊ូមតិ | អ្នកចូលរួម |
| 15.30 – 15.45 | សម្រាកថ្ងៃត្រង់ | | |
| 15.45 – 16.00 | ការសំយោគវគ្គបណ្តុះបណ្តាល | | អ្នកសម្របសម្រួលវគ្គ |
| | ការធ្វើតេស្តក្រោយវគ្គ | | អ្នកចូលរួម |

| | | | |
|---|---|---|---|
| 16.00 – 16.15 | | | |
| 16.15 – 16.30 | ការវាយតំលៃវគ្គ | | អ្នកចូលរួម |
| 16.30 – 17.00 | ការបិទវគ្គបណ្ដុះបណ្ដាល និង ការប្រគល់វិញ្ញាបនប័ត្រ | | អ្នកចូលរួម |
| បញ្ចប់ | | | |

## ឧបសម្ព័ន្ធទី ៦៖ ទម្រង់វាយតម្លៃ

# ទម្រង់វាយតម្លៃ

## I. មាតិកា វិធីសាស្ត្រ អ្នកសម្របសម្រួល វាគ្មិន និងអ្នកចូលរួម

1. វាយតម្លៃវគ្គដូចខាងក្រោម:

| *ប្រធានបទ* | *ល្អបំផុត* | *ល្អ* | *មធ្យម* | *មិនល្អ* | *គ្មានចម្លើយ* |
|---|---|---|---|---|---|
| ការតម្រងទិសមូលដ្ឋានស្តីពីជំងឺរបេង | | | | | |
| ជំងឺរបេង និងសិទ្ធិមនុស្ស | | | | | |
| សរសេរលិខិត | | | | | |
| ការចែករំលែកក្រុម | | | | | |
| ការងារក្រុម៖ ការកំណត់ការរំលោភបំពាន និងផលប៉ះពាល់ | | | | | |
| ការសម្តែងតួរ | | | | | |
| ការបញ្ចូលមតិលើសិទ្ធិមនុស្ស | | | | | |
| ការចងក្រងឯកសារអំពីការរំលោភសិទ្ធិមនុស្ស | | | | | |
| ការតម្រង់ទិសការតស៊ូមតិ | | | | | |

2. តើប្រធានបទណាមួយ ដែលទាក់ទងនឹងការងាររបស់អ្នកខ្លាំងបំផុត? ហេតុអ្វី?

______________________________________________________________

______________________________________________________________

______________________________________________________________

______________________________________________________________

____________________________

3. ប្រធានបទណាមួយ ដែលទាក់ទងនឹងការងាររបស់អ្នកតិចបំផុត? ហេតុអ្វី?

______________________________________________________________

______________________________________________________________

______________________________________________________________

______________________________________________________________

____________________________

4. តើអ្នកអាចនិយាយអ្វីខ្លះ អំពីវិធីសាស្ត្រ និងដំណើរការដែលត្រូវបានប្រើប្រាស់ នៅក្នុងវគ្គបណ្តុះបណ្តាលនេះទេ?

5. តើអ្នកមានការយល់ឃើញបែបណាខ្លះ អំពីអ្នកសម្របសម្រួល និងវាគ្មិន?

II. ផ្នែកភស្តុភា និងគាំទ្រ

| | ល្អបំផុត | ល្អ | មធ្យម | មិនល្អ | សូមពន្យល់ |
|---|---|---|---|---|---|
| បន្ទប់បណ្តុះបណ្តាល | | | | | |
| បន្ទប់សណ្ឋាគារ | | | | | |
| អាហារ | | | | | |
| ឯកសារ និងសម្ភារៈ | | | | | |
| ជំនួយផ្សេងៗ | | | | | |

III. យោបល់ និងសំណូមពរផ្សេងៗ ដើម្បីកែលំអសកម្មភាពបណ្តុះបណ្តាលនាពេលអនាគត